សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការលែងលះរវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ នៅប្រទេសកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ លោក **ខ៉ែត សាមីត**
កញ្ញា **ដេង ចាន់ណារី**

ណែនាំដោយ
លោកជំទាវ **ប៊ួយ ធីតា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី២៣

ឆ្នាំចូលសិក្សា ២០១៩
ឆ្នាំសរសេរសារណា ២០២៣

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ខែ៉ត សាមីត** និងឈ្មោះ **ដេង ចាន់ណារី** ជានិស្សិត ថ្នាក់បរិញ្ញាបត្រ ជំនាញនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២៣ ក្នុងឆ្នាំសិក្សា២០១៩ - ២០២៣ ដែលនឹងកំពុងតែសិក្សា នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច **សូមសម្តែងនូវការវេនកិច្ចដឹងគុណដ៏ខ្ពង់ខ្ពស់ ជាអនេកកប្បការជូនចំពោះ លោកអ្នកមានគុណ** របស់យើងខ្ញុំទាំងពីរៈ

- លោកឪពុកឈ្មោះ **ខែ៉ត មន** និងអ្នកម្តាយឈ្មោះ **រ៉េត សុផ័ន**
- លោកឪពុកឈ្មោះ **ដេង ឆន** និងអ្នកម្តាយឈ្មោះ **ឈឹម គុន្ធា**

ដោយ**លោកជាអ្នកមានគុណ**ដ៏ធំធេង ដែលបានផ្តល់កំណើត ព្រមទាំងចិញ្ចឹមបីបាច់ថែរក្សាកូនប្រកបដោយព្រហ្មវិហារធម៌ ដោយបានទំនុកបម្រុងកូន ហើយលោកថែមទាំងបានផ្តល់ទាំងកម្លាំងកាយ កម្លាំងចិត្ត អប់រំទូន្មានកូន ដោយពុះពារជំនះនូវរាល់គ្រប់ឧបសគ្គទាំងអស់ ដើម្បីឱ្យកូនបានសិក្សាតាំងពីកូននៅតូចចូលរៀនថ្នាក់មត្តេយ្យ រហូតដល់កូនធំពេញវ័យ ហើយក៏បានបន្តការសិក្សាដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រនេះផងដែរ។ មួយវិញទៀតលោកអ្នកមានគុណរបស់យើងខ្ញុំទាំងពីរ តែងតែធ្វើការប្រៀនប្រដៅដល់កូនដើម្បីឱ្យកូនក្លាយជាមនុស្សល្អ ដែលប្រកបដោយសីលធម៌ល្អ និងសុជីវធម៌ល្អ ព្រមទាំងចេះស្រឡាញ់ ចេះជួយដល់អ្នកដទៃ និងការចូលរួមសកម្មភាពសង្គមជាតិ ជាអាទិ៍ ដោយក្នុងនាមយើងជាចំណែកមួយនៃប្រទេសកម្ពុជា។ អាស្រ័យហេតុនេះ ដោយសារតែមានការយកចិត្តទុកដាក់ ការលើកទឹកចិត្ត និងការផ្តល់ភាពកក់ក្តៅរបស់លោកនេះហើយ ដែលជាកម្លាំងចលករមួយដ៏មហិមារ ទើបធ្វើឱ្យយើងខ្ញុំក្លាយជានិស្សិត ដែលបានខិតខំប្រឹងប្រែងរៀនសូត្រ រហូតបានបញ្ចប់ថ្នាក់បរិញ្ញាបត្រ ព្រមទាំងមានសមត្ថភាព រួមទាំងលទ្ធភាពក្នុងការសរសេរសារណាមួយនេះឡើងផងដែរ។

យើងខ្ញុំសូមថ្លែងអំណរគុណជូនចំពោះ **ឯកឧត្តម លុយ ចន្ណា សាកលវិទ្យាធិការ និងព្រមទាំងសាកលវិទ្យាធិការរង ព្រឹទ្ធិបុរស ព្រឹទ្ធិបុរសរង លោក លោកស្រីសាស្ត្រាចារ្យ សាស្ត្រចារ្យរង សាស្ត្រាចារ្យជំនួយ បុគ្គលិក** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ ដែលលោក លោកស្រី បានខិតខំលះបង់ទាំងកម្លាំងកាយ កម្លាំងចិត្ត ក្នុងការដឹកនាំគ្រប់គ្រង ហើយថែមទាំងបានបង្ហាត់បង្រៀន ផ្តល់នូវការអប់រំ ចំណេះដឹង ព្រមទាំងក្រមសីលធម៌ ដល់រូបយើងខ្ញុំក្នុងអំឡុងពេលសិក្សារយៈពេល ៤ (បួន) ឆ្នាំ កន្លងមកនេះ។ ជាពិសេសបានផ្តល់ទាំងបទពិសោធន៍ និងឱកាសដល់យើងខ្ញុំក្នុងការស្រាវជ្រាវ និងតាក់តែងបង្កើតស្នាដៃមួយនេះឡើង។

យើងខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ **គណៈគ្រប់គ្រងនៃបណ្ណាល័យនីតិសាស្ត្រ ដែលលោក លោកស្រី** បានរៀបចំប្រមូល និងគ្រប់គ្រងឯកសារ ព្រមទាំងសៀវភៅយ៉ាងសម្បូរបែបទាំងអស់ ដែលបានបង្កជាលក្ខណៈងាយស្រួល ដល់បងប្អូននិស្សិតគ្រប់រូបក្នុងការសិក្សាស្វែងយល់ពីការស្រាវជ្រាវ ដែលបងប្អូននិស្សិតគ្រប់រូបកំពុងតែស្វែងរកជាយូរមកហើយ ហើយយើងខ្ញុំនឹងចូលរួមជាចំណែកមួយក្នុងការរៀបចំតាក់តែងនូវសារណាមួយនេះឡើងបន្ថែម ដើម្បីផ្តល់ជាភាពងាយស្រួលសិក្សាស្វែងយល់ដល់បងប្អូននិស្សិតជំនាន់ក្រោយផងដែរ។

ជាពិសេសយើងខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ **លោកជំទាវ ម៉ួយ ធីតា** ដែលបានដឹកនាំការសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្ររបស់យើងខ្ញុំ ដោយ**លោកជំទាវ** បានផ្តល់ជាកិត្តិយស ព្រមទាំងចំណាយពេលវេលាដ៏មានតម្លៃក្នុងការដឹកនាំ និងផ្តល់នូវដំបូន្មាន ចំណេះដឹង យោបល់ល្អៗ ការលើកទឹកចិត្ត និងបទពិសោធន៍ជាច្រើន ថែមទាំងពន្យល់នូវរាល់ចម្ងល់របស់យើងខ្ញុំ ព្រមទាំងបាន កែតម្រូវនូវរាល់ចំណុចដែលយើងខ្ញុំបានខ្វះចន្លោះមួយចំនួនផងដែរ ដែលមានលក្ខណៈងាយស្រួលដល់យើងខ្ញុំទាំងពីរក្នុងការចាប់ផ្តើមសរសេរសារណានេះឡើង រហូតដល់ទទួលបានដោយជោគជ័យ។

ជាចុងក្រោយ យើងខ្ញុំសូមបន្តថ្លែងអំណរគុណដល់ប្រធានថ្នាក់ មិត្តនិស្សិត និងសិស្សច្បងទាំងអស់ ដែលបានរួមចំណែកក្នុងការជួយផ្តល់ជាយោបល់ និងគំនិតល្អៗដល់យើងខ្ញុំ ជាពិសេសបានជឿជាក់មកលើរូបយើងខ្ញុំដែលសកម្មភាពទាំងអស់នេះហើយ គឺជាចំណែកមួយយ៉ាងធំធេងបំផុត នៅក្នុងដំណើរការសរសេរសារណាមួយនេះរហូតដល់បានបញ្ចប់ជាស្ថាពរ និងប្រកបដោយលទ្ធផលជាទីគាប់ប្រសើរ។ ហើយជាកិច្ចបញ្ចប់ យើងខ្ញុំទាំងពីរ សូមបួងសួងដល់វត្ថុស័ក្តសិទ្ធិទាំងឡាយទាំងពួងលើលោកនេះ សូមឱ្យជួយតាមថែរក្សាដល់លោកអ្នកមានគុណរបស់យើងខ្ញុំ ញាតិមិត្ត ព្រមទាំងថ្នាក់ដឹកនាំសាកលវិទ្យាល័យ លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ និងសិស្សច្បងទាំងអស់ រួមទាំងមិត្តនិស្សិតគ្រប់រូប ឱ្យជួបប្រទះតែសេចក្តីសុខ សេចក្តីចម្រើនគ្រប់ពេលវេលា ព្រមទាំងជួបប្រទះនូវពុទ្ធពរទាំងឡាយបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ជាក់ស្តែងបន្ទាប់ពីយើងខ្ញុំបានឆ្លងកាត់ការសិក្សានៅថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អស់រយៈពេលជិត ៤ (បួន) ឆ្នាំ កន្លងមកនេះ ធ្វើឱ្យយើងខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំង ដែលទទួលបានឱកាសក្នុងការសរសេរសារណាបញ្ចប់ការសិក្សាក្នុងឆ្នាំនេះ។ ជាមួយគ្នានេះដែរ ចំពោះការសរសេរសារណាបញ្ចប់ការសិក្សានេះទៀតសោត យើងខ្ញុំទាំងពីរនាក់មានគោលបំណងរួមគ្នានោះគឺ ដើម្បីសិក្សាស្វែងយល់ និងអភិវឌ្ឍន៍ចំណេះដឹងបន្ថែមទៅលើចំណេះដឹងដែលមានស្រាប់ ដោយទទួលបានពីលោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ ព្រមទាំងសិស្សច្បងទាំងអស់គ្នាដែលតែងតែផ្តល់មកយើងខ្ញុំកន្លងមក។ ហើយបទពិសោធន៍ដែលយើងខ្ញុំទទួលបានកន្លងមកនេះ មានទាំងចំណេះវិជ្ជា ទាំងដំបូន្មានល្អៗរហូតដល់យើងខ្ញុំទាំងពីរសម្រេចបាននូវសារណាមួយនេះឡើងដោយជោគជ័យ។ លើសពីនេះ យើងខ្ញុំបានចងក្រងស្នាដៃមួយនេះទុកសម្រាប់ឱ្យនិស្សិតជំនាន់ក្រោយបានសិក្សាស្វែងយល់ឱ្យកាន់តែច្បាស់ និងជាមូលដ្ឋានសម្រាប់ការសិក្សាស្រាវជ្រាវបន្ថែមទៀត។ ដោយហេតុថា បើមើលតាមទិដ្ឋភាពជាក់ស្តែងនៅក្នុងសង្គមកម្ពុជាយើងនាពេលបច្ចុប្បន្ននេះ បានកើតឡើងនូវបញ្ហាជាច្រើនដែលជាប់ទាក់ទងទៅនឹងការរស់នៅមិនចុះសម្រុងនឹងគ្នាដោយចេះតែបង្កើតនូវចំណងអាពាហ៍ពិពាហ៍រួចហើយ តែងតែមានការបែកបាក់គ្នាទៅវិញ ហេតុដូច្នេះហើយទើបយើងខ្ញុំទាំងពីរនាក់សម្រេចចងក្រងនូវសារណាមួយនេះឡើង ដើម្បីជួយសម្រួលដល់ប្រជាពលរដ្ឋនៅប្រទេសកម្ពុជាមួយចំនួន ដែលមិនទាន់ស្វែងយល់ច្បាស់នូវនីតិវិធីនៃការលែងលះ។ អាស្រ័យហេតុនេះ យើងខ្ញុំក៏បានសម្រេចជ្រើសរើសនូវប្រធានបទ " **ការលែងលះរវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ នៅប្រទេសកម្ពុជា** " ដើម្បីចងក្រងធ្វើជាសារណាបញ្ចប់ការសិក្សានាឆ្នាំ២០២៣ នេះ។

យ៉ាងណាមិញ យើងខ្ញុំសង្ឃឹមថាការសិក្សាស្រាវជ្រាវ និងការចងក្រងជាសារណាមួយនេះឡើងក៏ជាចំណែកមួយជួយសម្រួលដល់ការសិក្សា និងចង់ស្វែងយល់នូវប្រធានបទមួយនេះឱ្យកាន់តែច្បាស់បន្ថែមទៀតដល់បងប្អូននិស្សិតជំនាន់ក្រោយ។ មួយវិញទៀត នៅក្នុងការចងក្រងនូវសារណាមួយនេះ យើងខ្ញុំបានរៀបរៀង និងខិតខំប្រឹងប្រែងពុះពារ ព្យាយាម ដោយតាក់តែងដើម្បីឱ្យបងប្អូននិស្សិត និងមិត្តអ្នកអាន ងាយស្រួលយល់ និងឆាប់ចាប់បានពីគោលបំណង និងបែបបទនៃសារណាមួយនេះ ព្រមទាំងអាចឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកអាន ដែលមានបំណងចង់ចេះ ចង់ដឹង សម្រាប់ជាមូលដ្ឋាននៃការស្វែងយល់នូវលិខិតបទដ្ឋានគតិយុត្តសំខាន់ៗ ដែលមានពាក់ព័ន្ធនឹងប្រធានបទមួយនេះ។ លើសពីនេះទៅទៀត យើងខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែងក្នុងការទទួលយកនូវមតិដែលបានលើកឡើងមកកាន់យើងខ្ញុំ បន្ទាប់ពីបងប្អូននិងមិត្តអ្នកអាន បានអាន និងបានសិក្សាអំពីប្រធានបទនេះ ដើម្បីជាចំណែកមួយយ៉ាងសំខាន់ក្នុងការជំរុញ

ពង្រឹងក្នុងអត្ថន័យ និងគំនិតស្ថាបនាកែលម្អឱ្យកាន់តែល្អប្រសើរបន្ថែមទៀត ទាំងអត្ថន័យ អត្ថរស ឆ្ពោះទៅរកភាពជោគជ័យនាថ្ងៃអនាគត។

# មាតិកា


ទំព័រ

**សេចក្តីផ្តើម** ........ ១

## ជំពូកទី១
## សញ្ញាណទូទៅនៃការលែងលះ

**១.១. បទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការលែងលះ**........ ៦

១.១.១. ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ........ ៧

១.១.២. ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ ........ ៨

១.១.៣. ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០ ........ ៨

១.១.៤. ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១០ ........ ៩

១.១.៥. ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ ........ ៩

១.១.៦. ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ២០១១........ ១០

១.១.៧. ច្បាប់ស្តីពីអត្រានុកូលដ្ឋានស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ឆ្នាំ២០២៣........ ១០

១.១.៨. ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ឆ្នាំ២០១៣ ........ ១១

**១.២. ទំនាក់ទំនងគតិយុត្តនៃសហព័ទ្ធ** ........ ១១

**១.៣. ប្រភេទនៃការលែងលះ** ........ ១២

១.៣.១. ការលែងលះដោយការព្រមព្រៀង ........ ១២

១.៣.២. ការលែងលះដោយគ្មានការព្រមព្រៀង........ ១២

**១.៤. មូលហេតុនៃការលែងលះ**........ ១២

១.៤.១. អំពើជិត........ ១៣

១.៤.២. ការបោះបង់សហព័ទ្ធចោលដោយគ្មានមូលហេតុត្រឹមត្រូវ........ ១៤

១.៤.៣. ការមិនបានដឹងថាស្លាប់ ឬរស់របស់សហព័ទ្ធណាម្ខាង........ ១៤

១.៤.៤. ការរស់នៅបែកបាក់គ្នារវាងសហព័ទ្ធ ........ ១៥

១.៤.៥. ករណីធ្ងន់ធ្ងរដែលមិនអាចបដិទានទំនាក់ទំនងឡើងវិញបាន ........ ១៥

# ជំពូកទី២

# ការលែងលះដោយការព្រមព្រៀង

**២.១. ទិដ្ឋភាពទូទៅនៃការលែងលះដោយការព្រមព្រៀង** ........................................ ១៦

**២.២. អាជ្ញាធរមានសមត្ថកិច្ច** ........................................ ១៧

២.២.១. ក្រុមប្រឹក្សាឃុំ-សង្កាត់ ........................................ ១៧

២.២.២. តុលាការរាជធានី-ខេត្ត ........................................ ១៨

**២.៣. នីតិវិធីដែលត្រូវបំពេញដោយភាគី** ........................................ ១៨

២.៣.១. ការស្នើសុំការលែងលះ ........................................ ១៨

២.៣.២. ពាក្យសុំលែងលះ ........................................ ១៩

២.៣.២.១. ពាក្យសុំលែងលះដោយលាយលក្ខណ៍អក្សរ ........................................ ១៩

២.៣.២.២. ពាក្យសុំលែងលះដោយផ្ទាល់មាត់ ........................................ ២០

២.៣.៣. ការដាក់ពាក្យសុំលែងលះ និងការបង់ពន្ធ ........................................ ២០

**២.៤. នីតិវិធីដោះស្រាយការលែងលះដោយការព្រមព្រៀង** ........................................ ២១

២.៤.១. ការកោះហៅគូភាគី ........................................ ២១

២.៤.២. ការផ្សះផ្សា ........................................ ២១

២.៤.៣. នីតិវិធីនៃការសាកសួរ ........................................ ២២

២.៤.៤. ការសម្រេចលើពាក្យស្នើសុំ ........................................ ២២

២.៤.៥. ការចេញដីកាសម្រេច ........................................ ២២

# ជំពូកទី៣

# ការលែងលះដោយគ្មានការព្រមព្រៀង

**៣.១. ទិដ្ឋភាពទូទៅនៃការលែងលះដោយគ្មានការព្រមព្រៀង** ........................................ ២៣

**៣.២. អាជ្ញាធរមានសមត្ថកិច្ច** ........................................ ២៤

៣.២.១. ក្រុមប្រឹក្សាឃុំ-សង្កាត់ ........................................ ២៤

៣.២.២. តុលាការរាជធានី-ខេត្ត ........................................................................ ២៤
**៣.៣. នីតិវិធីដែលត្រូវបំពេញដោយភាគី** ............................................................. ២៥
៣.៣.១. ការធ្វើបណ្តឹងលែងលះ ........................................................................ ២៥
៣.៣.១.១. និយមន័យនៃបណ្តឹង ........................................................................ ២៥
៣.៣.១.២. ការសរសេរពាក្យបណ្តឹង ........................................................................ ២៦
៣.៣.១.៣. ការដាក់ពាក្យបណ្តឹង និងការបង់ពន្ធ ........................................................ ២៧
៣.៣.២. ឯកសារភ្ជាប់ និងភស្តុតាង ........................................................................ ២៧
**៣.៤. នីតិវិធីជំនុំជម្រះលើបណ្តឹងលែងលះ** ............................................................. ២៨
៣.៤.១. ការពិនិត្យលើបណ្តឹងទាមទារការលែងលះ ........................................................ ២៨
៣.៤.១.១. ការទទួលយកបណ្តឹង ........................................................................ ២៨
៣.៤.១.២. ការលើកចោលពាក្យបណ្តឹង ........................................................................ ២៩
៣.៤.១.៣. ការបន្ថែម ឬផ្លាស់ប្តូរកម្មវត្ថុនៃបណ្តឹង ........................................................ ២៩
៣.៤.១.៤. ការដាក់បណ្តឹងតបរបស់ភាគីចុងចម្លើយ ........................................................ ២៩
៣.៤.២. ការកោះហៅគូភាគី និងការបញ្ជូនពាក្យបណ្តឹង ........................................................ ៣០
៣.៤.៣. ការផ្សះផ្សា ........................................................................ ៣០
៣.៤.៤. ការចាត់ចែងរក្សាការពារបណ្តោះអាសន្ន ........................................................ ៣១
៣.៤.៤.១. ការកំណត់អំពីការរស់នៅរបស់សហព័ទ្ធ ........................................................ ៣១
៣.៤.៤.២. ការថែរក្សាកូនជាបណ្តោះអាសន្ន ........................................................ ៣២
៣.៤.៤.៣. ការថែរក្សាទ្រព្យសម្បត្តិជាបណ្តោះអាសន្ន ........................................................ ៣២
៣.៤.៤.៤. ការផ្គត់ផ្គង់សហព័ទ្ធ ឬផ្គត់ផ្គង់កូន ........................................................ ៣២
៣.៤.៥. នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ........................................................ ៣៣
៣.៤.៦. នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ........................................................ ៣៤
៣.៤.៧. សេចក្តីសម្រេច ........................................................................ ៣៦
៣.៤.៧.១. ការចេញសាលក្រមលើបណ្តឹងលែងលះ ........................................................ ៣៦

៣.៤.៧.២. ការសម្រេចមិនឱ្យមានការលែងលះ ........ ៣៧
៣.៤.៧.៣. ការចូលជាស្ថាពរនៃសាលក្រម ........ ៣៧

# ជំពូកទី៤

# អានុភាពនៃការលែងលះ

**៤.១. ការកាត់ផ្តាច់ទំនាក់ទំនងគតិយុត្ត** ........ ៣៨
៤.១.១. ការកាត់ផ្តាច់ទំនាក់ទំនងគតិយុត្តរវាងសហព័ទ្ធ ........ ៣៨
៤.១.១.១. ស្ថានភាពគ្រួសារ (ពោះម៉ាយ ឬ មេម៉ាយ) ........ ៣៩
៤.១.១.២. ការបញ្ចប់នូវការរួមរស់ជីវភាពជាមួយគ្នា សហការ និងសង្គ្រោះគ្នាទៅវិញទៅមក. ៣៩
៤.១.១.៣. នាមត្រកូលអាចត្រូវបានបញ្ចប់ ........ ៣៩
៤.១.១.៤. ការបញ្ចប់ភាពជាសន្តតិជនជានិច្ច ........ ៤០
៤.១.១.៥. អត្តាធីនភាពនៅតែកើតមាន ........ ៤០
៤.១.១.៦. កាតព្វកិច្ចសងសំណងជម្ងឺចិត្តអាចកើតមាន ........ ៤០
៤.១.២. ការកាត់ផ្តាច់ទំនាក់ទំនងរវាងញាតិពន្ធ ........ ៤០
**៤.២. ការបែងចែកទ្រព្យសម្បត្តិ** ........ ៤១
៤.២.១. ទ្រព្យសម្បត្តិអកម្ម ........ ៤១
៤.២.២. ទ្រព្យសម្បត្តិសកម្ម ........ ៤១
៤.២.២.១. ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា ........ ៤២
៤.២.២.២. ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ ........ ៤២
ក. ទ្រព្យសម្បត្តិរួម ........ ៤២
ខ. ទ្រព្យសម្បត្តិដោយឡែក ........ ៤៣
**៤.៣. ការប្រគល់អំណាចមេបា** ........ ៤៣
**៤.៤. ការផ្តល់អាហារកាតព្វកិច្ច** ........ ៤៤
៤.៤.១. អាហារកាតព្វកិច្ចចំពោះកូន ........ ៤៤
៤.៤.២. អាហារកាតព្វកិច្ចចំពោះសហព័ទ្ធ ........ ៤៤

**៤.៥. ការចុះបញ្ជីអំពីការលៃខលះ** ........................................................ ៤៥
**សេចក្ដីសន្និដ្ឋាន** ........................................................ ៤៦
**អនុសាសន៍** ........................................................ ៤៨
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

នៅក្នុងសង្គមនាពេលបច្ចុប្បន្ននេះ ហេតុដែលនាំឱ្យកើតមាននូវអាពាហ៍ពិពាហ៍រវាងមនុស្សពីរនាក់បាន លុះត្រាតែអ្នកទាំងពីរបានបង្កើតឱ្យមាននូវស្នេហារវាងគ្នានឹងគ្នាជាមុនសិន ហើយបើតាមច្បាប់ធម្មជាតិ បណ្តាលឱ្យមានរូបភាព និងមានមនោសញ្ចេតនានឹងគ្នាទៅវិញទៅមករបស់មនុស្សពីរនាក់ ដែលវាជាស្នេហាដោយផ្តោតទៅលើបុរស និងស្ត្រី ដែលបានបង្ហាញក្តីស្រឡាញ់មកឱ្យគ្នា និងមានគោលបំណងចង់បង្កើតទំនាក់ទំនងមួយនេះឡើង ដោយការរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ដើម្បីកសាងគ្រួសារយ៉ាងមានសុភមង្គលជាមួយគ្នាតរៀងទៅ។ ជាមួយគ្នានេះដែរ ការរៀបអាពាហ៍ពិពាហ៍ រហូតបង្កើតបានជាគ្រួសារមួយជាមួយគ្នានេះដែរ ចំពោះពាក្យថា គ្រួសារ គឺជាការរស់នៅរបស់មនុស្សពីរនាក់ ឬមួយក្រុម ក្នុងន័យស្រឡាញ់គ្នា ដោយទទួលបន្ទុកមើលថែរក្សាការពារគ្នាពុះពាររាល់គ្រប់ឧបសគ្គជាមួយគ្នា មិនដោះដៃចោលគ្នាទោះបីជាស្ថិតក្នុងស្ថានភាពណាមួយក៏ដោយ។ ហេតុនេះដើម្បីបង្កើតបានជាគ្រួសារមួយ បុរស និងស្ត្រី ត្រូវតែឆ្លងកាត់ការរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាជាមុនសិន ដោយគោរពទៅតាមលក្ខខណ្ឌគតិយុត្ត និងស្របតាមប្រពៃណីឱ្យបានត្រឹមត្រូវ។ ជាមួយគ្នានេះដែរ បន្ទាប់ពីបានរៀបអាពាហ៍ពិពាហ៍ស្របតាមលក្ខខណ្ឌគតិយុត្តហើយនោះ បុរស និងស្ត្រី ត្រូវទៅចុះសំបុត្រអាពាហ៍ពិពាហ៍ (អេតាស៊ីវិល) ទើបបុរស និងស្ត្រី អាចក្លាយជាប្តីប្រពន្ធស្របតាមច្បាប់បាន។

ជាការពិតណាស់ការមានជីវិតគូដែលកក់ក្តៅនៅក្នុងគ្រួសារមួយដ៏ល្អ តែងតែចង់បង្កើតឡើងនូវរឿងល្អៗជាច្រើនបន្ថែមទៀតជាមួយគ្នា គឺការរស់នៅជាមួយគ្នារហូតចង់កសាងគ្រួសារមួយដែលពេញលេញបរិបូរណ៍ ដោយការបង្កើតនូវទ្រព្យសម្បត្តិ មានកូនមានចៅ បែបបទនៃការចិញ្ចឹមបីបាច់ថែរក្សាកូន និងការទទួលខុសត្រូវពេញលេញក្នុងនាមជាឪពុកម្តាយ ចំពោះកូនចៅទៅថ្ងៃមុខបន្តទៀត។ ដូចនេះគ្រួសារគឺការរស់នៅជាមួយគ្នាយ៉ាងមានសេចក្តីសុខព្រោះ មានគោលដៅតែមួយ គឺស្រឡាញ់គ្នាដោយចិត្តស្មោះឱ្យតម្លៃចំពោះគ្នាទៅវិញទៅមក ចាប់ដៃគ្នារកស៊ីធ្វើការដើម្បីជីវភាពមួយដ៏សមរម្យ និងថ្លៃថ្នូរ ហើយអ្វីដែលកាន់តែវិសេសវិសាលគឺ មានគ្រួសារទាំងសងខាងគាំទ្រ និងលើកទឹកចិត្តយ៉ាងពេញទំហឹង។ ជាក់ស្តែង នៅពេលដែលបង្កើតបានគ្រួសារដែលមានភាពកក់ក្តៅ និងមានសេចក្តីសុខនឹងគ្នាហើយនោះ តែងតែរករឿងឈ្លោះប្រកែកគ្នាឱ្យទាល់តែបាន ហើយគ្រួសារមួយចំនួន ដែលមានបញ្ហានឹងគ្នា នោះមិនមែនមកពីភាគីខាងប្តីតែម្ខាង ឬខាងប្រពន្ធតែម្ខាងនោះទេ ពេលខ្លះអាចមកពីចិត្តខ្លាំងចង់ឈ្នះរៀងខ្លួន។ ក្នុងករណីនេះ បើរស់នៅមិនយល់ចិត្តគ្នា រស់នៅមិនចុះសម្រុងនឹងគ្នា មិនចេះអត់ឱនអធ្យាស្រ័យគ្នានោះ ច្បាស់ហើយថារស់នៅជាមួយគ្នាបន្តទៅថ្ងៃមុខទៀតនោះប្រាកដណាស់ថាមិនសុខសាន្តនោះឡើយ បើនៅតែមិនចេះអត់ឱនអធ្យាស្រ័យឱ្យគ្នាបែបនេះ។ មួយវិញទៀតជីវិតជាប្តីប្រពន្ធនឹងគ្នា ពេលខ្លះមិនមែនរស់នៅជាមួយគ្នាហើយមិនដែលឈ្លោះប្រកែកគ្នានោះទេ ខ្លះមានរឿងរកាំរកូសនឹងគ្នា ខ្លះទៀតមានការអាក់អន់ស្រពន់ចិត្តនឹងគ្នានូវរឿងបន្តិចបន្តួច ដែលជាហេតុធ្វើឱ្យរស់នៅជាមួយគ្នា មិនចុះ

សម្រុងនឹងគ្នា និងគ្មានសុភមង្គល រហូតឈានដល់ការបែកបាក់គ្នា។ ហេតុនេះពេលរស់នៅមិនចុះសម្រុងនឹងគ្នាហើយនោះ ដែលជាហេតុនាំឱ្យមានការលែងលះកើតឡើងមកក្នុងគ្រួសារមិនខាន។

ស្របជាមួយគ្នាដែរ យើងអាចឱ្យនិយមន័យលើពាក្យ អាពាហ៍ពិពាហ៍បានថា ជាកិច្ចសន្យាដ៏ឱឡារិកមួយធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ដែលប្តេជ្ញាថា ខ្លួន នឹងរួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួនបានឡើយ។[1] ការមិនអាចរំលាយតាមទំនើងចិត្ត ពីព្រោះតែបន្ទាប់ពីការរៀបអាពាហ៍ពិពាហ៍ ជាប្តី និងប្រពន្ធ ហើយមានចំណងគតិយុត្តជាច្រើនកើតឡើងរវាងគ្នានឹងគ្នាតាមបែបលក្ខណៈជាទំនាក់ទំនងនៃឋានៈបុគ្គល និងទំនាក់ទំនងទ្រព្យសម្បត្តិ។ ប៉ុន្តែទោះជាបែបនេះ មិនមានច្បាប់ណាចែងថា តម្រូវឱ្យបុគ្គលត្រូវតែស្ថិតនៅក្នុងចំណងអាពាហ៍ពិពាហ៍ជាមួយគ្នាអស់មួយជីវិតនោះឡើយ មានន័យថាប្រសិនបើប្តី និងប្រពន្ធទាំងពីរនាក់មានវិវាទនឹងគ្នានៅក្នុងគ្រួសារ ហើយគ្មានសង្ឃឹមថានឹងអាចកែប្រែស្ថានភាពឱ្យរស់នៅចុះសម្រុងនឹងគ្នាឡើងវិញនោះទេ ឬភាគីទាំងពីរអស់មនោសញ្ចេតនា នឹងការរស់នៅជាមួយគ្នាជាប្តីប្រពន្ធហើយនោះ អ្នកទាំងពីរអាចរំលាយចំណងអាពាហ៍ពិពាហ៍របស់ខ្លួនតាមផ្លូវតុលាការ ដោយអាចធ្វើឡើងក្រោមរូបភាពពីរយ៉ាងគឺ ការលែងលះដោយគ្មានការព្រមព្រៀង និងការលែងលះដោយការព្រមព្រៀងរបស់ប្តីប្រពន្ធទាំងពីរ។ ការលែងលះដោយគ្មានការព្រមព្រៀង គឺដាច់ខាតភាគីនោះត្រូវមានហេតុផលដែលមានកំណត់នៅក្នុងច្បាប់ដែលជាប់ពាក់ព័ន្ធនឹងកំហុសរបស់សហព័ទ្ធ[2] ហើយនីតិវិធីនៃការលែងលះ ត្រូវដោះស្រាយដោយអនុលោមទៅតាមច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលផងដែរ។[3] ចំណែកឯការលែងលះដោយការព្រមព្រៀង ភាពចាំបាច់នៃមូលហេតុមិនត្រូវបានតម្រូវនោះទេ ពោលគឺឱ្យតែប្តី និងប្រពន្ធបង្ហាញពីឆន្ទៈយ៉ាងច្បាស់ និងកើតឡើងពីការស្ម័គ្រចិត្តរៀងខ្លួនថានឹងលែងលះជាមួយគ្នាហើយនោះ គឺអ្នកទាំងពីរអាចដាក់ពាក្យសុំទៅតុលាការបាន[4] ហើយដំណើរការនីតិវិធីដោះស្រាយត្រូវអនុវត្តទៅតាមច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។[5]

អាស្រ័យហេតុនេះតាមការបកស្រាយខាងលើ បានឆ្លុះបញ្ចាំងឱ្យឃើញថា ការរស់នៅជាមួយគ្នានៅអំឡុងពេលជាប្តីប្រពន្ធនឹងគ្នា គឺរមែងតែងតែជួបនូវបញ្ហាដែលតាមមកជាប់ជានិច្ច តិចក្តីច្រើនក្តីជាក់ស្តែងទៅតាមគ្រួសារនីមួយៗ។ ហើយពេលខ្លះក៏មានគ្រួសារមួយចំនួនដែលមានបញ្ហាបន្តិចបន្តួច ក៏ជារឿងមួយដែលងាយស្រួលក្នុងការដោះស្រាយជាមួយគ្នា ដោយមិនមានការប្តឹងផ្តល់ឱ្យក្លាយជារឿងធំ ដែលជាហេតុបណ្តាលឱ្យ

[1] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩, មាត្រា៣។

[2] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧៨។

[3] ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/០៦១០/០០៨, ០៨ មិថុនា ២០១០, មាត្រា៣ (គ)។

[4] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧៩។

[5] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០, មាត្រា៣។

មានបញ្ហាកើតឡើងរហូតដល់មានការឈ្លោះប្រកែកគ្នា និងមានការប្រើប្រាស់អំពើហិង្សាផងដែរ។ លើសពីនេះ នីតិវិធីនៃការលែងលះរបស់ប្ដី និងប្រពន្ធ មិនមែនចេះតែដោះស្រាយ ដោយមិនប្រើច្បាប់នោះទេ គឺត្រូវតែមានប្រើប្រាស់នូវប្រព័ន្ធច្បាប់ជាមូលដ្ឋាន ដោយហេតុថាការលែងលះរវាងភាគីខាងប្ដី ឬខាងប្រពន្ធជាភាគីខាងណាអ្នកសុំលែងលះក៏ដោយ វាជាបញ្ហាដែលស្មុគស្មាញដូចគ្នា ហើយវាជាបញ្ហាដែលពិបាកជាងការបង្កើតឱ្យមានអាពាហ៍ពិពាហ៍ទៅទៀត។ ជាក់ស្ដែងបើយើងក្រឡេកមកមើលប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះវិញ ការលែងលះ ក៏ជាបញ្ហាចោទមួយនៅក្នុងសង្គមកម្ពុជាផងដែរ។ ដូចនេះហើយទើបយើងខ្ញុំសម្រេចចិត្តក្នុងការសិក្សា និងស្វែងរកនូវចំណុចដែលងាយយល់ និងនីតិវិធីនៃការដោះស្រាយនូវបញ្ហាទាំងឡាយណាដែលបងប្អូននិស្សិតជំនាន់ក្រោយនៅមានចម្ងល់ដែលពាក់ព័ន្ធទៅនឹងប្រធានបទមួយនេះ។ ហើយក្នុងនាមយើងខ្ញុំទាំងពីរនាក់ជានិស្សិតដែលកំពុងសិក្សាលើវិស័យច្បាប់ដោយផ្ទាល់នោះ ស្របពេលដែលសង្គមកំពុងជួបបញ្ហាចោទ ដូចនេះយើងខ្ញុំក៏ចង់ចេះ ចង់ដឹង និងស្វែងយល់ឱ្យកាន់តែច្បាស់លើប្រធានបទមួយនេះ ហើយយើងខ្ញុំសង្ឃឹមថានៅពេលដែលបងប្អូននិស្សិតជំនាន់ក្រោយបានអាន និងបានសិក្សាលើប្រធានបទមួយនេះហើយបងប្អូននឹងពេញចិត្តផងដែរ។ ភ្ជាប់ជាមួយគ្នានេះដែរ យើងខ្ញុំសង្ឃឹមថាវាក៏ជាផ្នែកមួយដែលទៅជួយដោះស្រាយនូវចំណុចណាមួយដែលបងប្អូនទាំងអស់គ្នាមានមន្ទិលសង្ស័យតាំងពីយូរ ឬក៏ថ្មីៗនេះផងដែរ។

ដោយហេតុថាសព្វថ្ងៃនេះ នៅក្នុងប្រទេសកម្ពុជាយើងបច្ចុប្បន្នការលែងលះគឺមានច្រើនណាស់ ហើយចំពោះការដោះស្រាយដែលពាក់ព័ន្ធនឹងបញ្ហានេះក៏នូវមានអ្នកវិជ្ជាជីវៈច្បាប់មួយចំនួនដែលបានសិក្សារៀនសូត្រ និងបំពេញការងារក្នុងវិស័យច្បាប់មួយនេះ តែងតែមានបទពិសោធន៍ និងមានចំណេះដឹងជាច្រើនអំពីបញ្ហាមួយនេះ។ ប៉ុន្តែជាក់ស្ដែងនៅមានប្រជាពលរដ្ឋមួយចំនួន ដែលរស់នៅតំបន់ដែលដាច់ស្រយាលគាត់អាចនឹងមិនទាន់យល់ច្បាស់អំពីការលែងលះនេះថាមាននីតិវិធី និងទម្រង់បែបបទនៃការដោះស្រាយយ៉ាងណាខ្លះនោះទេ ហើយពេលខ្លះពួកគាត់នៅតែមានមន្ទិលសង្ស័យជាប់នៅក្នុងចិត្តគាត់ជានិច្ច អំពីបែបបទនៃកាលែងលះនេះថាមានលក្ខណៈបែបណាវិញ។ លើសពីនេះ ការលែងលះរវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរនៅប្រទេសកម្ពុជា តែងតែមាននូវចំណុចដែលជាប់ពាក់ព័ន្ធជាច្រើនចំណុចមកតាមរួមមាន ទាំងការបែងចែកទ្រព្យសម្បត្តិ, ការប្រគល់អំណាចមេបា, ការផ្ដល់អាហារកាតព្វកិច្ច និងការចុះបញ្ជីអំពីការលែងលះផងដែរ។ ហេតុដូច្នេះហើយទើបមានការលើកឡើងនូវចម្ងល់ជាច្រើនដែលពាក់ព័ន្ធនឹងការលែងលះរវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរនៅប្រទេសកម្ពុជា ដែលមានដូចជា៖

- តើមានមូលហេតុចម្បងយ៉ាងណាខ្លះដែលបណ្ដាលឱ្យកើតមាននូវការលែងលះ?
- តើការលែងលះរវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរនៅប្រទេសកម្ពុជា មានបែបបទយ៉ាងដូចម្ដេចខ្លះ?
- ហើយបើក្នុងករណីភាគីម្ខាងចង់លែងលះ តែភាគីម្ខាងទៀតមិនព្រមលែងលះ តើត្រូវមានដំណោះស្រាយយ៉ាងណាចំពោះចំណុចនេះ?

- តើការបែងចែកទ្រព្យសម្បត្តិ, ការប្រគល់អំណាចមេបា និងការផ្តល់អាហារកាតព្វកិច្ចផ្សេងៗទៀតនៅក្នុងនីតិវិធីនៃការលែងលះមានលក្ខណៈយ៉ាងដូចម្តេច?

ជាក់ស្តែងយើងខ្ញុំសង្កេតឃើញថា ការលែងលះរវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ មានលក្ខណៈស្មុគស្មាញយ៉ាងខ្លាំង ដែលជាហេតុធ្វើឱ្យយើងខ្ញុំមានចំណាប់អារម្មណ៍ចង់ធ្វើការចងក្រងជាសៀវភៅមួយនេះដើម្បីទុកជាស្នាដៃ និងបានបញ្ចេញនូវចំណេះដឹង និងបទពិសោធន៍ដែលទទួលបានពីលោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ រួមទាំងសិស្សច្បងផងដែរដែលបានផ្តល់ដំបូន្មាន និងចំណេះដឹងដល់យើងខ្ញុំដែលធ្វើឱ្យយើងខ្ញុំអាចមានឱកាសក្នុងការស្រាវជ្រាវឱ្យកាន់តែស៊ីជម្រៅ និងកាន់តែច្បាស់លាស់បន្ថែមទៀតទៅលើបញ្ហា ក៏ដូចជាចំណុចដែលជាប់ពាក់ព័ន្ធនឹងការលែងលះនៅប្រទេសកម្ពុជា។

គោលបំណងទាំងនោះរួមមានដូចខាងក្រោម៖

- ដើម្បីស្វែងយល់ពីបទដ្ឋានគតិយុត្តទាំងឡាយណាដែលជាប់ពាក់ព័ន្ធនឹងការលែងលះ
- ដម្បីស្វែងយល់ពីទំនាក់ទំនងគតិយុត្តនៃសហព័ទ្ធ
- ដើម្បីស្វែងយល់ពីប្រភេទ នៃការលែងលះនៅប្រទេសកម្ពុជា
- ដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់អំពីមូលហេតុនៃការលែងលះ
- ដើម្បីស្វែងយល់ពីនីតិវិធីនៃការដោះស្រាយការលែងលះដោយការព្រមព្រៀង
- ដើម្បីស្វែងយល់ពីនីតិវិធីនៃការដោះស្រាយការលែងលះដោយគ្មានការព្រមព្រៀង
- ដើម្បីស្វែងយល់ពីអានុភាពនៃការលែងលះរវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរនៅប្រទេសកម្ពុជា
- ដើម្បីស្វែងយល់ពីការអនុវត្តជាក់ស្តែង និងទ្រឹស្តីច្បាប់នានាដែលជាប់ពាក់ព័ន្ធនឹងការលែងលះ
- ដើម្បីស្វែងយល់ពីដំណើរការនីតិវិធីនៃការលែងលះរវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរនៅប្រទេសកម្ពុជា
- ដើម្បីស្វែងយល់ពីនីតិវិធីនៃការបែងចែកទ្រព្យសម្បត្តិ, ការប្រគល់អំណាចមេបា និងការផ្តល់អាហារកាតព្វកិច្ច និងនីតិវិធីអំពីការចុះបញ្ជីអំពីការលែងលះផងដែរ។
- ដើម្បីធ្វើការសន្និដ្ឋាន និងផ្តល់អនុសាសន៍ក្នុងការចូលរួមឱ្យមានវឌ្ឍនភាពនៃការអនុវត្តច្បាប់ និងអាចទៅបន្ថែមនៅចំណុចទាំងឡាយណាដែលនៅខ្វះចន្លោះផងដែរ។ លើសពីនេះដើម្បីចងក្រងទុកជាស្នាដៃមួយដែលជួយសម្រួលដល់បងប្អូននិស្សិតជំនាន់ក្រោយៗទៀតយកទៅសិក្សា។

ភ្ជាប់ជាមួយគ្នានេះដែរ នៅក្នុងខ្លឹមសារនៃការបកស្រាយលើប្រធានបទមួយនេះ គឺមានទំហំត្រឹមតែបកស្រាយទៅលើបទដ្ឋានគតិយុត្តដែលជាប់ពាក់ព័ន្ធនឹងការលែងលះ, អំពីទំនាក់ទំនងគតិយុត្ត, អំពីប្រភេទនៃការលែងលះ, អំពីមូលហេតុនៃការលែងលះ, នីតិវិធីនៃដំណើរការលែងលះ, អំពីនីតិវិធីនៃការបែងចែកទ្រព្យសម្បត្តិ, ការប្រគល់អំណាចមេបា និងការផ្តល់អាហារកាតព្វកិច្ចផ្សេងៗទៀត ដែលជាប់ពាក់ព័ន្ធត្រឹមតែ

ការលែងលះរវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរនៅប្រទេសកម្ពុជាតែប៉ុណ្ណោះ។ ទន្ទឹមនឹងនេះផងដែរការលែងលះនៅលើទឹកដីប្រទេសកម្ពុជាមានពីរករណី គឺការលែងលះរវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ និងការលែងលះរវាងពលរដ្ឋខ្មែរ និងជនបរទេស។ ហេតុនេះយើងខ្ញុំសូមបញ្ជាក់យ៉ាងច្បាស់ៗថា ការបកស្រាយយ៉ាងលម្អិត និងសំខាន់គឺផ្តោតទៅលើតែការលែងលះរវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរនៅប្រទេសកម្ពុជានោះទេ។

ហេតុនេះយើងខ្ញុំសង្ឃឹមថាការសិក្សាស្រាវជ្រាវលើប្រធានបទមួយនេះ និងមានសារៈប្រយោជន៍ គឺអាចដោះស្រាយនូវចម្ងល់ដែលបងប្អូននិស្សិតជំនាន់ក្រោយ ឬអ្នកអានទាំងអស់បានយ៉ាងពិតប្រាកដ។ ហើយអាចជាសៀវភៅដែលសំខាន់សម្រាប់អ្នកដែលបានអានទាំងឡាយ ដើម្បីបានយល់ដឹងកាន់តែស៊ីជម្រៅអំពីនីតិវិធីនៅក្នុងការលែងលះ និងចំណុចផ្សេងៗដែលបន្សល់ទុកបន្ទាប់ពីការលែងលះត្រូវបានបញ្ចប់។

លើសពីនេះចំពោះកម្រងវិធីដោះស្រាយនៃការស្រាវជ្រាវនេះ គឺបានពីការណែនាំពីសំណាក់ លោកជំទាវដែលដឹកនាំសារណា, លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ, សុំមតិយោបល់ពីបងៗមេធាវី សិស្សច្បង និងមិត្តរួមជំនាន់។

ចំពោះលិខិតបទដ្ឋានគតិយុត្តដែលជាប់ពាក់ព័ន្ធនៃការលែងលះមានដូចជា៖ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០, ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១០, ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩, ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ២០១០, ច្បាប់ស្តីពីអត្រានុកូលដ្ឋានស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ឆ្នាំ២០២៣ និងប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ឆ្នាំ២០១៣។

ដូច្នេះដើម្បីជាជំនួយក្នុងការសិក្សាទៅលើប្រធានបទ " **ការលែងលះរវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ នៅប្រទេសកម្ពុជា** " មានភាពងាយស្រួលនៅក្នុងការសិក្សា អំពីដំណាក់កាល និងនីតិវិធីនៃការលែងលះត្រង់ចំណុចនីមួយៗ ដោយសារណានេះយើងខ្ញុំបានបែងចែកជា ០៤ (បួន) ជំពូកធំៗគឺមានដូចខាងក្រោម៖

**ជំពូកទី១៖ សញ្ញាណទូទៅនៃការលែងលះ** ដោយបកស្រាយទៅលើបទដ្ឋានគតិយុត្តដែលជាប់ពាក់ព័ន្ធ ព្រមទាំងមូលហេតុនៃការលែងលះនៅប្រទេសកម្ពុជា។

**ជំពូកទី២៖ ការលែងលះដោយការព្រមព្រៀង** ដោយបកស្រាយអំពីនីតិវិធីក្នុងការដោះស្រាយរឿងក្តីលែងលះ ក្នុងករណីដែលភាគីបានព្រមព្រៀងគ្នាបញ្ចប់ទំនាក់ទំនងអាពាហ៍ពិពាហ៍ដោយសន្តិវិធី។

**ជំពូកទី៣៖ ការលែងលះដោយគ្មានការព្រមព្រៀង** ដោយបកស្រាយអំពីនីតិវិធីក្នុងការដោះស្រាយរឿងក្តីលែងលះមានលក្ខណៈជាបណ្តឹង។

**ជំពូកទី៤៖ អានុភាពនៃការលែងលះ** ដោយបានបកស្រាយអំពីអានុភាពដែលបន្សល់ទុកក្រោយពីការលែងលះ ព្រមទាំងការចុះបញ្ជីការលែងលះផងដែរ។

# ជំពូកទី១

# សញ្ញាណទូទៅនៃការលែងលះ

# ជំពូកទី១

# សញ្ញាណទូទៅនៃការលែងលះ

ជាទូទៅការរៀបអាពាហ៍ពិពាហ៍ គឺពិតជារឿងមួយដែលសំខាន់ណាស់សម្រាប់បុរស និងស្ត្រី ដែលបានសម្រេចចិត្តរួមគ្នាក្នុងការបង្កើតនូវចំណងអាពាហ៍ពិពាហ៍មួយនេះឡើង។ ក្នុងករណីនេះ យើងអាចឱ្យនិយមន័យនៃពាក្យថា អាពាហ៍ពិពាហ៍ បានថា គឺជាកិច្ចសន្យាដ៏ឱឡារិកមួយ ធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ ដែលប្ដេជ្ញាថា ខ្លួន នឹងរួមមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួនឡើយ។[6] ដោយហេតុថា កិច្ចសន្យានេះជាកិច្ចសន្យាដ៏ឱឡារិក ហេតុនេះអាពាហ៍ពិពាហ៍នឹងមានអានុភាពពេញលក្ខណៈច្បាប់បាន លុះត្រាតែអាពាហ៍ពិពាហ៍នោះធ្វើឡើងស្របតាមក្បួនខ្នាតដែលមានចែងក្នុងច្បាប់ជាធរមាន។ គួរបញ្ជាក់ផងដែរថា បុរស និងនារី មានសេរីភាពពេញលេញ ក្នុងការជ្រើសរើសគូស្រករក្នុងគោលដៅកសាងគ្រួសារ ដោយរួមរស់នៅជាមួយគ្នា រួមសុខរួមទុក្ខជាមួយគ្នាទៅថ្ងៃមុខ និងឈានដល់បង្កើតឱ្យមានចំណងគតិយុត្តរវាងគ្នា និងគ្នារហូតដល់មានបុត្រ, មានទ្រព្យសម្បត្តិរួមគ្នា ព្រមទាំងមានសិទ្ធិ និងកាតព្វកិច្ចផ្សេងទៀតជាមួយគ្នាផងដែរ។ ប៉ុន្តែអាពាហ៍ពិពាហ៍ ដែលត្រូវបានទទួលស្គាល់ដោយច្បាប់ គឺទាមទារឱ្យភាគីដែលមានឆន្ទៈចង់បញ្ចប់នូវចំណងអាពាហ៍ពិពាហ៍របស់ភាគីទាំងពីរបាន។ ប៉ុន្តែចំណងអាពាហ៍ពិពាហ៍មួយចំនួនបែរជាជួបរឿងល្អក់កករចំពោះគ្នា ដោយសារការរស់នៅមិនចុះសម្រុងគ្នា មិនទុកចិត្តគ្នា តែងតែមានការខ្វែងគំនិតគ្នា បង្កើតឱ្យមានអំពើហិង្សា ការជេរប្រមាថគ្នាជាអាទិ៍ ដែលជាហេតុឈានទៅរកការបែកផ្លូវគ្នាតាមរយៈការលែងលះ។ ហេតុដូច្នេះ នៅក្នុងជំពូកទី១ ដែលបានបកស្រាយអំពី សញ្ញាណទូទៅនៃការលែងលះនេះ ក៏មានលិខិតបទដ្ឋានគតិយុត្តមួយចំនួនដែលយើងខ្ញុំនឹងលើកយកមកបកស្រាយលម្អិតនៅចំណុចបន្ទាប់គឺរួមមាន៖ (១.១.) បទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការលែងលះ, (១.២.)ទំនាក់ទំនងគតិយុត្តនៃសហព័ទ្ធ, (១.៣.) ប្រភេទនៃការលែងលះ និង(១.៤.) មូលហេតុនៃការលែងលះ ។

## ១.១. បទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការលែងលះ

ជាក់ស្តែងបើយើងក្រឡេកមកមើលប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ ដោយមានការកើនឡើងជាលំដាប់នូវការបង្កើតឱ្យមាននូវចំណងអាពាហ៍ពិពាហ៍រវាងបុរស និងស្ត្រី ហើយក៏មានច្រើនដូចគ្នានូវការកើតមានឡើងនូវការលែងលះរវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរនៅក្នុងប្រទេសកម្ពុជាផ្ទាល់ ដោយសារតែការរស់នៅមិនចុះសម្រុងនឹងគ្នាទើបឈានដល់មានការលែងលះបែបនេះ ហេតុនេះហើយទើបមានបទដ្ឋានគតិយុត្តមួយចំនួនជាប់ពាក់ព័ន្ធនឹងការលែងលះរវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរផងដែរ។ គួរបញ្ជាក់ផងដែរថា ការលែងលះ

[6] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩, មាត្រា៣។

ដែលអនុលោមទៅនឹងបទដ្ឋានគតិយុត្ត អាចធ្វើបានតែទៅលើចំណងអាពាហ៍ពិពាហ៍ដែលត្រូវបានធ្វើអនុលោមតាមក្បួនច្បាប់តែប៉ុណ្ណោះ ហើយដើម្បីឱ្យភាគីអាចស្នើសុំលែងលះបានលុះត្រាតែ មានមូលហេតុដែលអាចនាំឱ្យមានការលែងលះបាន។ អាស្រ័យហេតុនេះ យើងខ្ញុំក៏បានលើកយកបទដ្ឋានគតិយុត្តចំនួន ០៨ (ប្រាំបី) ដែលជាប់ពាក់ព័ន្ធនឹងការដោះស្រាយការលែងលះនៅកម្ពុជានេះផងដែរ ដែលលិខិតបទដ្ឋានទាំងនោះរួមមាន៖ (១.១.១.) ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, (១.១.២.) ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, (១.១.៣.) ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ២០១០, (១.១.៤.) ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១០, (១.១.៥.) ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ១៩៨៩, (១.១.៦.) ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ២០១១, (១.១.៧.) ច្បាប់ស្តីពីអត្រានុកូលដ្ឋានស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ឆ្នាំ២០២៣, (១.១.៨.) ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ឆ្នាំ២០១៣ ។

### ១.១.១. ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានព្រះមហាក្សត្រឡាយព្រហស្តលេខា និងប្រកាសឱ្យប្រើនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។ ក្រមនេះ បានបញ្ញត្តិអំពីគោលការណ៍ទូទៅដែលទាក់ទងទៅនឹងទំនាក់ទំនងគតិយុត្តផ្នែករដ្ឋប្បវេណី។ បញ្ញត្តិនៃក្រមរដ្ឋប្បវេណីនេះ ត្រូវយកមកអនុវត្តចំពោះទំនាក់ទំនងទ្រព្យសម្បត្តិ និងទំនាក់ទំនងញាតិ លើកលែងតែមានកំណត់ផ្សេងនៅក្នុងច្បាប់ពិសេស។[7] ហើយក្រមរដ្ឋប្បវេណី ក៏បានកំណត់អំពីគោលការណ៍នៃការធានាសេចក្តីថ្លៃថ្នូររបស់បុគ្គល ភាពស្មើគ្នារបស់បុរស នារី និងសិទ្ធិលើទ្រព្យសម្បត្តិ ដែលត្រូវបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ។[8] លើសពីនេះទៅទៀត ក្រមរដ្ឋប្បវេណី គោរពនូវសេរីភាពនៃឆន្ទៈរបស់បុគ្គល និងបញ្ញត្តិអំពីទំនាក់ទំនងគតិយុត្តប្រកបដោយសមភាពរវាងបុគ្គលឯកជន ដោយរួមបញ្ចូលទាំងនីតិបុគ្គល។ នីតិបុគ្គលសាធារណៈ ដែលនៅក្នុងទំនាក់ទំនងនៃការជួញដូរត្រូវចាត់ទុកថាជាបុគ្គលឯកជន។[9] ជាក់ស្តែងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ក៏បានបញ្ញត្តិនូវមាត្រាមួយចំនួនដែលជាប់ពាក់ព័ន្ធនឹងការលែងលះនៅក្នុង គន្ថីទី៧. អំពីញាតិ ហើយនៅក្នុងគន្ថីនេះ ក៏បានចែងលម្អិតទាក់ទងនឹង មូលហេតុនៃការលែងលះ, នីតិវិធីនៃការលែងលះ, ការបែងចែកទ្រព្យសម្បត្តិប្តីប្រពន្ធ, ការប្រគល់អំណាចមេបា និងការផ្តល់អាហារកាតព្វកិច្ច។ ជាពិសេសនៅក្នុងជំពូកទី១.អំពីបញ្ញត្តិទូទៅ,ជំពូកទី៣.អំពីអាពាហ៍ពិពាហ៍ និងជំពូកទី៥.អំពីអំណាចមេបាជាអាទិ៍។

[7] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១។

[8] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា២។

[9] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៣។

### ១.១.២. ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឱ្យប្រើប្រាស់ដោយព្រះមហាក្សត្រ ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ជាបទដ្ឋានគតិយុត្តមាននីតិវិធី ដែលទាក់ទងទៅនឹងបណ្តឹងនៃសំណុំរឿងរដ្ឋប្បវេណី ត្រូវធ្វើតាមបញ្ញត្តិនៃក្រមនេះ លើកលែងតែក្នុងករណីដែលច្បាប់ផ្សេងបានកំណត់ពិសេស។[10] លើសពីនេះ គោលបំណងនៃក្រមនីតិវិធីរដ្ឋប្បវេណី គឺដើម្បីឱ្យតុលាការដោះស្រាយវិវាទរដ្ឋប្បវេណីដោយផ្អែកលើច្បាប់ និងដើម្បីការពារសិទ្ធិរបស់បុគ្គលឯកជន ហើយចំពោះជនគ្រប់រូបត្រូវបានធានានូវសិទ្ធិពឹងពាក់តុលាការបាន។[11] បន្ថែមលើសពីនេះទៅទៀត នីតិវិធីនៃការលែងលះ គឺត្រូវអនុវត្ត ឬអនុលោមទៅតាមក្រមនីតិវិធីរដ្ឋប្បវេណី ក៏ប៉ុន្តែទន្ទឹមនឹងនេះ ដោយសារតែកម្រិតនៃការរីកចម្រើនផ្នែកច្បាប់នៅប្រទេសកម្ពុជាយើងសព្វថ្ងៃមានភាពល្អប្រសើរ ទើបមានច្បាប់មួយចំនួនដែលជាប់ទាក់ទងនឹងនីតិវិធីនៃការលែងលះ មានដូចជា ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០ និងច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១០ ផងដែរ។

### ១.១.៣. ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០

ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានព្រះមហាក្សត្រប្រកាស ព្រះរាជក្រម លេខ នស/រកម/០៧១០/០១៣ នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០។ មួយវិញទៀត ច្បាប់នេះត្រូវបានរៀបចំឡើងក្នុងគោលបំណង ធានាការអនុវត្តឱ្យបានត្រឹមត្រូវនូវនីតិវិធីក្នុងការដោះស្រាយរឿងក្តីដែលមិនមែនជាបណ្តឹង។[12] ជាក់ស្តែង ក្នុងវិសាលភាពនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង បានលើកពីនីតិវិធីនៃការលែងលះតាមការព្រមព្រៀង គឺត្រូវអនុវត្តទៅតាមច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ព្រោះតែច្បាប់នេះបានបញ្ញតិផងដែរ ទាក់ទងទៅនឹងវិសាលភាពនៃការអនុវត្តចំពោះការលែងលះដោយការព្រមព្រៀងនេះ។[13] ជាការពិតណាស់ ការលែងលះដោយការព្រមព្រៀង ដោយបានបញ្ញត្តិនៅក្នុងមាត្រា៩៧៩ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ហើយក៏មានចែងនៅក្នុងច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង នៃតារាងឧបសម្ព័ន្ធផ្នែកទី៤ លេខរៀងទី៥ ទៀតផង។ មួយវិញទៀត ចំពោះករណីណាដែលច្បាប់បានកំណត់ ចំពោះការដោះស្រាយរឿងក្តីលែងលះដោយការព្រមព្រៀងក៏ត្រូវអនុលោមជាមួយនឹងនីតិវិធីរដ្ឋប្បវេណីទូទៅផងដែរ។ ហេតុដូច្នេះហើយ ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី

[10] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១។

[11] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២។

[12] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០, មាត្រា២។

[13] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០, តារាងឧបសម្ព័ន្ធផ្នែកទី៤ លេខរៀងទី៥។

ដែលមិនមែនជាបណ្ដឹង ក៏ត្រូវបានគេយកមកប្រើប្រាស់ក្នុងការដោះស្រាយរឿងក្ដីលែងលះតាមការព្រមព្រៀងបន្ថែមទៀត។

**១.១.៤. ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១០**

ច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានព្រះមហាក្សត្រប្រកាស ព្រះរាជក្រមលេខ នស/រកម/០៦១០/០០៨ បានដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១០។ ច្បាប់នេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងធានា ការអនុវត្តឱ្យបានត្រឹមត្រូវនូវនីតិវិធីក្នុងការដោះស្រាយរឿងក្ដីដែលជាប់ទាក់ទងនឹងឋានៈបុគ្គល។[14] ចំពោះវិសាលភាពនៃការអនុវត្តរបស់ច្បាប់នេះ គឺនៅត្រង់ចំណុច (គ) មាត្រា៣ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១០ ក៏បានបញ្ញត្តិពីការអនុវត្តបណ្ដឹង ទាក់ទងនឹងការលែងលះផងដែរ។ [15] ដូច្នេះការលែងលះដោយគ្មានការព្រមព្រៀង ដែលជាការលែងលះដោយមានបណ្ដឹងលែងលះ ដែលបណ្ដឹងលែងលះនោះ នឹងត្រូវអនុវត្តនីតិវិធីតាមបញ្ញត្តនៃច្បាប់នេះ។ ប៉ុន្តែ ចំពោះចំណុចនីតិវិធីផ្សេងទៀតដែលច្បាប់នេះមិនមាន គឺត្រូវប្រើប្រាស់តាមមូលដ្ឋាននៃក្រមនីតិវិធីរដ្ឋប្បវេណីបន្ថែម មិនមែន មានន័យថាការលែងលះដោយគ្មានការព្រមព្រៀងនេះ ត្រូវបានអនុលោមការច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលតែមួយនោះទេ ព្រោះវិសាលភាពនៃការអនុវត្តក្រមរដ្ឋប្បវេណី គឺបានក្ដោបទៅលើបណ្ដឹងរដ្ឋប្បវេណីទាំងអស់។

**១.១.៥. ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩**

ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ បានសម្រេចប្រកាសឱ្យប្រើប្រាស់ច្បាប់នេះ ដែលរដ្ឋសភានៃរដ្ឋកម្ពុជា បានអនុម័តនៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៨៩ នាសម័យប្រជុំសាមញ្ញលើកទី១៧ នីតិកាលទី១។ ច្បាប់នេះ មានគោលដៅ ដាក់បទបញ្ញា និងការរៀបអាពាហ៍ពិពាហ៍ និងគ្រួសារ ដោយធានាសមភាពរវាងសហព័ទ្ធក្នុងអាពាហ៍ពិពាហ៍ និងក្នុងជីវភាពគ្រួសារ ពង្រឹងការទទួលខុសត្រូវរបស់ឪពុកម្ដាយ ក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូន និងជម្រុញការបណ្ដុះបណ្ដាលសីលធម៌ និងការអប់រំ ដើម្បីឱ្យទៅជាពលរដ្ឋល្អ មានមនសិការស្នេហាជាតិ ស្រឡាញ់ការងារ មានសម្បជញ្ញៈទទួលខុសត្រូវចំពោះសង្គម។[16] ម្យ៉ាងវិញទៀតច្បាប់នេះក៏បានបញ្ញតិអំពីមូលហេតុនៃការលែងលះគ្នាផងដែរ ដោយប្ដី ឬ ប្រពន្ធអាចប្ដឹងសុំលែងលះគ្នាបាន កាលបើមានមូលហេតុគ្រប់គ្រាន់ នេះបញ្ជាក់ថាខ្លួនពុំអាចរួមរស់ជាមួយគ្នាតទៅទៀតបានទេ។ ដោយមូលហេតុទាំងនោះមានដូចជាៈ ការចុះចោលពីលំនៅឋាន ដោយឥតមានមូលហេតុត្រឹមត្រូវ ហើយឥតមានផ្គត់ផ្គង់ស្បៀងអាហារ និងទំនុកបម្រុងកូនសោះឡើយ។ មិនតែប៉ុណ្ណោះថែមទាំងមានការវាយដំឃោរឃៅ ធ្វើទុក្ខបុកម្នេញប្រមាថមើលងាយ

[14] ច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/០៦១០/០០៨, ០៨ មិថុនា ២០១០, មាត្រា២។

[15] ច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/០៦១០/០០៨, ០៨ មិថុនា ២០១០, មាត្រា៣។

[16] ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩, មាត្រា១។

ធ្ងន់ធ្ងរចំពោះសហព័ទ្ធ ឬ ចំពោះបុព្វញាតិរបស់សហព័ទ្ធនេះ។ ហើយមានចរិតផ្ទុយពីសីលធម៌ ឬ ប្រព្រឹត្តអាណាចារ្យ អពលានុភាព នៃលិង្គ និងបានរស់នៅបែកគ្នាអស់រយៈពេលជាង ០១ (មួយ) ឆ្នាំ។[17] ការលែងលះដែលយោងតាមច្បាប់នេះ គឺបានអនុញ្ញាតឱ្យមានការលែងលះដោយការស្ម័គ្រចិត្តរវាងប្តីប្រពន្ធទាំងពីរនាក់បាន។[18] ហើយ ប្រសិនបើប្តីប្រពន្ធទាំងពីរនោះ សម្រេចចិត្តច្បាស់ហើយថាអស់មនោសញ្ចេតនារស់នៅជាមួយគ្នា ហើយសង្ឃឹមថានឹងមិនអាចបន្តជាមួយគ្នាទៀតបាន។ ហេតុដូច្នេះពាក់ព័ន្ធនឹងច្បាប់នេះត្រូវបាន និរាករណ៍ដោយ ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ២០១១ ដោយរក្សាទុកតែមាត្រាចំនួន ០៥ (ប្រាំ) ប៉ុណ្ណោះ ចាប់ពីមាត្រា៧៦ មាត្រា៧៧ និងមាត្រា៧៩ ដល់មាត្រា៨១ ដែលបានបញ្ញត្តិទាក់ទងនឹងអាហារកិច្ចក្រោយពេលលែងលះ។

### ១.១.៦. ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ២០១១

ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី បានប្រកាសឱ្យប្រើប្រាស់ដោយព្រះរាជក្រម លេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១។ ច្បាប់នេះមានគោលបំណងធានាស្ថិរភាពនៃទំនាក់ទំនងគតិយុត្តផ្នែករដ្ឋប្បវេណី និងធានាឱ្យមានការអនុវត្តបានត្រឹមត្រូវបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណី។[19] លើសពីនេះច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី មានវិសាលភាពអនុវត្តចំពោះបញ្ហាដែលទាក់ទងនឹងការអនុវត្តក្រមរដ្ឋប្បវេណី។[20] ដោយស្របតាមគោលការណ៍នៃការអនុវត្តក្រមរដ្ឋប្បវេណីបានបញ្ញត្តិថា ក្រមរដ្ឋប្បវេណី មិនត្រូវអនុវត្តចំពោះបញ្ហាដែលបានកើតឡើងមុនកាលបរិច្ឆេទនៃការអនុវត្តដែលបានកំណត់នៅក្នុងមាត្រា៤ (កាលបរិច្ឆេទនៃការអនុវត្តក្រមរដ្ឋប្បវេណី) លើកលែងតែមានបញ្ញត្តិផ្សេងទៀត។ ប៉ុន្តែទំនាក់ទំនងគតិយុត្តជាបន្តដែលបានកើតឡើងមុនកាលបរិច្ឆេទនៃការអនុវត្ត ហើយនៅតែមានអត្ថិភាពក្រោយពេលកាលបរិច្ឆេទនៃការអនុវត្ត ត្រូវអនុលោមតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ដោយគិតត្រឹមកាលបរិច្ឆេទនៃការអនុវត្ត។[21]

### ១.១.៧. ច្បាប់ស្តីពីអត្រានុកូលដ្ឋានស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ឆ្នាំ២០២៣

ច្បាប់ស្តីពីអត្រានុកូលដ្ឋានស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម បានប្រកាសឱ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ នស/រកម/០៧២៣/០០៩ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២៣។ ច្បាប់នេះបានកំណត់អំពីវិធាន និងនីតិវិធីដែលទាក់ទងនឹងការចុះបញ្ជីអត្រានុកូលដ្ឋាន ការចុះបញ្ជីស្នាក់នៅ ការរៀបចំស្ថិតិអត្រានុកូលដ្ឋាន ការចុះបញ្ជីអត្តសញ្ញាណបុគ្គលនឹងការរៀបចំ និងការគ្រប់គ្រងបញ្ជីប្រជាជន ក្នុងគោលបំណងដើម្បី ធានាឱ្យមានការចុះបញ្ជីអត្រានុកូលដ្ឋាន ដែលជាកាតព្វកិច្ច ជាសកលដោយជាប់លាប់ និងអចិន្ត្រៃយ៍, ធានាឱ្យមានការចុះបញ្ជី

---

[17] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩, មាត្រា៣៩។

[18] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩, មាត្រា៤០។

[19] ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, លេខ នស/រកម/០៥១១/០០៧, ៣១ ឧសភា ២០១១, មាត្រា២។

[20] ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, លេខ នស/រកម/០៥១១/០០៧, ៣១ ឧសភា ២០១១, មាត្រា៣។

[21] ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, លេខ នស/រកម/០៥១១/០០៧, ៣១ ឧសភា ២០១១, មាត្រា៥(១)។

អត្តសញ្ញាណបុគ្គលជាសកល ដោយជាប់លាប់ និងជាអចិន្ត្រៃយ៍, ធានាឱ្យមនុស្សគ្រប់រូបមានអត្តសញ្ញាណខាងផ្លូវច្បាប់តាមរយៈការចុះបញ្ជីអត្រានុកូលដ្ឋាន ការចុះបញ្ជីអត្តសញ្ញាណ ដោយផ្តល់ចំពោះបុគ្គលម្នាក់ៗនូវលេខសម្គាល់អត្តសញ្ញាណបុគ្គល និងធានានូវការគោរពសិទ្ធិមនុស្ស ការទទួលបានសេវាគ្រប់ប្រភេទ ហើយជាមូលដ្ឋានសម្រាប់រៀបចំផែនការអភិវឌ្ឍន៍ និងការតាមដានភាពរីកចម្រើននៃសង្គម។[22] ជាមួយគ្នានេះដែរ ច្បាប់នេះក៏មានវិសាលភាពអនុវត្តចំពោះជនគ្រប់រូបដែលរស់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា និងប្រជាពលរដ្ឋខ្មែរដែលរស់នៅបរទេស។[23]

### ១.១.៨. ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ឆ្នាំ២០១៣

ប្រកាស ស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ លេខ ៨១.កយ.ស្រក/១៣ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៣។ ប្រកាសនេះ មានគោលដៅធានានូវប្រសិទ្ធិភាព នៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដែលបង្កើតអានុភាពរវាងប្តីប្រពន្ធដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ឱ្យបានត្រឹមត្រូវទៅតាមក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ និងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ២០១១។[24] ជាក់ស្តែងនៅក្នុងប្រកាសនេះមានគោលបំណងដើម្បីអនុញ្ញាតឱ្យប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា អាចធ្វើការចុះបញ្ជីកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិនៅមុន ឬ ក្រោយការរៀបអាពាហ៍ពិពាហ៍បាន ដើម្បីកំណត់ឱ្យបានច្បាស់លាស់ អំពីទំនាក់ទំនងទ្រព្យសម្បត្តិប្តីប្រពន្ធ។[25] លើសពីនេះ ប្រកាសនេះ មានវិសាលភាពអនុវត្តទៅលើចំណុចមួយចំនួនដូចជា ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, ការចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, ការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ និងនីតិវិធីនៃការចេញលិខិតបញ្ជាក់។[26]

## ១.២. ទំនាក់ទំនងគតិយុត្តនៃសហព័ទ្ធ

ដូចយើងបានដឹងស្រាប់ហើយថា ចំពោះការរៀបអាពាហ៍ពិពាហ៍ដែលស្របតាមច្បាប់ធ្វើឱ្យកើតឡើងនូវចំណងដែលជាប់ទាក់ទងរវាងគូភាគីប្តីនឹងប្រពន្ធទាំងពីរនាក់ ហើយទំនាក់ទំនងគតិយុត្តនៃសហព័ទ្ធ អាចបង្កើតឱ្យមាននូវចំណងគតិយុត្តមួយចំនួនជាមួយគ្នាដូចជា៖ ការបង្កើតឱ្យមានបុត្រ, ការបង្កើតឱ្យមានទ្រព្យសម្បត្តិរួមរបស់ប្តីនឹងប្រពន្ធ និងទំនាក់ទំនងគតិយុត្តអំពីទ្រព្យសម្បត្តិរវាងប្តីនឹងប្រពន្ធ ហើយអាចធ្វើឱ្យកើតមានឡើងនូវសិទ្ធិ និងករណីយកិច្ចរបស់សហព័ទ្ធផងដែរ។

---

22 ច្បាប់ស្តីពីអត្រានុកូលដ្ឋានស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម, លេខ នស/រកម/០៧២៣/០០៩, ០១ កក្កដា ២០២៣, មាត្រា១។

23 ច្បាប់ស្តីពីអត្រានុកូលដ្ឋានស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម, លេខ នស/រកម/០៧២៣/០០៩, ០១ កក្កដា ២០២៣, មាត្រា២។

24 ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, លេខ ៨១.កយ.ស្រក/១៣, ០៩ សីហា ២០១៣, ប្រការ១។

25 ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, លេខ ៨១.កយ.ស្រក/១៣, ០៩ សីហា ២០១៣, ប្រការ២។

26 ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, លេខ ៨១.កយ.ស្រក/១៣, ០៩ សីហា ២០១៣, ប្រការ៣។

## ១.៣. ប្រភេទនៃការលែងលះ

ជាក់ស្តែងបើយើងក្រឡេកមកមើល ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បានបញ្ញត្តិឱ្យមានការលែងលះដោយការព្រមព្រៀងរវាងគូភាគីទាំងពីរ ដោយស្របតាមបញ្ញត្តិមាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។ នៅក្នុងករណីនេះដែរ តុលាការនឹងសម្រេចឱ្យមានការលែងលះគ្នា ប្រសិនបើតុលាការយល់ឃើញថា ភាគីទាំងសងខាងមានបំណងពិតប្រាកដ ក្នុងការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍។

មួយវិញទៀត ប្រសិនបើភាគីមិនមានការព្រមព្រៀងលែងលះគ្នាទេ នោះការលែងលះនៅតែអាចធ្វើទៅបាន លុះត្រាតែមានមូលហេតុត្រឹមត្រូវយ៉ាងច្បាស់លាស់ដូចមានចែងក្នុងមាត្រា ៩៧៨ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។

ហេតុនេះ បើយើងក្រឡេកមកមើលក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បានបញ្ញតិថា ការលែងលះមានពីរប្រភេទគឺ ការលែងលះដោយការព្រមព្រៀង និងការលែងលះដោយគ្មានការព្រមព្រៀង។

### ១.៣.១. ការលែងលះដោយការព្រមព្រៀង

ការលែងលះដោយការព្រមព្រៀង សំដៅលើការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍។[27] ហេតុនេះ បើនៅក្នុងអំឡុងពេលដែលអ្នកទាំងពីររស់នៅជាមួយគ្នាជាប្តី ប្រពន្ធ មានការរកាំរកូសនឹងគ្នា រស់នៅមិនចុះសម្រុងនឹងគ្នា ឬ ក៏បង្កើតឱ្យមាននូវសកម្មភាពណាមួយដែលបញ្ជាក់ឱ្យឃើញថាអ្នកទាំងពីរពិតជាអស់មនោសញ្ចេតនា និងអស់និស្ស័យជាប្តីប្រពន្ធនឹងគ្នា ហើយក៏មិនអាចបន្តក្នុងការកសាងគ្រួសារជាមួយគ្នាហើយនោះ អ្នកទាំងពីរអាចសម្រេចចិត្តលែងលះជាមួយគ្នាដោយស្ម័គ្រចិត្តបាន។

### ១.៣.២. ការលែងលះដោយគ្មានការព្រមព្រៀង

ការលែងលះដោយគ្មានការព្រមព្រៀង ឬអាចហៅម៉្យាងទៀតបានថាជា ការលែងលះតាមពាក្យបណ្តឹង សំដៅលើការផ្តាច់នូវចំណងអាពាហ៍ពិពាហ៍ ដោយភាគីម្ខាងមិនបានធ្វើការព្រមព្រៀងគ្នាអំពីសិទ្ធិ និងកាតព្វកិច្ចផ្សេងៗក្រោយពេលលែងលះ។ ការលែងលះដោយគ្មានការព្រមព្រៀង ត្រូវអនុលោមទៅតាមច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។

## ១.៤. មូលហេតុនៃការលែងលះ

ជាការពិតណាស់ការរៀបអាពាហ៍ពិពាហ៍ គឺធ្វើឡើងដោយគោលការណ៍ស្ម័គ្រចិត្ត និងពេលមានចំណងតាមផ្លូវច្បាប់ ហើយបុរស និងនារី ដែលជាសហព័ទ្ធមិនអាចទាមទារការលែងលះតាមតែអំពើចិត្តរបស់ខ្លួននោះឡើយ។ ហេតុនេះ បើមានភាគីណាមួយដែលជាភាគីខាងប្តី ឬខាងប្រពន្ធ ចង់លែងលះ គឺត្រូវតែមានអង្គហេតុ

[27] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧៩។

បញ្ជាក់ពីមូលហេតុរបស់ខ្លួនដែលបណ្តាលឱ្យខ្លួនមិនអាចរស់នៅជាមួយគ្នាបានតទៅថ្ងៃមុខទៀត ហើយចំណុចនេះក៏ជាវិធានការមួយក្នុងការការពារភាពសុចរិតរបស់ភាគីម្ខាងទៀតដែរ។ ដូច្នេះហើយទើបក្រមរដ្ឋប្បវេណីបានកំណត់ពីមូលហេតុមួយចំនួនដែលជាប់ពាក់ព័ន្ធនឹងការលែងលះ ដើម្បីឱ្យភាគីដែលរៀបអាពាហ៍ពិពាហ៍ស្របច្បាប់គឺ ប្តី ឬប្រពន្ធ អាចមានសិទ្ធិក្នុងការដាក់ពាក្យបណ្តឹងលែងលះគ្នា។[28] បន្ថែមលើសពីនេះ ដោយស្របទៅតាមខ្លឹមសារនៃមាត្រា ៩៧៩ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បានអនុញ្ញាតឱ្យមានការលែងលះដោយការព្រមព្រៀងរវាងគូភាគីផងដែរ។ ក្នុងករណីនេះដែរ តុលាការនឹងសម្រេចឱ្យមានការលែងលះគ្នា ប្រសិនបើតុលាការយល់ឃើញថា ភាគីទាំងសងខាងមានបំណងពិតប្រាកដ ក្នុងការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍។ អាស្រ័យហេតុនេះ យើងខ្ញុំនឹងធ្វើការបកស្រាយឱ្យកាន់តែច្បាស់អំពីមូលហេតុនៃការលែងលះគ្នា ដោយបានកំណត់យកនូវចំណុចដូចជា (១.៤.១.) អំពើផិត, (១.៤.២.) ការបោះបង់សហព័ទ្ធចោលដោយគ្មានមូលហេតុត្រឹមត្រូវ, (១.៤.៣.) ការមិនបានដឹងថាស្លាប់ ឬរស់របស់សហព័ទ្ធណាម្ខាង, (១.៤.៤.) ការរស់នៅបែកបាក់គ្នារបស់សហព័ទ្ធ និង(១.៤.៥.) ករណីធ្ងន់ធ្ងរដែលមិនអាចបដិទានទំនាក់ទំនងឡើងវិញបាន។

### ១.៤.១. អំពើផិត

អំពើផិត គឺជាការរួមសេវនកិច្ចរវាងបុរសដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនដែលមិនទាន់រំលាយជាមួយស្ត្រីដទៃក្រៅពីប្រពន្ធរបស់ខ្លួន ឬការរួមសេវនកិច្ចរវាងស្ត្រីដែលមានចំណងអាពាហ៍ពិពាហ៍មិនទាន់រំលាយជាមួយបុរសដទៃក្រៅពីប្តីរបស់ខ្លួន។[29] ហើយភាគីខាងប្តី ឬប្រពន្ធ អាចដាក់ពាក្យបណ្តឹងលែងលះគ្នាបានតែក្នុងករណីដែលបានកំណត់ឡើងថា បើបានប្រព្រឹត្តអំពើផិតទៅលើសហព័ទ្ធ។[30]

ឧបមាថា៖ លោក សុខ និងលោកស្រី សុខា ជាប្តីប្រពន្ធនឹងគ្នា។ ក្រោយពីបានរស់នៅជាមួយគ្នាអស់រយៈពេល ២ (ពីរ) ឆ្នាំ ស្រាប់តែលោក សុខ ទៅចាប់ចិត្តស្រឡាញ់ជាមួយនឹងនាង សយ ដោយអ្នកទាំងពីរបានដើរលេង និងណាត់ជួបគ្នាជាញឹកញាប់ ព្រមទាំងបានរួមសេវនកិច្ចជាមួយគ្នា។ ជាមួយគ្នានេះដែរ ថ្ងៃមួយលោកស្រី សុខា ក៏បានដឹងថាប្តីរបស់លោកស្រីមានស្រី ហើយលោកស្រីក៏បានតាមដានរហូតបានឃើញផ្ទាល់ភ្នែកថាប្តីរបស់លោកស្រីពិតជាមានលួចលាក់ស្រីខាងក្រៅពិតប្រាកដមែន។ ក្នុងករណីនេះ ទង្វើរបស់លោក សុខ ដែលបានធ្វើដាក់លោកស្រី សុខា ជាការផិតក្បត់យ៉ាងពិតប្រាកដ។ ដូច្នេះ លោកស្រី សុខា មានសិទ្ធិក្នុងការដាក់ពាក្យបណ្តឹងដើម្បីសុំលែងលះពីលោក សុខ ទៅតុលាការបាន។

[28] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧៨ (១)។
[29] ច្បាប់ស្តីពីឯកពន្ធភាព, លេខ នស/រកម/១០០៦/០២៦, ២១ តុលា ២០០៦, មាត្រា៧។
[30] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧៨ (១)(ក)។

### ១.៤.២. ការបោះបង់សហព័ទ្ធចោលដោយគ្មានមូលហេតុត្រឹមត្រូវ

ចំពោះការបោះបង់សហព័ទ្ធចោលដោយគ្មានមូលហេតុត្រឹមត្រូវ ក៏ជាចំណុចមួយដែលគួរឱ្យកត់សម្គាល់ផងដែរ ព្រោះការបោះបង់ចោលក៏មានន័យថា បោះបង់ទាំងករណីយកិច្ចរួមរស់នឹងគ្នា ដែលប្តី ប្រពន្ធគ្រប់រូបគួរតែអនុវត្តនៅពេលដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នារួចហើយ នោះភាគីណាម្ខាងដែលត្រូវបានបោះបង់នោះអាចដាក់ពាក្យបណ្តឹងទៅតុលាការបាន។[31] ដោយហេតុថាជីវិតរស់នៅជាប្តីប្រពន្ធនឹងគ្នា គឺត្រូវមានករណីយកិច្ចរួមរស់នឹងគ្នា សហការគ្នា និងសង្គ្រោះគ្នាទៅវិញទៅមក ហើយប្តីប្រពន្ធត្រូវរួមរស់ជីវភាពជាមួយគ្នា ហើយត្រូវសហការសង្គ្រោះគ្នាទៅវិញទៅមក។[32]

ឧបមាថា៖ លោក សៅ និងលោកស្រី នារី ជាប្តីប្រពន្ធនឹងគ្នា។ ស្រាប់តែថ្ងៃមួយលោកស្រី នារី បានចុះចេញពីផ្ទះចោលលោក សៅ រួចទៅរស់នៅជាមួយ និងបងស្រីរបស់លោកស្រី ដោយមិនបានឈ្លោះប្រកែកគ្នាសោះឡើយ។ លោកស្រី នារី បានចុះចេញដោយស្ងាត់ៗ ដោយមិនមានមូលហេតុត្រឹមត្រូវនោះទេ។ ក្នុងករណីនេះ ទង្វើរបស់លោកស្រី នារី ដែលបានបោះបង់សហព័ទ្ធចោលដោយមិនបានប្រាប់ពីមូលហេតុបែបនេះ ជាមូលហេតុចម្បងមួយដែលភាគីម្ខាងទៀតគឺលោក សៅ ដែលជាប្តីរបស់លោកស្រី នារី នោះ អាចដាក់ពាក្យបណ្តឹងសុំលែងលះពីលោកស្រី នារី ទៅតុលាការបាន។

### ១.៤.៣. ការមិនបានដឹងថាស្លាប់ ឬរស់របស់សហព័ទ្ធណាម្ខាង

ប្តី ឬប្រពន្ធ ដែលបានចុះចេញពីផ្ទះ ដោយសហព័ទ្ធម្ខាងទៀតមិនបានដឹងថាទៅនៅទីណា កន្លែងណា ហើយថែមទាំងមិនអាចទាក់ទងបានទៀត។ ការមិនបានដឹងថាសហព័ទ្ធនោះស្លាប់ ឬរស់ ភាគីអាចយកជាមូលហេតុក្នុងការលែងលះរបស់ខ្លួនបានផងដែរ ប៉ុន្តែការមិនបានដឹងដំណឹង ដោយទាក់ទងមិនបានបែបនេះ ឬការអវត្តមានរបស់សហព័ទ្ធត្រូវតែមានរយៈពេលជាង ១ (មួយ) ឆ្នាំ។[33] ក្នុងករណីនេះចង់មានន័យថា បន្ទាប់ពីផុតរយៈពេលជាង ១ (មួយ) ឆ្នាំនេះហើយសហព័ទ្ធណាម្ខាងដែលបានបាត់ខ្លួននោះ នៅតែមិនមានដំណឹងថាស្លាប់ ឬ រស់នោះ សហព័ទ្ធម្ខាងទៀតអាចដាក់ពាក្យសុំលែងលះ និងសហព័ទ្ធម្ខាងទៀតបាន។

ឧបមាថា៖ លោក ហេង និងលោកស្រី នី ជាប្តីប្រពន្ធនឹងគ្នា។ ក្រោយពីបានរស់នៅជាមួយគ្នាសុខៗ ស្រាប់តែលោក ហេង បានសម្រេចចិត្តចាកចេញពីស្រុកកំណើតដើម្បីទៅធ្វើការនៅក្រៅប្រទេស។ បន្ទាប់ពីថ្ងៃដែលលោក ហេង បានចាកចេញទៅ គឺលោកស្រី នី ទាក់ទងទៅលោកមិនបានសោះឡើយ ហើយក៏ពុំមានដំណឹងពីលោកថានៅរស់ ឬ ក៏ស្លាប់ដោយសារមូលហេតុអ្វីមួយត្រឡប់មកវិញដែរ។ ក្នុងករណីនេះ បើលោក ហេង

[31] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧៨ (១)(ខ)។

[32] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៦៦។

[33] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧៨ (១)(គ)។

បានដំណឹងបែបនេះ លើសពី ១ (មួយ) ឆ្នាំ នោះលោកស្រី នី អាចដាក់ពាក្យបណ្ដឹងសុំលែងលះ ពីលោក ហេង ទៅតុលាការបាន។

### ១.៤.៤. ការរស់នៅបែកបាក់គ្នារវាងសហព័ទ្ធ

បើសហព័ទ្ធ បានរស់នៅបែកបាក់គ្នាជាបន្តបន្ទាប់រហូតដល់អស់រយៈពេលជាង ១ (មួយ) ឆ្នាំ ក៏ជាមូលហេតុនៃការលែងលះផងដែរ ហើយការរស់នៅបែកគ្នាបែបនេះអាចបណ្ដាលមកពីការរស់នៅមិនចុះសម្រុងនឹងគ្នា ហើយក៏មានការទើសទាល់នឹងគ្នាទើបជាហេតុធ្វើឱ្យភាគីណាម្ខាងសម្រេចចិត្តចាកចេញទៅនៅផ្ទះផ្សេងមួយទៀត។[34] ការរស់នៅបែកបាក់គ្នា មិនមែនសុទ្ធសឹងតែជាចំណុចដែលភាគីអាចដាក់ពាក្យបណ្ដឹងលែងលះគ្នាបាននោះទេ ព្រោះប្ដីប្រពន្ធមួយចំនួនទៀត ក៏មានរស់នៅបែកគ្នាដូចគ្នា តែដោយសារតែកត្តាការងារជាដើម នេះគឺដើម្បីយកចំណូលសម្រាប់ផ្គត់ផ្គង់ដល់គ្រួសារ។

ឧបមាថា៖ ក្រោយពីលោក ឈុន និងលោកស្រី ដា បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាអស់រយៈពេល ៣ (បី) ឆ្នាំរួចមក លោក ឈុន និងលោកស្រី ដា បានសម្រេចចិត្តរស់នៅបែកបាក់គ្នា ដោយសារតែមានការអាក់អន់ស្រពន់ចិត្តនឹងគ្នាពីរឿងបន្តិចបន្តួច។ ហេតុនេះ ក្នុងករណីដែលអ្នកទាំងពីររស់នៅបែកគ្នាលើសពី ១ (មួយ) ឆ្នាំ នោះភាគីណាម្ខាងអាចដាក់ពាក្យបណ្ដឹងសុំលែងលះទៅតុលាការបាន។

### ១.៤.៥. ករណីធ្ងន់ធ្ងរដែលមិនអាចបដិទានទំនាក់ទំនងឡើងវិញបាន

តាមការបកស្រាយនៅចំណុចមួយចំនួនដែលជាប់ពាក់ព័ន្ធទៅនឹងមូលហេតុនៃការលែងលះខាងលើរួចមក ចំពោះមូលហេតុនៃការលែងលះ មិនមែនមានត្រឹមតែចំណុចដែលបានបកស្រាយនឹងនោះទេ ពោលគឺនៅមានមូលហេតុផ្សេងទៀតដែលជាប់ពាក់ព័ន្ធនោះគឺ ការបែកបាក់ ហើយដោយគ្មានសង្ឃឹមថាអាចនឹងអាចបដិទានឡើងវិញបាន។[35] ជាមួយគ្នានេះដែរ ចំពោះកំហុសដែលអាចចាត់ទុកថាមានលក្ខណៈធ្ងន់ធ្ងរ ដែលមិនអាចឱ្យភាគីទាំងពីរបដិទានទំនាក់ទំនងឡើងវិញបាននោះមានដូចជា ការជេរប្រមាថ ការប្រើប្រាស់អំពើហិង្សា ការចំណាយប្រាក់ខ្ជះខ្ជាយដើម្បីតែប្រយោជន៍ផ្ទាល់ខ្លួន ការជំពាក់បំណុលគេដោយគ្មានមូលហេតុត្រឹមត្រូវជាអាទិ៍ ដែលទាំងអស់នេះជាមូលហេតុដែលបណ្ដាលឱ្យមានការបែកបាក់ និងមិនអាចបដិទានវិញបានទេ។ ក្នុងករណីទាំងនេះហើយ ដែលជាមូលហេតុដែលអាចឱ្យភាគីម្ខាងដាក់ពាក្យបណ្ដឹងលែងលះជាមួយនឹងភាគីម្ខាងទៀតបាន។

[34] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧៨ (១)(យ)។

[35] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧៨ (១)(ង)។

# ជំពូកទី២
# ការលែងលះដោយ
# ការព្រមព្រៀង

# ជំពូកទី២
# ការលែងលះដោយការព្រមព្រៀង

ការលែងលះដោយការព្រមព្រៀង អាចធ្វើទៅបានលុះត្រាតែ គូភាគីបានព្រមព្រៀងគ្នាក្នុងការរំលាយនូវចំណងអាពាហ៍ពិពាហ៍។ ហើយអាពាហ៍ពិពាហ៍ មានអានុភាព ដោយការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជីនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។[36] ហេតុនេះ ការលែងលះដោយការព្រមព្រៀង គឺស្ថិតនៅក្រោមវិសាលភាព នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។[37] ការលែងលះដោយការព្រមព្រៀង តុលាការត្រូវសម្រេចសេចក្តីដោយដីកាសម្រេចអំពីការលែងលះ។[38] ជាក់ស្តែងនៅក្នុងជំពូកទី២ ការលែងលះដោយការព្រមព្រៀង យើងខ្ញុំក៏បានលើកយកនូវចំណុចមួយចំនួនបន្ថែមទៀតផងដែរ ដែលត្រូវបកស្រាយបន្តពីនីតិវិធីក្នុងការលែងលះដោយការព្រមព្រៀង ដោយធ្វើការសិក្សាទៅលើចំណុចដូចជា៖ (២.១.) ទិដ្ឋភាពទូទៅនៃការលែងលះដោយការព្រមព្រៀង, (២.២.) អាជ្ញាធរមានសមត្ថកិច្ច, (២.៣.) នីតិវិធីដែលត្រូវបំពេញដោយភាគី និង(២.៤.) នីតិវិធីដោះស្រាយការលែងលះដោយការព្រមព្រៀង។

## ២.១. ទិដ្ឋភាពទូទៅនៃការលែងលះដោយការព្រមព្រៀង

ការលែងលះដោយការព្រមព្រៀង គឺជាការរំលាយនូវចំណងអាពាហ៍ពិពាហ៍ដែលស្របច្បាប់របស់គូភាគី។ ហើយការព្រមព្រៀងនេះទៀតសោត កើតឡើងពីឆន្ទៈពិតប្រាកដរបស់គូភាគីដោយផ្ទាល់។ ក្នុងករណីនេះ តុលាការអាចសម្រេចឱ្យលែងលះគ្នាបាន ប្រសិនបើតុលាការយល់ឃើញថា ភាគីទាំងសងខាងមានបំណងពិតប្រាកដ ក្នុងការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍។[39] ចំពោះការលែងលះដោយការព្រមព្រៀង មុននឹងសម្រេចដាក់ពាក្យសុំទៅតុលាការ ភាគីទាំងសងខាងត្រូវព្រមព្រៀងគ្នាឱ្យរួចជាស្រេចនូវមួយចំនួនដូចជាស្នើសុំការបែងចែកទ្រព្យសម្បត្តិ, ការបែងចែកអំណាចមេបាលើកូន, បន្ទុកសាហ៊ុយចំណាយសម្រាប់ចិញ្ចឹមបីបាច់ថែរក្សាកូន ជាអាទិ៍។ ហេតុនេះ ការលែងលះដោយការព្រមព្រៀម មិនមែនជារឿងដែលស្មុគស្មាញក្នុងការដោះស្រាយនោះទេ ព្រោះតែភាគីទាំងសងខាងបានសម្រេចព្រមព្រៀងគ្នារួចជាស្រេចនូវកម្មវត្ថុដែលបានដាក់មកតុលាការរួចរាល់ហើយដែរ។ ក្នុងករណីនេះ ភាគីដាក់ពាក្យសុំលែងលះមកតុលាការនេះ គឺគ្រាន់តែសុំឱ្យ

[36] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៥៥។

[37] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០, មាត្រា១ និងមាត្រា៣

[38] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០, មាត្រា៣ (២)។

[39] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧៩។

តុលាការចេញដីកាសម្រេចតាមរយៈការដាក់ពាក្យសុំលែងលះដោយការព្រមព្រៀងរបស់គូភាគីតែប៉ុណ្ណោះ។ យ៉ាងណាមិញ ការលែងលះដោយការព្រមព្រៀងក៏ដោយ ក៏ត្រូវតែឆ្លងកាត់នីតិវិធីនៅតុលាការដដែល។

**២.២. អាជ្ញាធរមានសមត្ថកិច្ច**

ចំពោះភាគីដែលមានឆន្ទៈចង់ស្នើសុំលែងលះ ភាគីត្រូវដាក់ពាក្យសុំទៅអាជ្ញាធរដែលមានសមត្ថកិច្ចលើការដោះស្រាយរឿងក្ដីលែងលះ។ តែបើក្នុងករណីមានតុលាការច្រើនដែលមានសមត្ថកិច្ចលើរឿងក្ដីណាមួយ នោះតុលាការដែលទទួលពាក្យសុំលែងលះមុនគេចំពោះរឿងក្ដីនោះ ត្រូវមានសមត្ថកិច្ចដោះស្រាយ។[40] ដូចនេះ ដើម្បីស្នើសុំលែងលះដោយការព្រមព្រៀងបាន ត្រូវឆ្លងកាត់នូវអាជ្ញាធរដែលមានសមត្ថកិច្ចចំនួន ពីរគឺ៖ (២.២.១.) ក្រុមប្រឹក្សាឃុំ-សង្កាត់ និង(២.២.២.) តុលាការរាជធានី-ខេត្ត។

**២.២.១. ក្រុមប្រឹក្សាឃុំ-សង្កាត់**

ក្នុងដំណាក់កាលនេះ ក្រុមប្រឹក្សាឃុំ-សង្កាត់ មិនមានសមត្ថកិច្ចក្នុងការសម្រេចឱ្យគូភាគីលែងលះគ្នា ការបែងចែកទ្រព្យសម្បត្តិ, ការបែងចែកអំណាចមេបាលើកូន, ក៏ដូចជាបន្ទុកសាហ៊ុយចំណាយសម្រាប់ចិញ្ចឹមបីបាច់ថែរក្សាកូន នោះឡើយ។ សូមបញ្ជាក់ផងដែរថា ក្រុមប្រឹក្សាឃុំ-សង្កាត់ ដើរតួនាទីយ៉ាងចម្បងនៅក្នុងនីតិវិធីផ្សះផ្សា។ ហេតុនេះ ការដាក់ពាក្យសុំលែងលះទៅកាន់ក្រុមប្រឹក្សាឃុំ-សង្កាត់ គ្រាន់តែជាជម្រើសរបស់គូភាគីតែប៉ុណ្ណោះ ពោលគឺថាភាគី ដែលចង់ដាក់ពាក្យសុំលែងលះ ត្រូវដាក់ដោយផ្ទាល់ទៅកាន់តុលាការដែលមានសមត្ថកិច្ចតែម្ដងក៏បាន។ ជាមួយគ្នានេះដែរ ប្រសិនបើភាគីណាម្ខាង បានសម្រេចចិត្តដាក់ពាក្យសុំលែងលះមកកាន់ក្រុមប្រឹក្សាឃុំ-សង្កាត់ នៃលំនៅឋានរបស់ប្ដី ឬប្រពន្ធ ដូច្នេះក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវដើរតួនាទីជាកិច្ចបឋមសិន គឺជាអ្នកផ្សះផ្សាគូភាគីជាមុនសិន។ យ៉ាងណាមិញ ការផ្សះផ្សាបែបនេះ គឺក្នុងគោលបំណងដើម្បីឱ្យគូភាគីបានត្រូវរ៉ូវគ្នាវិញ ហើយធ្វើការសះជានឹងគ្នាដើម្បីបន្តការរស់នៅក្នុងជីវិតជាប្ដីប្រពន្ធសារជាថ្មីម្ដងទៀត។ ក្នុងករណីនេះ ក្រុមប្រឹក្សាឃុំ-សង្កាត់ មានរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ដោយគិតចាប់ពីថ្ងៃដែលទទួលបានពាក្យសុំលែងលះ គឺត្រូវធ្វើយ៉ាងណាដែលអាចជាវិធីក្នុងការផ្សះផ្សាឱ្យគូភាគីសះជានឹងគ្នាបានវិញ។[41] បន្ទាប់ពីក្រុមប្រឹក្សាឃុំ-សង្កាត់ បានធ្វើការផ្សះផ្សាហើយនោះ បើគូភាគីយល់ព្រមសះជានឹងគ្នាវិញ នោះក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវតែកត់ត្រាពីអ្វីដែលគូភាគីបានសះជានឹងគ្នា ដោយទុកធ្វើជាកំណត់ហេតុ ដើម្បីធ្វើកិច្ចសន្យាសះជាដល់ភាគីទាំងពីរក្នុងការសម្រេចចិត្តទទួលយកការផ្សះផ្សានេះ។

[40] ច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០, មាត្រា៧ (១)។
[41] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៨២ (២)។

### ២.២.២. តុលាការរាជធានី-ខេត្ត

ជាការពិតណាស់ សមត្ថកិច្ចក្នុងការជម្រះក្តីលើរឿងក្តីលែងលះ គឺត្រូវបានកំណត់ដោយច្បាប់។ ហើយនៅក្នុងករណីការលែងលះដោយការព្រមព្រៀង មិនមែនគ្រប់តុលាការទាំងអស់សុទ្ធតែមានសមត្ថកិច្ចក្នុងការដោះស្រាយលើរឿងក្តីលែងលះនោះទេ ពោលគឺរឿងក្តីប្រភេទនេះ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខរបស់តុលាការ។[42] ហេតុនេះ ចំពោះសមត្ថកិច្ចផ្តាច់មុខលើរឿងក្តីលែងលះដោយការព្រមព្រៀង គឺជាតុលាការនៃលំនៅឋានរបស់ភាគីប្តី ឬប្រពន្ធ។[43] ជារួមមក តុលាការដែលមានសមត្ថកិច្ចលើរឿងក្តីលែងលះដោយការព្រមព្រៀង គឺជាសមត្ថកិច្ចរបស់តុលាការរាជធានី-ខេត្តនៃលំនៅឋានរបស់ប្តី ឬប្រពន្ធ ដែលជាអ្នកដាក់ពាក្យសុំលែងលះដោយការព្រមព្រៀងនោះ។ ដូចនេះ មុនដាក់ពាក្យសុំទៅតុលាការលែងលះដោយការព្រមព្រៀង ភាគីក៏ត្រូវបំពេញកាតព្វកិច្ចមួយចំនួនដែលជាប់ពាក់ព័ន្ធទៅនឹងលំហូរនៃនីតិវិធីរដ្ឋប្បវេណីផងដែរ។

## ២.៣. នីតិវិធីដែលត្រូវបំពេញដោយភាគី

ចំពោះរឿងក្តីនៃការលែងលះដោយការព្រមព្រៀង គឺមានតែភាគីប្តី ឬប្រពន្ធទេ ដែលជាអ្នកផ្តើមដំណើរការនីតិវិធីក្នុងការដោះស្រាយជាដំបូងតាមរយៈការដាក់ពាក្យសុំទៅតុលាការ ហើយមិនមែនជារឿងក្តីដែលតុលាការអាចចាប់ផ្តើមនីតិវិធីបណ្តឹងដោយឆន្ទានុសិទ្ធិឡើយ។ នៅត្រង់ចំណុចនេះចង់មានន័យថា កម្មវត្ថុនៃការសម្រេច និងការចេញដីកាសម្រេច គឺអាស្រ័យលើភាគីជាអ្នកកំណត់នៅក្នុងពាក្យសុំ ហើយតុលាការអាចចាប់ផ្តើមជម្រះក្តីបានលុះត្រាតែបានទទួលនូវពាក្យសុំជាមុនសិន។ ហើយចំពោះសមត្ថកិច្ចផ្តាច់មុខនៅក្នុងរឿងក្តីលែងលះដោយការព្រមព្រៀង គឺជាតុលាការនៃលំនៅឋានរបស់ប្តីប្រពន្ធ។ ចំពោះនីតិវិធីដែលត្រូវបំពេញដោយភាគីនេះ ក៏នៅមានចំណុចដែលយើងខ្ញុំនឹងយកមកបកស្រាយបន្ថែមផងដែរគឺ (២.៣.១.) ការស្នើសុំការលែងលះ ហើយនៅក្នុងចំណុចមួយនេះ ក៏នៅមានចំណុចតូចៗមួយចំនួនដែលយើងខ្ញុំនឹងយកមកបកស្រាយនៅចំណុចខាងក្រោមជាបន្តបន្ទាប់ផងដែរ។

### ២.៣.១. ការស្នើសុំការលែងលះ

ចំពោះការស្នើសុំការលែងលះដោយការព្រមព្រៀង ចាប់ផ្តើមនៅពេលដែលភាគីសម្រេចដាក់ពាក្យស្នើសុំទៅតុលាការ ដោយអនុលោមតាមច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០។ ហេតុនេះ ដើម្បីអាចដាក់ពាក្យស្នើសុំទៅតុលាការបាន លុះត្រាតែគូភាគីបានព្រមព្រៀងគ្នាដោយធ្វើកិច្ចព្រមព្រៀងលែងលះជាមួយគ្នា និងមានផ្តិតស្នាមមេដៃរបស់គូភាគី ព្រមទាំងមានឯកសារភ្ជាប់មកជាមួយផងដែរ ទើបអាចដាក់

---

[42] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/0៧១០/0១៣, ១០ កក្កដា ២០១០, មាត្រា៤។

[43] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/0៧១០/0១៣, ១០ កក្កដា ២០១០, មាត្រា៤ តារាងឧបសម្ព័ន្ធផ្នែកទី៤ លេខរៀងទី៥

ពាក្យសុំលែងលះដោយការព្រមព្រៀងបាន។ ចំពោះឯកសារដែលត្រូវភ្ជាប់ជាមួយនឹងកិច្ចព្រមព្រៀងលែងលះមានដូចជា អត្តសញ្ញាណប័ណ្ណគូភាគី, សំបុត្រអាពាហ៍ពិពាហ៍, សំបុត្របញ្ជាក់កំណើតកូន, សៀវភៅស្នាក់នៅ ជាអាទិ៍។

### ២.៣.២. ពាក្យសុំលែងលះ

ជាទូទៅពាក្យសុំលែងលះ ត្រូវធ្វើឡើងដោយសហព័ទ្ធណា ដែលមានឆន្ទៈពិតប្រាកដក្នុងការព្រមព្រៀងលែងលះគ្នា។ ក្នុងករណីដែលមានការព្រមព្រៀងលែងលះគ្នាបែបនេះ សហព័ទ្ធដែលមានបំណងចង់លែងលះនោះ អាចធ្វើការលែងលះគ្នាបានតាមរយៈពីរទម្រង់គឺ (២.៣.២.១.) ការដាក់ពាក្យសុំដែលធ្វើឡើងជាលាយលក្ខណ៍អក្សរ និង(២.៣.២.២.) ការដាក់ពាក្យសុំដែលធ្វើឡើងដោយផ្ទាល់មាត់។[44]

#### ២.៣.២.១. ពាក្យសុំលែងលះដោយលាយលក្ខណ៍អក្សរ

ដោយស្របតាមច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០ ចំពោះពាក្យសុំលែងលះដោយការព្រមព្រៀង អាចធ្វើជាលាយលក្ខណ៍អក្សរបានលុះត្រាតែ អ្នកដាក់ពាក្យសុំត្រូវសរសេរទៅតាមទម្រង់ដែលកំណត់ដោយច្បាប់ ហើយនៅក្នុងពាក្យសុំត្រូវសរសេរបញ្ជាក់នូវ ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំឱ្យបានច្បាស់លាស់ ហើយបើក្នុងករណីដែលអ្នកដាក់ពាក្យសុំមាន អ្នកតំណាងនោះនៅក្នុងពាក្យសុំក៏ត្រូវសរសេរបញ្ជាក់ពីអាសយដ្ឋានរបស់អ្នកតំណាងនោះផងដែរ។ ចំពោះចំណុចបន្ទាប់ត្រូវសរសេរនោះគឺ ខ្លឹមសារនៃដីកាសម្រេច ឬ សកម្មភាពផ្សេងទៀតរបស់តុលាការដែលអ្នកដាក់ពាក្យសុំទាមទារត្រង់ចំណុចនេះ ប្រសិនបើអ្នកដាក់ពាក្យសុំលែងលះមកតុលាការ គឺប្រាកដណាស់ច្បាស់ជាសុំទាមទារឱ្យតុលាការចេញដីកាសម្រេចលែងលះ, ការបែងចែកទ្រព្យសម្បត្តិ, ការបែងចែកអំណាចមេបាលើកូន, បន្ទុកសាហ៊ុយចំណាយសម្រាប់ចិញ្ចឹមបីបាច់ថែរក្សាកូន ជាអាទិ៍។ ហើយចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំចុងក្រោយនោះគឺ អង្គហេតុដែលជាមូលហេតុនៃការទាមទារ នៅក្នុងចំណុចនេះ ត្រូវសរសេរបញ្ជាក់ពីអង្គហេតុចម្បងដែលជាមូលហេតុសម្រាប់គាំទ្រដល់ខ្លឹមសារនៃដីកាសម្រេច ដែលអ្នកដាក់ពាក្យសុំបានទាមទារ។[45] ជាមួយគ្នានេះដែរ បើក្នុងករណីដែលអ្នកដាក់ពាក្យសុំ មានឯកសារជាភស្តុតាង នោះអ្នកដាក់ពាក្យសុំត្រូវភ្ជាប់ឯកសារទាំងនោះជាឯកសារដើម ឬ ឯកសារថតចម្លង ដោយភ្ជាប់ជាមួយនឹងពាក្យសុំលែងលះដាក់ជូនមកតុលាការ។[46]

[44] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០, មាត្រា៤ (១) តារាងឧបសម្ព័ន្ធផ្នែកទី៤ លេខរៀងទី៥

[45] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០, មាត្រា២៦ (២)។

[46] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០, មាត្រា២៦ (៤)។

### ២.៣.២.១. ពាក្យសុំលែងលះដោយផ្ទាល់មាត់

ចំពោះពាក្យសុំលែងលះដោយផ្ទាល់មាត់ ភាគច្រើនទម្រង់នេះត្រូវបានប្រើប្រាស់ដោយប្រជាពលរដ្ឋដែលមិនសូវយល់ដឹងពីច្បាប់ឱ្យកាន់តែស៊ីជម្រៅ និងមិនមានលទ្ធភាពក្នុងការប្រគល់សិទ្ធិជូនមេធាវីដើម្បីធ្វើជាមេធាវីតំណាងដោយអាណត្តិ។ យ៉ាងណាមិញ ដើម្បីដាក់ពាក្យសុំដោយផ្ទាល់មាត់ អ្នកដាក់ពាក្យសុំត្រូវធ្វើសេចក្តីថ្លែងការណ៍នូវចំណុចនីមួយៗ នៅចំពោះមុខក្រឡាបញ្ជី ហើយក្នុងករណីនេះ ក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុ និងចុះហត្ថលេខា ហើយកំណត់ហេតុនេះហើយត្រូវបានចាត់ទុកថាជាពាក្យសុំ។[47]

### ២.៣.៣. ការដាក់ពាក្យសុំលែងលះ និងការបង់ពន្ធ

ចំពោះការដាក់ពាក្យសុំលែងលះ អ្នកដាក់ពាក្យសុំលែងលះ ត្រូវដាក់ពាក្យសុំនោះតុលាការនៃលំនៅឋានរបស់ប្តី ឬប្រពន្ធ ដែលមានសមត្ថកិច្ចដោះស្រាយលើរឿងក្តីលែងលះដោយខ្លួនឯងផ្ទាល់បាន ឬក្នុងករណីដែលអ្នកដាក់ពាក្យសុំ មានមេធាវីតំណាងដំណាងដោយអាណត្តិដែលបានជ្រើសហើយនោះ មេធាវីនឹងជាអ្នកយកពាក្យសុំនោះដាក់ចូលដោយផ្ទាល់ទៅតុលាការក៏បានដែរ។[48] បន្ទាប់ពីពាក្យសុំលែងលះ បានដាក់ចូលរដ្ឋបាលតុលាការរាជធានី-ខេត្តហើយនោះ រដ្ឋបាលនឹងបញ្ជូនពាក្យសុំនេះទៅក្រឡាបញ្ជី ហើយក្រឡាបញ្ជីមាន តួនាទីជាអ្នកពិនិត្យលើពាក្យសុំនោះ ថាស្របតាមបញ្ញត្តិមាត្រា២៦នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ដែរឬទេ? បើពិនិត្យទៅឃើញថាត្រឹមត្រូវហើយនោះ ក្រឡាបញ្ជីត្រូវបញ្ជូនរឿងក្តីនេះទៅចៅក្រមដើម្បីដំណើរការនីតិវិធីបន្ត។ ប៉ុន្តែបើពិនិត្យទៅឃើញថាមិនត្រឹមត្រូវទេនោះ ក្រឡាបញ្ជីត្រូវរាយការណ៍យ៉ាងប្រញាប់ជូនទៅចៅក្រម ដើម្បីឱ្យចៅក្រមធ្វើការសម្រេចថា ឱ្យអ្នកដាក់ពាក្យសុំនោះធ្វើការកែតម្រូវ ឬចៅក្រមសម្រេចលើកចោលពាក្យសុំនោះតាមរយៈដីកាសម្រេច។

ជាមួយគ្នានេះដែរ ចំពោះការដាក់ពាក្យសុំលែងលះ អ្នកដាក់ពាក្យសុំត្រូវបង់ប្រាក់នៃការបង់ពន្ធដាក់ពាក្យសុំចំនួន ៥.០០០ (ប្រាំពាន់) រៀល ។[49] ក្នុងករណីដែល អ្នកដាក់ពាក្យសុំមិនបានបង់ពន្ធលើពាក្យសុំលែងលះទេនោះ តុលាការនឹងលើកពាក្យសុំនោះចោលដោយដីកាសម្រេច។[50] បន្ថែមលើសពីនេះ បន្ទាប់ពីចំណាយលើការបង់ពន្ធដាក់ពាក្យសុំនេះហើយ អ្នកដាក់ពាក្យសុំត្រូវចំណាយផ្សេងៗទៀត ប្រសិនបើស្ថានភាពនៃរឿងក្តីបានតម្រូវដូចជា ការបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធផងដែរ។

[47] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០, មាត្រា២៦ (៣)។
[48] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០, មាត្រា១៥។
[49] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០, មាត្រា២២ (១)។
[50] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០, មាត្រា២២ (៦)។

## ២.៤. នីតិវិធីដោះស្រាយការលែងលះដោយការព្រមព្រៀង

នីតិវិធីលែងលះដោយការព្រមព្រៀងអាចចាប់ផ្តើម នៅពេលដែលពាក្យសុំបានដាក់ជូនតុលាការរួចរាល់ ពេលនោះរដ្ឋបាលនឹងបញ្ជូនពាក្យសុំនោះទៅក្រឡាបញ្ជីដែលត្រូវទទួលបន្ទុកក្នុងរឿងក្តីនេះ។ ជាមួយគ្នានេះដែរ ពាក្យសុំនោះ ត្រូវបានត្រួតពិនិត្យដោយក្រឡាបញ្ជី បើពិនិត្យឃើញថាត្រឹមត្រូវតាមកំណត់ច្បាប់ហើយនោះតុលាការ នឹងចាត់ចំណាត់ការទៅតាមនីតិវិធីជាបន្តបន្ទាប់ដូចជា៖ (២.៤.១.) ការកោះហៅគូភាគី, (២.៤.២.) ការផ្សះផ្សា, (២.៤.៣.), នីតិវិធីនៃការសាកសួរ និង(២.៤.៤.) ការសម្រេចលើពាក្យស្នើសុំ។

### ២.៤.១. ការកោះហៅគូភាគី

ចំពោះនីតិវិធីកោះហៅគូភាគី បន្ទាប់ពីក្រឡាបញ្ជីបានត្រួតពិនិត្យទៅលើពាក្យសុំឃើញថាត្រឹមត្រូវ ក្រឡាបញ្ជីនឹងចុះសំណុំរឿងនោះចូលទៅក្នុងបញ្ជី រួចបញ្ជូនសំណុំរឿងនេះទៅកាន់ចៅក្រមដែលត្រូវទទួលបន្ទុក ក្នុងរឿងនេះដើម្បីធ្វើការបើកការជំនុំជម្រះនូវនីតិវិធីជាបន្តបន្ទាប់ទៀត។ ចំពោះនីតិវិធីបន្ទាប់ គឺតុលាការអាច កោះហៅអ្នកដាក់ពាក្យសុំលែងលះ ភាគីម្ខាងទៀត ឬ ជាជនផ្សេងទៀតដែលតុលាការយល់ឃើញថាចាំបាច់ ដោយកំណត់កាលបរិច្ឆេទ។[51] ដោយហេតុថាបានជា តុលាការកោះហៅភាគីឱ្យចូលមកនេះគឺ ដើម្បីឱ្យភាគី ចូលមកបំភ្លឺឱ្យកាន់តែច្បាស់ អំពីអង្គហេតុ ដែលបានដាក់មកតុលាការ។

### ២.៤.២. ការផ្សះផ្សា

ការផ្សះផ្សា គឺជាវិធានការចាត់ចែងដោយតុលាការ ដើម្បីសម្របសម្រួល បញ្ចុះបញ្ចូលឱ្យសហព័ទ្ធ ព្រមព្រៀងសះជានឹងគ្នាវិញ។ នៅក្នុងករណីដែលភាគីយកពាក្យសុំលែងលះទៅដាក់នៅក្រុមប្រឹក្សាឃុំ-សង្កាត់ គឺបានឆ្លងកាត់នូវនីតិវិធីផ្សះផ្សាដូចបានជម្រាបជូននៅខាងលើរួចហើយ។ ប៉ុន្តែទោះបីជាបានឆ្លងកាត់ ឬមិនបាន ឆ្លងកាត់ការផ្សះផ្សានៅដំណាក់កាលក្រុមប្រឹក្សាឃុំ-សង្កាត់ក៏ដោយ តុលាការត្រូវតែសាកល្បងផ្សះផ្សាជាមុនសិន មុននឹងឈានទៅដល់នីតិវិធីបន្តបន្ទាប់ទៀត។[52] ហេតុនេះ ទោះបីជារឿងក្តីនៃការលែងលះដោយការព្រមព្រៀង ជាការសម្តែងឆន្ទៈរបស់ភាគីក៏ដោយ ក៏ចៅក្រមតែងតែព្យាយាមផ្សះផ្សាភាគីទាំងពីរឱ្យត្រូវរ៉ូវនឹងគ្នាវិញដែរ។ ហើយបើតុលាការពិនិត្យឃើញថា ការលែងលះនោះអាចបង្កជាផលអវិជ្ជមានខ្លាំងចំពោះកូន ហើយភាគីនៅមាន មនោសញ្ចេតនាជាមួយគ្នានៅឡើយ នោះការផ្សះផ្សាធ្វើឡើងដើម្បីឱ្យភាគីព្រមសះជានឹងគ្នាវិញ ហើយយល់ព្រម ដកពាក្យសុំលែងលះ ហើយព្រមទៅរួមរស់នៅជាមួយគ្នាជាប្តីប្រពន្ធនឹងគ្នាម្តងទៀត។

[51] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០, មាត្រា២៩ (១)។

[52] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៨៤ (១)។

### ២.៤.៣. នីតិវិធីនៃការសាកសួរ

ជាក់ស្តែងបើយើងក្រឡេកមកមើលនៅក្នុងនីតិវិធីនៃការសាកសួរវិញ គឺក្រៅពីបានផ្តល់ឱ្យភាគីបញ្ជាក់ឱ្យកាន់តែច្បាស់នូវឆន្ទៈព្រមព្រៀងរបស់ខ្លួនលើគ្រប់បញ្ហាដែលបានទាមទារ ហើយតុលាការអាចធ្វើការស្រាវជ្រាវដោយឆន្ទានុសិទ្ធិ ឬធ្វើការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិទៀតផង។[53] ហេតុនេះចំពោះការដឹកនាំនីតិវិធីនេះ តុលាការមិនឈរលើគោលការណ៍នៃសិទ្ធិចាត់ចែងរបស់ភាគីដូចការអនុវត្តក្នុងនីតិវិធីបណ្តឹងធម្មតាឡើយ ពោលគឺតុលាការអាចលើកយកអង្គហេតុដែលភាគីមិនបានអះអាងមកធ្វើជាមូលដ្ឋាននៃដីកាសម្រេចបាន។

### ២.៤.៤. ការសម្រេចលើពាក្យស្នើសុំ

នៅក្នុងពាក្យស្នើសុំលែងលះដោយការព្រមព្រៀង គឺមានន័យថាជាការចេញសេចក្តីសម្រេចដោយតុលាការ លើពាក្យសុំលែងលះដែលភាគីបានដាក់ជូនតុលាការ ហើយពាក្យសុំនេះទៀតសោតត្រូវសម្រេចចេញដោយដីកាសម្រេចរបស់តុលាការចំពោះការស្នើសុំទាំងឡាយណាដែលភាគីបានដាក់ជូនតុលាការ។

### ២.៤.៥. ការចេញដីកាសម្រេច

បន្ទាប់ពីបានឆ្លងកាត់នូវនីតិវិធីផ្សះផ្សា និងនីតិវិធីនៃការសាកសួររួចមក គូភាគីនៅតែមិនសះជានឹងគ្នាវិញនោះទេ។ ហេតុនេះ តុលាការអាចសម្រេចសេចក្តី ដោយការចេញដីកាសម្រេចចំពោះពាក្យស្នើសុំលែងលះដោយការព្រមព្រៀងរបស់គូភាគីបាន។[54] ភ្ជាប់ជាមួយគ្នានេះដែរ តុលាការត្រូវចេញដីកាសម្រេច ដោយធ្វើឡើងក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ ហើយត្រូវសរសេរនូវសំអាងហេតុ ដោយមាននូវសេចក្តីសម្រេចបញ្ចប់ និងមានចុះហត្ថលេខារបស់ចៅក្រមលើសេចក្តីសម្រេចផងដែរ។[55] ជាមួយគ្នានេះដែរ ការជូនដំណឹងអំពីដីកាសម្រេចទៅដល់ភាគីដែលបានធ្វើការដាក់ពាក្យសុំនោះ ត្រូវធ្វើឡើងតាមរយៈបញ្ជូន ឬការផ្ញើជូនជាឯកសារថតចម្លងយថាភូតនៃដីកានោះ។[56] បន្ថែមលើសនេះទៀត ដីកាសម្រេចនេះ នឹងមានតម្លៃដូចគ្នាទៅនឹងសាលក្រមស្ថាពរដែរ។ បន្ទាប់ពីបានចេញដីកាសម្រេចរួចរាល់ហើយ ភាគីដែលបានទទួលដីកាសម្រេចចង់ប្តឹងជំទាស់ អាចប្តឹងជំទាស់បានក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ដោយគិតចាប់ពីថ្ងៃបានទទួលការជូនដំណឹងអំពីដីកាសម្រេចនោះ។[57]

[53] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០, មាត្រា២៧។
[54] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០, មាត្រា២៨ (១)។
[55] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០, មាត្រា៣៥។
[56] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០, មាត្រា៣៦។
[57] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០, មាត្រា៤០។

# ជំពូកទី៣
# ការលែងលះដោយ
# គ្មានការព្រមព្រៀង

# ជំពូកទី៣
# ការលែងលះដោយគ្មានការព្រមព្រៀង

ការលែងលះដោយគ្មានការព្រមព្រៀង ឬការលែងលះតាមពាក្យបណ្តឹង គឺជាការផ្តាច់នូវចំណង អាពាហ៍ពិពាហ៍ ដោយភាគីម្ខាងមិនបានធ្វើការព្រមព្រៀងគ្នាអំពីសិទ្ធិ និងកាតព្វកិច្ចផ្សេងៗក្រោយពេលលែងលះ។ ការលែងលះដោយគ្មានការព្រមព្រៀង ត្រូវអនុលោមទៅតាមច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។ ការលែងលះដោយគ្មានការព្រមព្រៀង ត្រូវឆ្លងកាត់នូវដំណាក់កាលជាច្រើន ដែលធ្វើឱ្យការលែងលះដោយគ្មានការព្រមព្រៀងមានភាពស្មុគស្មាញ ក៏ដូចជាត្រូវប្រើរយៈពេលយូរជាងការលែងលះដោយការព្រមព្រៀង។ ដើម្បីយល់ដឹង និងសិក្សាអំពីការលែងលះដោយគ្មានការព្រមព្រៀង ឱ្យបានច្បាស់លាស់ គប្បីយល់នូវ (៣.១.) ទិដ្ឋភាពទូទៅនៃការលែងលះដោយគ្មានការព្រមព្រៀង, (៣.២.) អាជ្ញាធរមានសមត្ថកិច្ច, (៣.៣.) នីតិវិធីដែលត្រូវបំពេញដោយភាគី និង(៣.៤.) នីតិវិធីជំនុំជម្រះលើបណ្តឹងលែងលះជាមុនសិន។

## ៣.១. ទិដ្ឋភាពទូទៅនៃការលែងលះដោយគ្មានការព្រមព្រៀង

ការលែងលះដែលមានមូលហេតុដូចមានចែងនៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ គឺជាការលែងលះដោយគ្មានការព្រមព្រៀង មានន័យថាភាគីម្ខាង(ប្តី-ប្រពន្ធ)នៃអាពាហ៍ពិពាហ៍ មិនមានឆន្ទៈក្នុងការលែងលះ តែភាគីម្ខាងទៀតមិនអាចរួមរស់ជាមួយគ្នាទៀតបាន ដោយយោងទៅលើមូលហេតុនៃការលែងលះ ដូចជាមានអំពើផិតក្បត់ ទៅលើសហព័ទ្ធ, ការបោះបង់សហព័ទ្ធចោល ដោយគ្មានមូលហេតុត្រឹមត្រូវ, មិនដឹងច្បាស់ថាសហព័ទ្ធស្លាប់ ឬរស់អស់រយៈពេលជាង ១ (មួយ) ឆ្នាំ, សហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់ អស់រយៈពេលជាង ១ (មួយ) ឆ្នាំ ដែលផ្ទុយនឹងគោលបំណងអាពាហ៍ពិពាហ៍ និងករណីផ្សេងទៀតដែលនាំឱ្យទំនាក់ទំនងត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន។

ដូច្នេះភាគីម្ខាង (ប្តី-ប្រពន្ធ) នៃអាពាហ៍ពិពាហ៍ អាចដាក់ពាក្យបណ្តឹងទាមទារលែងលះគ្នា ទៅតុលាការរាជធានី-ខេត្ត ហើយបើតុលាការរកឃើញថាមានមូលហេតុ និងភស្តុតាងបញ្ជាក់យ៉ាងច្បាស់លាស់ថាភាគីទាំងពីរពិតជាមិនអាចរួមរស់នៅជាមួយគ្នាជាប្តីប្រពន្ធទៀតបាន នោះតុលាការត្រូវសម្រេចឱ្យភាគីលែងលះគ្នាតាមរយៈអំណាច " សាលក្រម " នេះបើយោងតាមច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។

បើទោះបីជាពាក្យបណ្តឹងទាមទារការលែងលះរបស់ភាគី មានមូលហេតុដូចមានរៀបរាប់ខាងលើក៏ដោយ ប៉ុន្តែប្រសិន បើតុលាការយល់ឃើញថាការលែងលះនោះ បណ្តាលឱ្យការទ្រទ្រង់ជីវភាពរបស់ប្តី-ប្រពន្ធ ឬកូនក្រលំបាក ឬឈឺចាប់ដែលពុំអាចទ្រាំទ្របាន ឬដោយសារតែការទាមទារនោះផ្ទុយនឹងភាពសុចរិត នោះតុលាការអាចច្រានចោល ការទាមទារលែងលះគ្នានោះបាន ដោយពិចារណាលើស្ថានភាពជាក់ស្តែង ឬដោយឆន្ទានុសិទ្ធិ។

ហេតុដូច្នេះការលែងលះ ឬការរំលាយចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ ដែលប្តី-ប្រពន្ធបានចុះសំបុត្រអាពាហ៍ពិពាហ៍ ត្រូវតែធ្វើឡើងតាមផ្លូវតុលាការ។ ភាគីប្តី ឬប្រពន្ធ មិនអាចបង្កើតកិច្ចព្រមព្រៀងលែងលះក្រៅប្រព័ន្ធតុលាការ ឬគ្រាន់តែដាក់លិខិតជូនដំណឹងទៅក្រុមប្រឹក្សាឃុំ-សង្កាត់បានទេ។ ប្រសិនបើមិនបានឆ្លងកាត់ការសម្រេចសេចក្តីតាមរយៈសេចក្តីសម្រេចរបស់តុលាការនោះទេ ចំណងអាពាហ៍ពិពាហ៍របស់ពួកគេត្រូវទុកជាបានការដដែល។

## ៣.២. អាជ្ញាធរមានសមត្ថកិច្ច

ចំពោះអាជ្ញាធរមានសមត្ថកិច្ចក្នុងរឿងក្តីលែងលះដោយគ្មានការព្រមព្រៀងមានពីរគឺ (៣.២.១.) ក្រុមប្រឹក្សាឃុំ-សង្កាត់ និង(៣.២.២.) តុលាការរាជធានី-ខេត្ត។

### ៣.២.១. ក្រុមប្រឹក្សាឃុំ-សង្កាត់

ក្រុមប្រឹក្សាឃុំ-សង្កាត់មានតួនាទីចម្បងគឺ ធ្វើការផ្សះផ្សា និងសម្របសម្រួលក្នុងនីតិវិធីលែងលះដោយគ្មានការព្រមព្រៀង។ ក្រុមប្រឹក្សាឃុំ-សង្កាត់ពុំមានអំណាចក្នុងការសម្រេចសេចក្តីលើបណ្តឹងលែងលះនោះទេ ពោលគឺពុំមានអំណាចសម្រេចឱ្យមានការលែងលះគ្នា ឬសម្រេចអំពីការបែងចែកទ្រព្យសម្បត្តិរួមប្តីប្រពន្ធ ឬសម្រេចអំពីអ្នកមានសិទ្ធអំណាចមេបាលើកូនឡើយ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយនៅពេលភាគីមានបំណងចង់លែងលះ ភាគីត្រូវដាក់ពាក្យសុំនោះទៅក្រុមប្រឹក្សាឃុំ-សង្កាត់នៅលំនៅឋានប្តី ឬប្រពន្ធឱ្យដោះស្រាយមុនពេលដាក់ទៅតុលាការ។ ក្នុងករណីនេះ ក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវធ្វើការផ្សះផ្សាឱ្យភាគីនៃបណ្តឹង ដើម្បីឱ្យភាគីសះជាគ្នាបានក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីបានទទួលពាក្យសុំនោះ។ ប្រសិនបើក្រុមប្រឹក្សាឃុំ-សង្កាត់មិនអាចផ្សះផ្សាឱ្យភាគីសះជាគ្នាបានទេ ត្រូវចាត់ទុកថាមានពាក្យបណ្តឹងលែងលះគ្នា ហើយក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវបញ្ជូនពាក្យបណ្តឹងលែងលះនោះទៅតុលាការជាបន្ទាន់។[58] មូលហេតុនៃការផ្សះផ្សាគឺ ដោយសារតែការលែងលះអាចធ្វើឱ្យបាត់បង់ផលប្រយោជន៍ជាច្រើនដូចជា ពេលវេលា ទ្រព្យសម្បត្តិ និងសុភមង្គលជាអាទិ៍។ ប៉ុន្តែក្នុងករណីដែលការផ្សះផ្សារបស់ក្រុមប្រឹក្សាឃុំ-សង្កាត់បានសម្រេច មានន័យថាភាគីព្រមព្រៀងរួមរស់នៅជាមួយគ្នាវិញ នោះក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវធ្វើកំណត់ហេតុ ក៏ដូចជាធ្វើកិច្ចសន្យាសះជាដល់ភាគី។

### ៣.២.២. តុលាការរាជធានី-ខេត្ត

នៅក្នុងនីតិវិធីបណ្តឹងលែងលះ សមត្ថកិច្ចសាលាជម្រះក្តីពិសេសលើរឿងក្តីលែងលះគ្នា ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខ របស់តុលាការរាជធានី-ខេត្ត ដែលមានសមត្ថកិច្ចនៅលំនៅឋានរបស់ភាគីនៃទំនាក់ទំនងឋានៈ

[58] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៨២ (២)។

បុគ្គលដែលពាក់ព័ន្ធនឹងបណ្ដឹងនោះ។[59] ក្នុងករណីនេះមានន័យថា នៅពេលដែលភាគីណា(ប្ដី ឬប្រពន្ធ) ដែលមានបំណងចង់រំលាយអាពាហ៍ពិពាហ៍ ភាគីនោះត្រូវដាក់ពាក្យបណ្ដឹងទៅកាន់តុលាការរាជធានី-ខេត្តនៃលំនៅឋានរបស់ប្ដី ឬប្រពន្ធ ឬលំនៅឋានរបស់ប្ដីប្រពន្ធ។ នៅក្នុងករណីដែលពាក្យបណ្ដឹងលែងលះមិនបានឆ្លងកាត់ការផ្សះផ្សានៅក្រុមប្រឹក្សាឃុំ-សង្កាត់ក៏ដោយ ក៏ភាគីនៃបណ្ដឹងអាចដាក់ពាក្យបណ្ដឹងលែងលះរបស់ខ្លួនទៅកាន់តុលាការមានសមត្ថកិច្ចដោយផ្ទាល់ផងដែរ។ នៅពេលដែលទទួលពាក្យបណ្ដឹងលែងលះ តុលាការត្រូវធ្វើចំណាត់ការលើរឿងក្ដីស្របតាមនីតិវិធី។

### ៣.៣. នីតិវិធីដែលត្រូវបំពេញដោយភាគី

នៅក្នុងរឿងក្ដីនៃការលែងលះដោយគ្មានការព្រមព្រៀងមានតែភាគីនៃបណ្ដឹង (ប្ដី ឬប្រពន្ធ) ទេ ដែលជាអ្នកផ្ដើមដំណើរការនីតិវិធីក្នុងការដាក់ពាក្យបណ្ដឹងទៅតុលាការ មិនមែនជារឿងក្ដីដែលតុលាការអាចចាប់ផ្ដើមនីតិវិធីបណ្ដឹងដោយឆន្ទានុសិទ្ធិឡើយ។ មានន័យថា កម្មវត្ថុនៃការសម្រេច និងចេញសាលក្រមគឺ ភាគីជាអ្នកកំណត់នៅក្នុងពាក្យបណ្ដឹង ហើយតុលាការអាចចាប់ផ្ដើមជម្រះក្ដីបានទាល់តែទទួលបានពាក្យបណ្ដឹងជាមុនសិន។ ហេតុនេះក្នុងនីតិវិធីលែងលះដោយគ្មានការព្រមព្រៀង ភាគីត្រូវបំពេញនូវកាតព្វកិច្ចមួយចំនួនក្នុងការចូលរួមក្នុងដំណើរនីតិវិធី មានដូចជា៖ (៣.៣.១.) ការធ្វើបណ្ដឹងលែងលះ (៣.៣.២.) ឯកសារភ្ជាប់ និងភស្តុតាងទៅតុលាការផងដែរ។

#### ៣.៣.១. ការធ្វើបណ្ដឹងលែងលះ

បណ្ដឹងលែងលះកើតឡើងនៅពេលដែលភាគីដែលមានបំណងចង់រំលាយអាពាហ៍ពិពាហ៍ដាក់ពាក្យបណ្ដឹងទៅយកទៅដាក់នៅតុលាការដែលមានសមត្ថកិច្ច ដោយអនុលោមតាមច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១០ និងក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។ ប៉ុន្តែមុននឹងដាក់ពាក្យបណ្ដឹងទៅតុលាការមានសមត្ថកិច្ច ភាគីគប្បីត្រូវតែសរសេរពាក្យបណ្ដឹងនោះ ជាលាយលក្ខណ៍អក្សរ ក៏ដូចជាភ្ជាប់ជាមួយនូវឯកសារ និងភស្តុតាងជាមុនសិន។

##### ៣.៣.១.១. និយមន័យនៃបណ្ដឹង

បណ្ដឹង សំដៅលើសកម្មភាពទាមទារមួយ ដែលធ្វើឡើងដោយដើមចោទចំពោះចុងចម្លើយទៅកាន់តុលាការនៃការជំនុំជម្រះក្ដី ដោយបានអះអាងពីអត្ថិភាព ឬទំនាក់ទំនងគតិយុត្តតាមផ្លូវច្បាប់ ហើយទាមទារឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារកំណត់មួយ ដោយផ្អែកទៅលើការអះអាងទាំងនេះ តាមរយៈពេលការដាក់ពាក្យបណ្ដឹង។ បណ្ដឹងរដ្ឋប្បវេណី អាចត្រូវបានបែងចែកជាច្រើនប្រភេទទៅតាមបទដ្ឋាននីមួយៗ ប៉ុន្តែ

[59] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១០ (១)។

វិធីបែងចែក ដែលជាគោលគំនិតនៃក្រមនីតិវិធីរដ្ឋប្បវេណី គឺការបែងចែកដោយយកប្រភេទនៃការទាមទារតាមផ្លូវបណ្ដឹង និងខ្លឹមសារនៃការទាមទារ ធ្វើជាមាត្រដ្ឋានក្នុងការកំណត់ នាំឱ្យប្រភេទនៃបណ្ដឹងត្រូវបានបែងចែកជាបីគឺ បណ្ដឹងទាមទារឱ្យផ្ដល់តាវការលិក បណ្ដឹងទាមទារឱ្យបញ្ជាក់ និងបណ្ដឹងទាមទារឱ្យបង្កើត ប្ដូរ ឬរំលត់ទំនាក់ទំនងគតិយុត្ត។ សម្រាប់បណ្ដឹងនៅក្នុងរឿងលែងលះដោយគ្មានការព្រមព្រៀង ជាប្រភេទបណ្ដឹងទាមទារឱ្យបង្កើត ប្ដូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត មានន័យថា ជាបណ្ដឹងទាមទារ ឱ្យតុលាការចេញសាលក្រមបង្កើតទំនាក់ទំនងគតិតយុត្តថ្មីដោយផ្អែកលើការអះអាងអំពីអត្ថិភាពនៃសិទ្ធិ ឬ មានមូលហេតុនៃការបង្កើតទំនាក់ទំនងគតិយុត្តជាកំណត់ណាមួយតាមផ្លូវបណ្ដឹង។

### ៣.៣.១.២. ការសរសេរពាក្យបណ្ដឹង

ដោយយោងតាមមាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ ការប្ដឹង ត្រូវធ្វើដោយដាក់ពាក្យបណ្ដឹងជាលាយលក្ខណ៍អក្សរទៅតុលាការ។ ចំពោះពាក្យបណ្ដឹងលែងលះនេះដែរ ភាគីដែលធ្វើបណ្ដឹងលែងលះ ត្រូវបានច្បាប់កំណត់ឱ្យហៅថា ភាគីដើមបណ្ដឹង ឬភាគីដើមចោទ ហើយសហព័ទ្ធម្ខាងទៀតដែលទទួលរងការប្ដឹងពីបណ្ដឹងលែងលះនោះ ហៅថា ចុងចម្លើយ។ នៅក្នុងពាក្យបណ្ដឹងលែងលះនេះផងដែរ ត្រូវសរសេរអំពី ឈ្មោះ អាសយដ្ឋាន របស់ដើមចោទ និងចុងចម្លើយឱ្យបានច្បាស់លាស់។ ក្នុងករណីដែល ដើមចោទ និងចុងចម្លើយមានមេធាវីតំណាងដោយអាណត្តិ ក្នុងពាក្យបណ្ដឹងលែងលះក៏ត្រូវសរសេរអំពីឈ្មោះរបស់មេធាវី និងអាសយដ្ឋានរបស់ក្រុមហ៊ុនរបស់មេធាវីតំណាងដោយអាណត្តិនោះដូចគ្នា។ លើសពីនេះនៅក្នុងពាក្យបណ្ដឹងលែងលះក៏ត្រូវសរសេរអំពីខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ។ ខ្លឹមសារដែលត្រូវបញ្ជាក់រួមមាន ខ្លឹមសារទាមទារចម្បង និងខ្លឹមសារទាមទារបន្ទាប់បន្សំ។ ចំពោះខ្លឹមសារទាមទារចម្បង គឺជាការទាមទារនូវការលែងលះ។ ចំណែកឯខ្លឹមសារទាមទារបន្ទាប់បន្សំ រួមមាន ការបែងចែកទ្រព្យសម្បត្តិ ការសុំសិទ្ធិគ្រប់គ្រងបីបាច់ថែរក្សា និងធ្វើជាអ្នកមានអំណាចមេបាលើកូន ជាអាទិ៍។ បន្ថែមពីនេះ សហព័ទ្ធដើមចោទ ក៏ត្រូវសរសេរអំពី អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ និងអង្គហេតុដែលជាមូលហេតុនៃការទាមទារផងដែរ។ ហេតុនេះ សម្រាប់អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារក្នុងបណ្ដឹងលែងលះ គឺតម្រូវឱ្យភាគីធ្វើការបង្ហាញ ពីចំណងគតិយុត្តដោយស្របច្បាប់ ទៅកាន់តុលាការ ពីព្រោះការលែងលះអាចទាមទារទៅបាន លុះត្រាតែភាគីពិតជាមានអត្ថិភាពនៃសិទ្ធិក្នុងការធ្វើបណ្ដឹងលែងលះ។ [60] ហើយសម្រាប់អង្គហេតុដែលជាមូលហេតុនៃការទាមទារជាហេតុការណ៍ទាំងឡាយណាដែលនាំដើមចោទសម្រេចធ្វើបណ្ដឹងលែងលះ ពោលគឺមូលហេតុនៃការទាមទារលែងលះ នៅក្នុងមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[60] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៧៥ (២)។

**៣.៣.១.៣. ការដាក់ពាក្យបណ្ដឹង និងការបង់ពន្ធ**

ការដាក់ពាក្យបណ្ដឹងលើរឿងក្ដីលែងលះដោយគ្មានការព្រមព្រៀង ភាគីដែលមានបំណងចង់រំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍អាចដាក់ពាក្យបណ្ដឹងទៅខាងផ្នែករដ្ឋបាល របស់តុលាការរាជធានី-ខេត្តនៃលំនៅឋានប្ដី ឬប្រពន្ធ ឬលំនៅឋានប្ដីប្រពន្ធ។

ជាទូទៅនៅពេលដែលពាក្យបណ្ដឹងត្រូវបានដាក់ទៅតុលាការ ភាគីដើមចោទត្រូវបង់ពន្ធលើពាក្យបណ្ដឹងដែលមានចំនួនទឹកប្រាក់ដោយគណនាតាមតម្លៃនៃកម្មវត្ថុនៃបណ្ដឹង ដែលត្រូវបានកំណត់ដោយច្បាប់។ ហើយការគណនាពន្ធលើពាក្យបណ្ដឹង គឺត្រូវយកតម្លៃនៃកម្មវត្ថុនៃបណ្ដឹង មកធ្វើជាមូលដ្ឋានដើម្បីធ្វើការគណនា។ ប៉ុន្តែដោយសារកម្មវត្ថុនៃបណ្ដឹងលែងលះមិនអាចកំណត់បាន ករណីនេះតម្លៃកម្មវត្ថុនៃបណ្ដឹងលែងលះត្រូវចាត់ទុកថាមាន ចំនួន ៥.៥០០.០០០ (ប្រាំលានប្រាំសែន) រៀល។[61] ដូចនេះ នៅពេលដាក់ពាក្យបណ្ដឹងលែងលះ ដើមចោទ ត្រូវធ្វើការបង់ពន្ធលើពាក្យបណ្ដឹងលែងលះចំនួន ៥៥.០០០ (ប្រាំម៉ឺនប្រាំពាន់) រៀល។

**៣.៣.២. ឯកសារភ្ជាប់ និងភស្តុតាង**

ឯកសារភ្ជាប់ គឺសំដៅលើឯកសារទាំងឡាយណាដែលដើមចោទដាក់ភ្ជាប់ជាមួយនឹងពាក្យបណ្ដឹងលែងលះ។ មានន័យថានៅពេលដើមចោទដាក់ពាក្យបណ្ដឹងលែងលះទៅតុលាការ ដើមចោទត្រូវតែដាក់ឯកសារភ្ជាប់ផ្សេងៗដូចជា អត្តសញ្ញាណប័ណ្ណដើមចោទ និងចុងចម្លើយ សំបុត្រអាពាហ៍ពិពាហ៍ សំបុត្រកំណើតរបស់កូន ព្រមទាំងឯកសារផ្សេងៗដែលពាក់ព័ន្ធនឹងទ្រព្យសម្បត្តិ។ បន្ថែមពីនេះដើមចោទក៏ត្រូវដាក់ភ្ជាប់នឹងភស្តុតាងផ្សេងៗផងដែរ ពីព្រោះតុលាការត្រូវទទួលស្គាល់អង្គហេតុដោយផ្អែកលើភស្តុតាងជាមូលដ្ឋាន។[62] មួយវិញទៀតដោយសារតែបណ្ដឹងលែងលះជាប្រភេទបណ្ដឹងរដ្ឋប្បវេណី ដូចនេះការសម្រេចសេចក្ដីរបស់តុលាការពឹងផ្អែកលើអង្គហេតុ ភស្តុតាង និងសាក្សី ដែលភាគីនីមួយៗដាក់មកតុលាការ។ ការពិនិត្យភស្តុតាង ត្រូវធ្វើឡើងតាមការស្នើសុំឱ្យពិនិត្យរបស់ភាគី។ តុលាការអាចសម្រេចថា ត្រូវទទួលស្គាល់ ឬមិនទទួលស្គាល់នូវការអះអាងអំពីអង្គហេតុ ដោយភស្តុតាងដែលគូភាគីបានស្នើសុំឱ្យពិនិត្យ ឬបើយល់ឃើញថាមានការចាំបាច់ផ្សេងទៀតនោះតុលាការអាចធ្វើការពិនិត្យភស្តុតាង ដោយឆន្ទានុសិទ្ធិបាន។[63]

[61] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៦០ (៣) និងប្រកាសស្ដីពីការកែសម្រួលឧបសម្ព័ន្ធ១ និងឧបសម្ព័ន្ធ២ នៃប្រកាសលេខ ២៨ កយ ប្រក, ០៧ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៧ ស្ដីពីប្រភេទពាក្យសុំដែលតម្រូវឱ្យបង់ពន្ធចំនួនទឹកប្រាក់ នៃពន្ធដាក់ពាក្យ និងចំនួនពន្ធដែលត្រូវបង់ដើម្បីធ្វើសកម្មភាពក្រៅពីពាក្យសុំទៅតុលាការឱ្យសម្រេចសេចក្ដី និងមាត្រដ្ឋានសម្រាប់គណនាប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ និងតម្លៃកម្មវត្ថុនៃបណ្ដឹង, លេខ៥៤ កយ ប្រក/០៩, ២២ មិថុនា ២០០៩។

[62] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១២៣ (១)។

[63] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១២៤។

## ៣.៤. នីតិវិធីជំនុំជម្រះលើបណ្តឹងលែងលះ

នៅពេលដែលមានបណ្តឹងលែងលះ តុលាការត្រូវដំណើរការនីតិវិធីជំនុំជម្រះ ដោយអនុលោមទៅតាមច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណី និងច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។[64] ចំពោះនីតិវិធីជំនុំជម្រះលើរឿងក្តីលែងលះដោយគ្មានការព្រមព្រៀងនេះផងដែរ រួមមាន (៣.៤.១.) ការពិនិត្យលើបណ្តឹងទាមទារការលែងលះ, (៣.៤.២.) ការកោះហៅគូភាគី និងការបញ្ជូនពាក្យបណ្តឹង, (៣.៤.៣.) ការផ្សះផ្សា, (៣.៤.៤.) ការចាត់ចែងរក្សាការពារបណ្តោះអាសន្ន, (៣.៤.៥.) នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល, (៣.៤.៦.) នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ និង(៣.៤.៧.) ការសម្រេចសេចក្តី។

### ៣.៤.១. ការពិនិត្យលើបណ្តឹងទាមទារការលែងលះ

នៅពេលដែលបណ្តឹងត្រូវបានដាក់ ក្រឡាបញ្ជី គឺជាអ្នកដែលមានកាពតូកិច្ចក្នុងការទទួលនូវពាក្យបណ្តឹងលែងលះមកធ្វើការពិនិត្យ និងចុះលេខសំណុំរឿង។ ហើយក្រឡាបញ្ជីត្រូវធ្វើការពិនិត្យពាក្យបណ្តឹងលែងលះដោយផ្អែកតាមទម្រង់ដែលច្បាប់បានកំណត់ ពោលគឺ ត្រូវពិនិត្យមើលថា តើក្នុងពាក្យបណ្តឹងនោះមានសរសេរនូវចំណុចដែលចាំបាច់សរសេរក្នុងពាក្យបណ្តឹងគ្រប់គ្រាន់ តាមមាត្រា ៧៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីហើយឬនៅ? តើដើមចោទបានបង់ពន្ធសម្រាប់ការដាក់ពាក្យបណ្តឹង តាមច្បាប់បានកំណត់ ហើយឬនៅ? ការពិនិត្យនេះគឺជា ការពិនិត្យអំពីភាពស្រប ឬមិនស្រប នឹងលក្ខខណ្ឌទម្រង់ ហើយលក្ខខណ្ឌផលប្រយោជន៍នៃបណ្តឹង ឬ លក្ខខណ្ឌបណ្តឹងផ្សេងទៀត ឬក៏ការទាមទារ តាមផ្លូវបណ្តឹងនេះមានមូលហេតុត្រឹមត្រូវដែរឬទេ។ ក្នុងករណីដែលក្រឡាបញ្ជីពិនិត្យឃើញថា ពាក្យបណ្តឹងលែងលះនេះមិនត្រឹមត្រូវបានទម្រង់ច្បាប់កំណត់ទេនោះ ក្រឡាបញ្ជីត្រូវរាយការណ៍ទៅចៅក្រម ដើម្បីឱ្យចៅក្រមសម្រេចថា ត្រូវកែតម្រូវពាក្យបណ្តឹងលែងលះនោះ ឬ សម្រេចលើកបណ្តឹងចោលដោយដីកាសម្រេច។ ប្រសិនបើក្រឡាបញ្ជីពិនិត្យឃើញថា ពាក្យបណ្តឹងលែងលះនោះត្រឹមត្រូវទៅតាមទម្រង់ច្បាប់រួចហើយ ក្រឡាបញ្ជីត្រូវបញ្ជូនរឿងក្តីនេះ ទៅដល់ចៅក្រមដើម្បីដំណើរការនីតិវិធីបន្ត។[65]

#### ៣.៤.១.១. ការទទួលយកបណ្តឹង

នៅពេលដែលមានការដាក់ពាក្យបណ្តឹងលែះលះនៅតុលាការ ក្រឡាបញ្ជីជាអ្នកមានភារៈទទួលពាក្យបណ្តឹងលែងលះហើយត្រូវអនុវត្តតាមជំហានដូចខាងក្រោម៖

- វាយត្រាលើពាក្យបណ្តឹងដែលបានទទួល និងចុះកាលបរិច្ឆេទនៃការទទួល
- ចុះលេខរឿងនៅក្នុងសៀវភៅទទួលពាក្យបណ្តឹង និងនៅលើពាក្យបណ្តឹង
- យកពាក្យបណ្តឹង និងឯកសារពាក់ព័ន្ធមកដាក់បញ្ចូលក្នុងក្របសំណុំរឿង

[64] ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/០៦១០/០០៨, ០៨ មិថុនា ២០១០, មាត្រា៣ (គ)។
[65] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៧៧។

- បញ្ជូលសំណុំរឿងក្តីនោះទៅចៅក្រមទទួលបន្ទុកទៅតាមដីកាសម្រេចប្រចាំឆ្នាំ។

#### ៣.៤.១.២. ការលើកចោលពាក្យបណ្តឹង

បើតុលាការពិនិត្យឃើញថាពាក្យបណ្តឹងមានភាពមិនត្រឹមត្រូវលើចំណុចណាមួយដូចជា ភាពកង្វះខាតព័ត៌មានលម្អិត ការសរសេរពាក្យបណ្តឹងមិនត្រឹមត្រូវតាមទម្រង់ដែលច្បាប់បានកំណត់ កម្មវត្ថុនៃការលែងលះ អង្គហេតុចម្បង និងអង្គហេតុបន្ទាប់បន្សំមិនច្បាស់លាស់ ឬពុំទាន់បានបង់ពន្ធ ជាបឋម តុលាការគប្បីណែនាំដើមចោទ តាមរយៈក្រឡាបញ្ជី ឱ្យកែតម្រូវនូវចំណុចខ្វះខាតនោះ។[66]

មួយវិញទៀតក្នុងករណីដែលបណ្តឹងមានលក្ខណៈផ្ទុយនឹងច្បាប់ ហើយចំណុចខ្វះខាតនោះមិនអាចកែតម្រូវបានទេ តុលាការអាចលើកបណ្តឹងនោះចោលដោយសាលក្រម ដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់បាន។[67]

#### ៣.៤.១.៣. ការបន្ថែម ឬផ្លាស់ប្តូរកម្មវត្ថុនៃបណ្តឹង

ទោះបីដើមចោទដាក់ពាក្យបណ្តឹងលែងលះទៅតុលាការរួចរាល់ក្តី ក៏ដើមចោទនៅតែមានសិទ្ធិ ក្នុងការបន្ថែម ឬផ្លាស់ប្តូរនូវការទាមទារ ឬមូលហេតុនៃការទាមទារបាន រហូតដល់ពេលចប់ការទាញហេតុផលដោយផ្ទាល់មាត់នៃការជម្រះក្តីលើកទី១ ឬការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍។[68]

ការបន្ថែម ឬការផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹង ត្រូវធ្វើឡើងជាលាយល័ក្ខណ៍អក្សរ។ បន្ថែមពីនេះ ពេលដែលយល់ឃើញថាការបន្ថែម ឬការផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹងមិនត្រឹមត្រូវទេ តុលាការត្រូវចេញដីកាសម្រេចមិនយល់ព្រមនឹងការបន្ថែម ឬការផ្លាស់ប្តូរនោះតាមពាក្យសុំ ឬឆន្ទានុសិទ្ធិរបស់ខ្លួន។[69]

#### ៣.៤.១.៤. ការដាក់បណ្តឹងតបរបស់ភាគីចុងចម្លើយ

ភាគីដែលជាចុងចម្លើយនៃបណ្តឹងលែងលះ មានសិទ្ធិធ្វើបណ្តឹងតបទៅតុលាការបានរហូតដល់ពេលចប់ការទាញហេតុផលដោយផ្ទាល់មាត់នៃការជម្រះក្តីលើកទី១ ឬ ការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍។[70] បណ្តឹងតបនេះមានអានុភាពស្របច្បាប់សម្រាប់សេចក្តីសម្រេច លុះត្រាកម្មវត្ថុនៅក្នុងបណ្តឹងតបនោះមានទំនាក់ទំនងទៅនឹងកម្មវត្ថុដើមអំពីការលែងលះពីខាងដើមចោទ ឬ មធ្យោបាយការពាររបស់ដើមចោទផងដែរ។

---

66 ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៧៨។

67 ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៨១។

68 ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/០៦១០/០០៨, ០៨ មិថុនា ២០១០, មាត្រា១២។

69 ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៨៥។

70 ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/០៦១០/០០៨, ០៨ មិថុនា ២០១០, មាត្រា១២។

### ៣.៤.២. ការកោះហៅគូភាគី និងការបញ្ជូនពាក្យបណ្តឹង

បន្ទាប់ពីតុលាការបានពិនិត្យលើពាក្យបណ្តឹងលែងលះឃើញថាមានលក្ខណៈត្រឹមត្រូវតាមទម្រង់ដែលច្បាប់បានកំណត់ហើយ តុលាការត្រូវប្រញាប់កំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកដំបូងឱ្យបានឆាប់រហ័ស ក្នុងអំឡុងពេលមិនលើសពី ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃដាក់ពាក្យបណ្តឹងរបស់ខាងដើមចោទ។[71] មុននឹងកោះហៅគូភាគី និងបញ្ជូនពាក្យបណ្តឹង តុលាការត្រូវចេញដីកាបង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ ដើម្បីឱ្យដើមចោទ ឬបុគ្គលដែលទាក់ទងនឹងរឿងក្តីបង់ពន្ធលើប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ ទៅតាមចំនួនដែលតុលាការបានកំណត់ជាមុនសិន។ ចំពោះនីតិវិធីបន្តតុលាការត្រូវកោះហៅគូភាគី និងបញ្ជូនពាក្យបណ្តឹងលែងលះឱ្យចុងចម្លើយជាចាំបាច់[72] ព្រោះថាការបញ្ជូនពាក្យបណ្តឹង គឺជាការផ្តល់ឱកាសឱ្យភាគីចុងចម្លើយបានដឹងថាសហព័ទ្ធរបស់ខ្លួនបានប្តឹងសុំលែងលះ។ កិច្ចការបញ្ជូន ត្រូវធ្វើឡើងដោយក្រឡាបញ្ជី ឬបុគ្គលិកប្រៃសណីយ៍ ឬអាជ្ញាសាលាជាដើម។[73] ពាក្យបណ្តឹងត្រូវបានបញ្ជូនទៅដល់ចុងចម្លើយ ទើបបណ្តឹងនោះត្រូវបានចាត់ការ។

### ៣.៤.៣. ការផ្សះផ្សា

ការផ្សះផ្សា គឺជាការសម្របសម្រួល ដោយមានការចូលរួមអន្តរាគមន៍ពីមន្ត្រីមានសមត្ថកិច្ច ជូនដល់ភាគីដើមចោទ និងចុងចម្លើយនៃបណ្តឹងលែងលះ ដើម្បីឱ្យយល់ព្រមសះជានឹងគ្នា ព្រមទាំងបញ្ឈប់ពាក្យបណ្តឹងលែងលះពីតុលាការវិញ។ ជាទូទៅប្រសិនបើភាគី បានដាក់ពាក្យសុំទៅក្រុមប្រឹក្សាឃុំ-សង្កាត់ នោះ ក្រុមប្រឹក្សាឃុំ-សង្កាត់ ប្រាកដជាធ្លាប់ធ្វើការផ្សះផ្សា ទៅដល់គូភាគីក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ មុននឹងបញ្ជូនពាក្យបណ្តឹងលែងលះមកតុលាការ។[74] បើទោះបីជាធ្លាប់មាន ឬមិនធ្លាប់មាននូវការផ្សះផ្សានៅដំណាក់កាលក្រុមប្រឹក្សាឃុំ-សង្កាត់ ក៏តុលាការធ្វើការផ្សះផ្សាដល់គូភាគីដែរ។ មួយវិញទៀតបើទោះបីជាភាគីម្ខាងទាមទារយ៉ាងខ្លាំងចំពោះការលែងលះគ្នាក៏ដោយ តុលាការអាចសាកល្បងធ្វើការផ្សះផ្សាបាន។[75] មូលហេតុនៃការផ្សះផ្សាគឺដោយសារតែ ការលែងលះធ្វើឱ្យអាចបាត់បង់ផលប្រយោជន៍ជាច្រើនដូចជា ពេលវេលា ទ្រព្យសម្បត្តិ និងសុភមង្គលជាអាទិ៍។

[71] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៨០។

[72] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៧៩។

[73] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៤៦។

[74] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៩៨២ (២)។

[75] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៩៨៤ (១)។

### ៣.៤.៤. ការចាត់ចែងរក្សាការពារបណ្ដោះអាសន្ន

ជាទូទៅនីតិវិធីនៃការលែងលះដោយគ្មានការព្រមព្រៀង ត្រូវឆ្លងកាត់នូវនីតិវិធីជាច្រើន ព្រមទាំងមានការសាកល្បងជាច្រើនលើក ដើម្បីផ្សះផ្សាសហព័ទ្ធទាំងពីរដែលជាហេតុធ្វើឱ្យមាននីតិវិធីនៃការលែងលះដោយគ្មានការព្រមព្រៀងត្រូវការពេលវេលាមួយយ៉ាងយូរផងដែរ។ ហេតុនេះហើយទើបតុលាការអាចចេញដីកាសម្រេចបង្គាប់ឱ្យធ្វើការចាត់ចែងរក្សាការពារ ចំពោះការបំបែកលំនៅ ការគ្រប់គ្រងថែរក្សាកូន ការគ្រប់គ្រងទ្រព្យសម្បត្តិ អាហារកាតព្វកិច្ចរបស់សហព័ទ្ធ បន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍ និងសោហ៊ុយចិញ្ចឹមបីបាច់កូន ជាអាទិ៍ តាមពាក្យសុំ ឬដោយឆន្ទានុសិទ្ធិបាន។[76]

ចំពោះការចាត់ចែងរក្សាការពារនេះផងដែរ មានលក្ខណៈជាបណ្ដោះអាសន្ន ព្រោះវាមានប្រសិទ្ធិភាពតែអំឡុងពេលដែលដំណើរការនៃរឿងក្ដីប៉ុណ្ណោះ ពោលគឺនៅពេលដែលតុលាការចេញសាលក្រមស្ថាពររួចសាលក្រមនោះនឹងមកជំនួសឱ្យវិធានការបណ្ដោះអាសន្នហើយ រាល់វិធានការទាំងអស់នោះនឹងត្រូវអស់សុពលភាព។

#### ៣.៤.៤.១. ការកំណត់អំពីការរស់នៅរបស់សហព័ទ្ធ

នៅពេលដែលដំណើរការនៃរឿងក្ដីលែងលះ តុលាការអាចកំណត់ឱ្យសហព័ទ្ធរស់នៅបែកគ្នាជាបណ្ដោះអាសន្ន ក៏ព្រោះតែក្នុងគោលបំណងការពារនូវសុវត្ថិភាពរបស់ភាគីទាំងសងខាង។ មួយវិញទៀតចំពោះការលែងលះដោយគ្មានការព្រមព្រៀងរមែងតែងតែកើតឡើង ពីការរស់នៅមិនចុះសម្រុងគ្នានឹងគ្នាដូចជា មានការឈ្លោះទាស់ទែងគ្នា ការគុំគួន ដែលអាចបង្កឱ្យមានការប្រើអំពើហិង្សា រហូតឈានដល់ការបាត់បង់ជីវិតក៏ថាបាន។ នៅពេលដែលកើតមានអំពើហិង្សាភ្លាម ដើម្បីការពារជនរងគ្រោះ អាជ្ញាធរមានសមត្ថកិច្ចអាចចេញសេចក្ដីសម្រេចរដ្ឋបាលស្របតាមមាត្រា ៤៣ មាត្រា ៤៨ និងមាត្រា ៤៩ នៃច្បាប់ស្ដីគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងចាត់វិធានការបណ្ដោះអាសន្នផ្សេងៗបាន។ ទន្ទឹមនឹងការអន្តរាគមន៍របស់អាជ្ញាធរមានសមត្ថកិច្ច ជនរងគ្រោះអាចធ្វើបណ្ដឹងទៅតុលាការ ដើម្បីសុំឱ្យចេញដីកាការពារនេះបាន ឬ ប្រសិនបើតុលាការយល់ឃើញថាមានលក្ខណៈចាំបាច់ តុលាការអាចចេញដីកាការពារ ដោយឆន្ទានុសិទ្ធិបាន។ សម្រាប់ដីកាការពារនេះផងដែរ មានពីរដំណាក់កាល ដែលដំណាក់កាលទី១ ហៅថា ដីកាការពារបណ្ដោះអាសន្នដែលមានរយៈពេល ២ (ពីរ)ខែ ចេញក្នុងពេលដែលមានអាសន្នពីអំពើហិង្សាក្នុងគ្រួសារភ្លាមៗ និងដំណាក់ទី២ ហៅថា ដីកាការពារមានរយៈពេល ៦ (ប្រាំមួយ) ខែ ចេញក្នុងពេលដែលតុលាការកំពុងស៊ើបអង្កេតមិនទាន់ជំនុំជម្រះ ឬ មុនមានសាលក្រមស្ថាពរ។[77]

---

[76] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៨៣។

[77] ច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ, លេខ នស/រកម/១០០៥/០៣១, ២៤ តុលា ២០០៥, មាត្រា២៣។

**៣.៤.៤.២. ការថែរក្សាកូនជាបណ្តោះអាសន្ន**

ក្នុងករណីដែលភាគីទាំងសងខាង មិនបានពិភាក្សាគ្នាលើការថែរក្សាកូនក្នុងកំឡុងពេលនៃដំណើរការនីតិវិធីនៃការលែងលះដោយគ្មានការព្រមព្រៀង តុលាការអាចចេញនូវដីកាសម្រេចចាត់ចែងកូនជាបណ្តោះអាសន្នពោលគឺដើម្បីកំណត់ថា ឪពុក ឬម្តាយដែលជាអ្នកត្រូវមើលថែរក្សាកូនជាបណ្តោះអាសន្នសិនបាន។ គួរបញ្ជាក់ផងដែរថាការសម្រេចនេះ កើតឡើងតាមការស្នើសុំរបស់ភាគី ឬក៏កើតឡើងតាមឆន្ទានុសិទ្ធិរបស់តុលាការ។[78] លើសពីនេះសម្រាប់ការចាត់ចែងអំណាចមេបាលើកូន តុលាការត្រូវពិចារណាទៅលើផលប្រយោជន៍របស់កូនជាធំ។ ក្នុងករណីដែលកូនមានសមត្ថភាពគ្រប់គ្រាន់ អាចបង្ហាញឆន្ទៈអំពីការយល់ព្រមទៅនៅជាមួយ ឪពុក ឬម្តាយ នោះតុលាការត្រូវធ្វើការសម្រេចតាមឆន្ទៈរបស់កូន។

**៣.៤.៤.៣. ការថែរក្សាទ្រព្យសម្បត្តិជាបណ្តោះអាសន្ន**

តុលាការ អាចចេញដីកាសម្រេចទាក់ទងនឹងការថែរក្សាទ្រព្យសម្បត្តិជាបណ្តោះអាសន្ន ក្នុងអំឡុងពេលដំណើរការរឿងក្តីលែងលះបាន។ វិធានការបណ្តោះអាសន្ននេះ មានសារៈសំខាន់ ពីព្រោះនៅពេលអំឡុងពេលនៃការលែងលះនេះ ភាគីនៃបណ្តឹងលែងលះតែងមានការព្រួយបារម្ភទៅលើ បញ្ហាទ្រព្យសម្បត្តិ ដោយខ្លាចភាគីម្ខាងទៀត ព្យាយាមយកទ្រព្យសម្បត្តិទាំងនោះទៅធ្វើការកែប្រែ ឬ លក់ ឬ ផ្ទេរ ឬ បំផ្លាញចោលនូវទ្រព្យសម្បត្តិទាំងអស់ មុនពេលដែលតុលាការសម្រេច លើការបែងចែកទ្រព្យសម្បត្តិ។

**៣.៤.៤.៤. ការផ្គត់ផ្គង់សហព័ទ្ធ ឬផ្គត់ផ្គង់កូន**

តុលាការក៏មានអាចចេញដីកាសម្រេចទាក់ទងនឹងវិធានការបណ្តោះអាសន្នស្តីពី ការផ្គត់ផ្គង់កូនបណ្តោះអាសន្ន ដោយត្រូវពិចារណាលើការកំណត់ហិរញ្ញវត្ថុ ចាំបាច់សម្រាប់ចិញ្ចឹមផ្គត់ផ្គង់កូនៗដែលមាននៅក្នុងបន្ទុកក្នុងអំឡុងពេលដែល ឪពុក និងម្តាយកំពុងតែប្តឹងលែងលះគ្នា។ ហើយក្នុងករណីចាំបាច់ តុលាការក៏អាចសម្រេចឱ្យមានការផ្គត់ផ្គង់ដល់សហព័ទ្ធ ណាដែលកំពុងជួបបញ្ហាហិរញ្ញវត្ថុធ្ងន់ធ្ងរផងដែរ អាស្រ័យលើការពិចារណា និងឆន្ទានុសិទ្ធិរបស់តុលាការ។[79]

ជាទូទៅនៅក្នុងប្រទេសកម្ពុជា និងនៅប្រទេសដទៃទៀត តុលាការនឹងពិចារណាលើចំណុចមួយចំនួនដូចជា សេចក្តីត្រូវការរបស់កូន លទ្ធភាពខាងហិរញ្ញវត្ថុរបស់ឪពុក ឬម្តាយដែលត្រូវបានគេស្នើសុំប្រាក់ផ្គត់ផ្គង់ និងស្ថានភាពហិរញ្ញវត្ថុរបស់ឪពុក ឬម្តាយដែលកូនត្រូវរស់នៅជាមួយ។

[78] ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/០៦១០/០០៨, ០៨ មិថុនា ២០១០, មាត្រា២១។

[79] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៨៣។

### ៣.៤.៥. នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវរៀបចំនូវសេចក្តីអះអាងរបស់ភាគី បំភ្លឺនូវចំណុចវិវាទនៃរឿងក្តីដែលគូភាគីយល់មិនស្របគ្នា និងរៀបចំភស្តុតាងដែលទាក់ទងនឹងចំណុចវិវាទនៃរឿងក្តីនោះ ដើម្បីអាចធ្វើការវិនិច្ឆ័យរឿងក្តីនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ឱ្យបានល្អិតល្អន់។[80] លើសពីនេះទៅទៀតចំពោះនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជានីតិវិធីមួយដែលតុលាការធ្វើឡើង ដើម្បីលើកកម្ពស់ និងសម្រួលដល់ការជម្រះក្តីនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់។ តុលាការ ត្រូវដឹកនាំនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះឡើង គឺដើម្បីជាឱកាសមួយដល់ភាគីទាំងសងខាង បានមកជួបជុំគ្នានៅតុលាការ ដើម្បីនិយាយនៅចំពោះមុខគ្នា ពីចំណុចវិវាទ ការអះអាង និងការបំភ្លឺទាំងឡាយ ទាក់ទងនឹងការលែងលះ។ បន្ថែមពីនេះតុលាការអាចបង្គាប់ ឱ្យភាគីធ្វើការបំភ្លឺបន្ថែមចំពោះចំណុចមិនច្បាស់នៃបណ្តឹង ឬឯកសារត្រៀម ឬធ្វើការសាកសួរដល់ភាគីបន្ថែម។[81]

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវធ្វើនៅកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចចូលរួមបាន មានន័យថា គោលការណ៍ចំពោះមុខ ត្រូវបានតុលាការយកមកអនុវត្តយ៉ាងពេញលេញនៅក្នុងនីតិវិធីនេះ។ មួយវិញទៀត នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះទៀតសោត តុលាការមិនចាំបាច់ធ្វើជាសាធារណៈទេ ហើយតាមធម្មតា គេប្រើបន្ទប់ក្រៅពីសាលសវនាការ ពោលគឺប្រព្រឹត្តទៅនៅក្នុងបន្ទប់របស់ចៅក្រមដែលទទួលបន្ទុករឿងក្តីលែងលះនោះ។[82] តុលាការ ត្រូវបង្គាប់ឱ្យដើមចោទថ្លែងការណ៍អំពីបណ្តឹងទាមទាររបស់ខ្លួនដោយផ្ទាល់មាត់។ ក្នុងករណីដែលភាគីមានមេធាវី តំណាងដោយអាណាត្តិ មេធាវីអាចថ្លែងការណ៍ជំនួសកូនក្តីរបស់ខ្លួនបាន។ បន្ថែមពីនេះ ភាគីនៃបណ្តឹងលែងលះ ត្រូវដាក់ មធ្យោបាយតទល់ ឬ មធ្យោបាយការពារខ្លួន ឱ្យតុលាការផងដែរ។[83]

មួយវិញទៀត នៅក្នុងនីតិវិធីត្រៀមនេះ តុលាការត្រូវឱ្យក្រឡាបញ្ជីធ្វើកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នៅគ្រប់កាលបរិច្ឆេទនីមួយៗ។ នៅក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះផងដែរ ក្រឡាបញ្ជីត្រូវកត់ត្រានូវចំណុចមួយចំនួនដូចជា សញ្ញាណរឿងក្តី ឈ្មោះចៅក្រម និងក្រឡាបញ្ជី ឈ្មោះភាគី និងបុគ្គលដែលពាក់ព័ន្ធ ព្រមទាំងពេលវេលា និងទីកន្លែង។ បន្ទាប់មកប្រធានក្រុមប្រឹក្សាជំនុំជម្រះ និងក្រឡាបញ្ជី ត្រូវចុះហត្ថលេខាលើកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនោះ។[84]

---

[80] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១០៣។

[81] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៩០ (១)។

[82] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១០៥ (២)។

[83] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៩៣

[84] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១១០។

ទាក់ទងនឹងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នេះផងដែរ ក្រឡាបញ្ជីត្រូវកត់ត្រាបន្ថែមនូវចំណុចសារធាតុដូចជា ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ និងចម្លើយតបរបស់ចុងចម្លើយចំពោះការទាមទារនោះ ខ្លឹមសារនៃអង្គហេតុដែលបានអះអាង ការស្នើសុំពិនិត្យភស្តុតាង ព្រមទាំងសកម្មភាពផ្សេងៗដែលគូភាគីបានធ្វើនៅនីតិវិធីនេះ។[85] ក្នុងករណីដែលភាគី ឬអ្នកដទៃទៀតដែលពាក់ព័ន្ធ ប្តឹងតវ៉ាចំពោះសេចក្តីកត់ត្រានៅក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនោះ ត្រូវកត់សេចក្តីប្តឹងតវ៉ានៅក្នុងកំណត់ហេតុនោះ។[86]

### ៣.៤.៦. នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់

មុននឹងចេញសាលក្រមស្តីពីបណ្តឹងលែងលះ តុលាការចាំបាច់ត្រូវឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ជាមុនសិន។ ជាទូទៅនៅពេលដែលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានចប់សព្វគ្រប់ហើយ តុលាការត្រូវកំណត់កាលបរិច្ឆេទ ដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ហើយត្រូវកោះហៅភាគីនៃបណ្តឹងលែងលះមកចូលរួម។[87] ចំពោះកាលបរិច្ឆេទជាក់លាក់នៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់វិញ គឺអាស្រ័យលើសិទ្ធិសម្រេចរបស់តុលាការ។ ទោះបីជាតុលាការមានសិទ្ធិសម្រេចកាលបរិច្ឆេទនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ក៏ដោយ តុលាការត្រូវជ្រើសកាលបរិច្ឆេទដែលភាគីសងខាងអាចមានវត្តមានបាន។[88] លើសពីនេះ ក្នុងនីតិវិធីទាញហេតុផលនេះទៀតសោត ជាទូទៅធ្វើឡើងនៅសាលសវនាការជាសាធារណៈ ប៉ុន្តែសម្រាប់បណ្តឹងលែងលះវិញ មិនត្រូវធ្វើជាសាធារណៈឡើយ ពោលគឺតុលាការអាចរៀបចំនៅសាលសវនាការ ក៏ប៉ុន្តែត្រូវមានលក្ខណៈអសាធារណៈ មានតែបុគ្គលដែលពាក់ព័ន្ធនឹងរឿងក្តីលែងលះប៉ុណ្ណោះដែលអាចចូលរួមបាន។

នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នេះដែរ ភាគីទាំងសងខាងត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដើម្បីចង្អុលបង្ហាញឱ្យបានច្បាស់នៅអង្គហេតុដែលត្រូវនឹងបញ្ជាក់ដោយការពិនិត្យភស្តុតាង ដែលនឹងត្រូវធ្វើនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់។ ហើយនៅពេលដែលធ្វើការទាញហេតុផលដោយផ្ទាលមាត់ ភាគីទាំងសងខាងអាចអះអាងអំពីអង្គហេតុបន្ថែម និងអាចដាក់ភស្តុតាងមកទៀតបាន តែការបន្ថែមទាំងនេះត្រូវមានលក្ខណៈត្រឹមត្រូវតាមច្បាប់កំណត់។[89]

---

[85] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១១១។
[86] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១១២ (១)។
[87] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១១៣។
[88] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១១៥ (១)។
[89] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១១៦។

នៅមុនពេលដែលតុលាការសម្រេចសេចក្តី តុលាការត្រូវស្វែងរកភស្តុតាងនានា ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការសេចក្តី។ ជាទូទៅភស្តុតាងត្រូវបានពិនិត្យតាមឆន្ទានុសិទ្ធិរបស់តុលាការ ឬតាមការស្នើសុំរបស់ភាគី ដូចជា តុលាការទទួលបានការបំភ្លឺបន្ថែម ទៅលើរឿងក្តីលែងលះ តាមរយៈការសាកសួរសាក្សី។

ដើម្បីឱ្យតុលាការអាចប្រមូលភស្តុតាងគ្រប់គ្រាន់ និងគ្រប់ជ្រុងជ្រោយ ដោយចៅក្រមអាចសាកសួរជនណាមួយជាសាក្សីបាន។ តុលាការអាចបង្គាប់ឱ្យនាំខ្លួនសាក្សីដែលមិនព្រមចូលខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវដោយដីកាសម្រេចបាន។ ប្រសិនបើសាក្សីមិនព្រមចូលខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវតុលាការអាចពិន័យជាប្រាក់មិនលើសពី ១.០០០.០០០ (មួយលាន) រៀល បានដោយដីកាសម្រេច។ [90]

រីឯការសាកសួរភាគីលែងលះវិញ គឺចាំបាច់ណាស់សម្រាប់តុលការ ដែលត្រូវតែសាកសួរទៅកាន់ភាគីដើមចោទ និងចុងចម្លើយឱ្យធ្វើការអះអាង ដើម្បីប្រមូលយកព័ត៌មានទាំងឡាញពាក់ព័ន្ធរឿងក្តី។ ភាគីតែងឆ្លើយបំភ្លឺ ឬសារភាព ឬ បដិសេដចោលនូវការអះអាងទៅវិញទៅមកនៅចំពោះមុខតុលាការ។ មួយវិញទៀត គឺការត្រួតពិនិត្យតាមរយៈការធ្វើកោសលវិច័យ។ កោសលវិច័យគឺជាភស្តុតាង ដោយបង្គាប់ឱ្យតតិយជន ដែលមានឯកទេស បច្ចេកទេស និងចំណេះដឹងផ្សេងៗ ឱ្យវិនិច្ឆ័យនូវចំណុចណាមួយ ដោយផ្អែកលើ ឯកទេស បច្ចេកទេស និងចំណេះដឹងនោះ។ កោសលវិច័យ គឺជាការពិនិត្យភស្តុតាងមួយប្រភេទ ហើយជាគោលការណ៍ត្រូវធ្វើឡើងដោយការស្នើសុំពីភាគី ដូចភស្តុតាងដទៃទៀតដែរ ប៉ុន្តែករណីដែលទទួលស្គាល់ថាមានការការចាំបាច់ តុលាការអាចបង្គាប់ឱ្យធ្វើកោសលវិច័យបាន។ [91] លើសពីនេះ ភស្តុតាងជាឯកសារផ្សេងៗទៀត ដែលជាប់ពាក់ព័ន្ធ តុលាការត្រូវយកមកពិនិត្យវិនិច្ឆ័យលើឯកសារទាំងអស់នោះ។ ភស្តុតាងជាឯកសារសម្រាប់វិវាទលែងលះមានដូចជា សំបុត្រអាពាហ៍ពិពាហ៍ សំបុត្រកំណើតកូន ក៏ដូចជាឯកសារដែលពាក់ព័ន្ធនឹងទ្រព្យសម្បត្តិជាដើម។

តុលាការអាចអនុញ្ញាតឱ្យភាគីនីមួយៗធ្វើការទាញហេតុផលចុងក្រោយបាន មុនពេលបញ្ឈប់ការទាញហេតុផលដោយផ្ទាល់មាត់។[92] តុលាការត្រូវឱ្យក្រឡាបញ្ជីធ្វើកំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់ជូនតុលាការផងដែរ។ នៅក្នុងកំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវកត់ត្រា នូវចំណុចដូចជា សញ្ញាណរឿងក្តី ឈ្មោះចៅក្រម និងក្រឡាបញ្ជី ព្រមទាំងឈ្មោះរបស់ភាគី និងបុគ្គលដែលពាក់ព័ន្ធ និងពេលវេលា ទីកន្លែងផងដែរ។[93] ទាក់ទងនឹងកំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់នេះផងដែរ ក្រឡាបញ្ជី

[90] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១៣២។

[91] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១២៤។

[92] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១១៦ (៥)។

[93] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១១៨។

ត្រូវកត់ត្រានូវ ចំណុចសារធាតុបន្ថែមមួយចំនួនដូចជា សេចក្ដីថ្លែងការណ៍របស់សាក្សី របស់ភាគីផ្ទាល់ខ្លួន ព្រមទាំងសកម្មភាពផ្សេងៗដែលគូភាគីបានធ្វើនៅនីតិវិធីនេះ។[94]

### ៣.៤.៧. សេចក្ដីសម្រេច

បន្ទាប់ពីឆ្លងកាត់នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់រួចហើយ តុលាការនឹងធ្វើការសម្រេចសេចក្ដីដោយការចេញសាលក្រម។ នៅក្នុងការសម្រេចសេចក្ដី ទៅលើរឿងក្ដីលែងលះដោយគ្មានការព្រមព្រៀង តុលាការមានឆន្ទានុសិទ្ធិសម្រេចចេញសាលក្រម ឬសម្រេចបដិសេធចោលនូវបណ្ដឹងលែងលះនោះ។

#### ៣.៤.៧.១. ការចេញសាលក្រមលើបណ្ដឹងលែងលះ

សាលក្រម សំដៅលើការសម្រេចសេចក្ដីដែលតុលាការធ្វើលិខិតសាលក្រមដែលមានលក្ខណៈគ្រប់គ្រាន់ទៅតាមទម្រង់ដែលច្បាប់បានកំណត់ ដោយផ្អែកលើការទាញហេតុផលដោយផ្ទាល់មាត់។[95] ក្នុងករណីបើយល់ឃើញថា ត្រូវបញ្ចប់ការវិនិច្ឆ័យដោយផ្អែកលើលទ្ធផលដែលបានពីការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យលើភស្តុតាង តុលាការត្រូវបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ហើយចេញសាលក្រម។[96] ជាទូទៅតុលាការត្រូវចេញសាលក្រមចំពោះការទាមទារទាំងអស់ដែលភាគីបានសុំ។ ហើយតុលាការមិនអាចចេញសាលក្រមចំពោះចំណុចណាដែលភាគីមិនបានសុំឡើយ។[97] ក៏ប៉ុន្តែប្រសិនបើតុលាការចេញសាលក្រម ឬសាលដីកាដែលទទួលស្គាល់ការទាមទាររបស់ដើមចោទនៅក្នុងបណ្ដឹងទាមទារលែងលះគ្នា តុលាការត្រូវធ្វើការសម្រេចសេចក្ដីអំពីការកំណត់អ្នកមានអំណាចមេបាដោយឆន្ទានុសិទ្ធិ ហើយបើមានពាក្យសុំរបស់ភាគី ត្រូវធ្វើការសម្រេចសេចក្ដីអំពីការចាត់ចែងទាក់ទងនឹងការបីបាច់រក្សាកូន ឬការចាត់ចែងទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិ។[98] ទាក់ទងនឹកការសម្រេចសេចក្ដីអំពីការកំណត់អ្នកមានអំណាចមេបា ឬការចាត់ចែងទាក់ទងនឹងការបីបាច់រក្សាកូន នេះផងដែរ តុលាការត្រូវពិចារណា ថ្លឹងថ្លែង ពីយោបល់របស់កូន ស្របទៅតាមអាយុ និងសភាពចាស់ទុំរបស់កូននោះ។[99]

នៅក្នុងលិខិតសាលក្រម តុលាការត្រូវសរសេរអំពី តុលាការដែលមានសមត្ថកិច្ច, ថ្ងៃដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់, ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគីដែលពាក់ព័ន្ធ, អង្គហេតុ, ចំណុចវិវាទ, សំអាងហេតុ និងសេចក្ដីសម្រេចបញ្ចប់ផងដែរ។ ចៅក្រមដែលចេញសាលក្រមត្រូវចុះហត្ថលេខា

[94] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១១៩។
[95] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១៧៩ (១)។
[96] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១៨០។
[97] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១៨២ (១) (២)។
[98] ច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/០៦១០/០០៨, ០៨ មិថុនា ២០១០, មាត្រា២២ (១)។
[99] ច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/០៦១០/០០៨, ០៨ មិថុនា ២០១០, មាត្រា២២ (៤)។

លើលិខិតសាលក្រមនោះផងដែរ។ សាលក្រមនឹងមានអានុភាពដោយការប្រកាស។[100] ការប្រកាសសាលក្រម ត្រូវធ្វើឡើងក្នុងអំឡុងពេល ១ (មួយ) ខែ គិតចាប់ពីថ្ងៃដែលបានបញ្ចប់នូវការទាញហេតុផលដោយផ្ទាល់មាត់។[101] ជាក់ស្តែង សាលក្រមដែលបានសម្រេចអំពីការលែងលះត្រូវបញ្ជូនឱ្យទៅ ភាគីក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ដោយត្រូវគិតចាប់ពីថ្ងៃដែលបានប្រកាសសាលក្រម។[102]

### ៣.៤.៧.២. ការសម្រេចមិនឱ្យមានការលែងលះ

ទោះបីជាក្នុងករណីដែលមានមូលហេតុគ្រប់គ្រាន់តាមពាក្យបណ្តឹង សម្រាប់ការសម្រេចសេចក្តីឱ្យលែងលះគ្នាក៏ដោយ ប្រសិនបើយល់ឃើញថា ការលែងលះនោះនឹងបណ្តាលឱ្យការទ្រទ្រង់ជីវភាពរបស់សហព័ទ្ធ ឬកូនក្រលំបាកយ៉ាងខ្លាំង ឬមានការឈឺចាប់យ៉ាងខ្លាំងដែលពុំអាចទ្រាំទ្របាន នោះតុលាការអាចច្រានចោលការទាមទារលែងលះគ្នា ដោយពិចារណាទៅលើស្ថានភាពទាំងឡាយបាន។[103]

ក្នុងករណីដែលមានមូលហេតុផ្សេងទៀត តុលាការក៏អាចច្រានការទាមទារលែងលះគ្នាបានដែរ ប្រសិនបើយល់ឃើញថា ការទាមទារនោះផ្ទុយនឹងភាពសុចរិត ដោយជនដែលទាមទារឱ្យលែងលះគ្នានោះធ្វេសប្រហែសយ៉ាងខ្លាំង ក្នុងការសហប្រតិបត្តិការ និងជួយសង្គ្រោះចំពោះសហព័ទ្ធ ហើយតុលារការអាចច្រានចោលការទាមទារលែងលះគ្នានោះ ដោយឆន្ទានុសិទ្ធិបាន។[104]

### ៣.៤.៧.៣. ការចូលជាស្ថាពរនៃសាលក្រម

ជាការពិតណាស់ សាលក្រមមិនអាចចូលជាស្ថាពរ នៅមុនពេលផុតអំឡុងពេលដែលបានកំណត់សម្រាប់ការប្តឹងឧបាស្រ័យ ទៅតុលាការជាន់ខ្ពស់ (សាលាឧទ្ធរណ៍ និងតុលាការកំពូល) បានទេ។ ជាទូទៅនៅពេលដែលសាលក្រមត្រូវបានបញ្ជូនឱ្យទៅភាគីក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ដោយត្រូវគិតចាប់ពីថ្ងៃដែលបានប្រកាសសាលក្រមរួចមក គូភាគីអាចប្តឹងឧទ្ធរណ៍នឹងសាលក្រមនេះបានក្នុងអំឡុងពេល ១ (មួយ) ខែ ដោយគិតចាប់តាំងពីថ្ងៃដែលបានទទួលការបញ្ជូនលិខិតសាលក្រម។[105] ហេតុនេះ បើគ្មានការប្តឹងដូចបានលើកឡើងខាងលើនេះទេ ហើយអំឡុងពេលដែលអនុញ្ញាតឱ្យប្តឹងត្រូវបានផុតកំណត់ នោះសាលក្រមនឹងចូលជាស្ថាពរ។

---

[100] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១៨៦។

[101] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១៨៧។

[102] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១៣៨ (៣)។

[103] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧៨ (២)។

[104] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧៨ (៣)។

[105] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៦៤ (១)។

# ជំពូកទី៤
# អានុភាពនៃការលៃខលះ

# ជំពូកទី៤
# អានុភាពនៃការលែងលះ

ជាការពិតសេចក្ដីសម្រេចរបស់តុលាការអំពីការលែងលះចូលជាស្ថាពរ នៅពេលដែលអំឡុងពេលនៃបណ្ដឹងឧបាស្រ័យបានកន្លងផុត។ ជាក់ស្ដែង បើសេចក្ដីសម្រេចនោះជាសាលក្រម អំឡុងពេលដែលប្ដឹងឧទ្ធរណ៍គឺមានរយៈពេល ១ (មួយ) ខែ ដោយគិតចាប់ពីថ្ងៃដែលភាគី ទាំងដើមចោទ និងចុងចម្លើយទទួលបាននូវការបញ្ជូនលិខិតសាលក្រម។[106] ក្នុងករណីដែលសេចក្ដីសម្រេចនេះជា ដីកាសម្រេច អំឡុងពេលនៃការប្ដឹងជំទាស់មានរយៈពេល ២ (ពីរ) សប្ដាហ៍ ដោយគិតចាប់ពីថ្ងៃដែលបានទទួលការជូនដំណឹងពីដីកាសម្រេចនោះ។[107] ដូចនេះនៅពេលដែលសេចក្ដីសម្រេចអំពីការលែងលះបានចូលជាស្ថាពរ អានុភាពនៃការលែងលះក៏កើតមានឡើងដែលនាំឱ្យកើតមានឡើងនូវ (៤.១.) ការកាត់ផ្ដាច់ទំនាក់ទំនងគតិយុត្ត, (៤.២.) ការបែងចែកទ្រព្យសម្បត្តិ, (៤.៣.) ការប្រគល់អំណាចមេបា, (៤.៤) ការផ្ដល់អាហារកាតព្វកិច្ច ព្រមទាំង (៤.៥.) ការចុះបញ្ជីអំពីការលែងលះផងដែរ។

## ៤.១. ការកាត់ផ្ដាច់ទំនាក់ទំនងគតិយុត្ត

ជាទូទៅអានុភាពនៃការលែងលះនឹងធ្វើឱ្យមានការកាត់ផ្ដាច់ទំនាក់ទំនងគតិយុត្តដូចជា៖ (៤.១.១.) ការកាត់ផ្ដាច់ទំនាក់ទំនងគតិយុត្តរវាងសហព័ទ្ធ និង(៤.១.២.) ការកាត់ផ្ដាច់ទំនាក់ទំនងរវាងញាតិពន្ធ។

### ៤.១.១. ការកាត់ផ្ដាច់ទំនាក់ទំនងគតិយុត្តរវាងសហព័ទ្ធ

អាពាហ៍ពិពាហ៍មួយកើតឡើង នៅពេលដែលបុរស និងស្ត្រី ដែលមានវ័យនីតិភាព បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ហើយព្រមទាំងបានចុះសំបុត្រអាពាហ៍ពិពាហ៍ដោយស្របតាមច្បាប់កំណត់។ តាមច្បាប់ក្រោយពីអាពាហ៍ពិពាហ៍ត្រូវបានបង្កើតឡើង ហើយគូភាគីនៃអាពាហ៍ពិពាហ៍នឹងក្លាយជាសហព័ទ្ធនឹងគ្នា។ ដូច្នេះក្នុងឋានៈជាសហព័ទ្ធនេះបានផ្ដល់នូវសិទ្ធិ និងករណីយកិច្ចមួយចំនួន ព្រមទាំងបង្កើតឱ្យមានទំនាក់ទំនងគតិយុត្តរវាងញាតិពន្ធផងដែរ។ នៅពេលដែលពួកគេលែងលះគ្នា នោះអានុភាពនៃការលែងលះបានកាត់ផ្ដាច់ទំនាក់ទំនងគតិយុត្តរវាងសហព័ទ្ធ ចាប់ពីសេចក្ដីសម្រេចរបស់តុលាការចូលជាស្ថាពរ។ អានុភាពនោះរួមមាន (៤.១.១.១.) ស្ថានភាពគ្រួសារ (ពោះម៉ាយ ឬ មេម៉ាយ), (៤.១.១.២.) ការបញ្ចប់នូវការរួមរស់ជីវភាពជាមួយគ្នា សហការ និងសង្គ្រោះគ្នាទៅវិញទៅមក, (៤.១.១.៣.) នាមត្រកូលអាចត្រូវបានបញ្ចប់, (៤.១.១.៤.) ការបញ្ចប់ភាពជាសន្តិជនជានិច្ច, (៤.១.១.៥.) អត្តាធីនភាពនៅតែកើតមាន និង(៤.១.១.៦.) កាតព្វកិច្ចសងសំណងជម្ងឺចិត្តអាចកើតមានផងដែរ។

---

[106] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៦៤ (២)។

[107] ច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០, មាត្រា៤០។

### ៤.១.១.១. ស្ថានភាពគ្រួសារ (ពោះម៉ាយ ឬ មេម៉ាយ)

នៅពេលដែលសាលក្រមរបស់តុលាការបានចូលជាស្ថាពររួច គូភាគីនៃបណ្តឹងលែងលះ ដែលធ្លាប់តែជាប្តីប្រពន្ធស្របច្បាប់នឹងគ្នានោះ បានប្រែក្លាយជានៅលីវរៀងៗខ្លួនសារជាថ្មី។ មានន័យថា នៅពេលដែលសាលក្រមបានចូលជាស្ថាពរ ភាគីមានសិទ្ធិសេរីភាពឡើងវិញ ក្នុងការរៀបអាពាហ៍ពិពាហ៍ ដោយស្របទៅតាមច្បាប់ម្តងទៀត។ ប៉ុន្តែសម្រាប់ភាគីដែលជានារីវិញពុំអាចរៀបអាពាហ៍ពិពាហ៍ថ្មីទៀតបានឡើយ ប្រសិនបើអំឡុងពេល ១២០ (មួយរយម្ភៃ) ថ្ងៃ ពុំបានកន្លងផុត គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍មុន ត្រូវបានរំលាយ ឬ លុបចោល។ ទោះបីជាយ៉ាងណាក៏ដោយ ក៏នារីអាចរៀបអាពាហ៍ពិពាហ៍ថ្មីបានក្នុងករណីដែលនារីមានផ្ទៃពោះនៅមុនពេលដែលអាពាហ៍ពាហ៍មុនត្រូវបានរំលាយ ឬ លុបចោល ហើយបានសម្រាលកូន ឬ ចំពោះករណីដែលមានលិខិតបញ្ជាក់ពីការគ្មានផ្ទៃពោះ ពីវេជ្ជបណ្ឌិត។[108]

### ៤.១.១.២. ការបញ្ចប់នូវការរួមរស់ជីវភាពជាមួយគ្នា សហការ និងសង្គ្រោះគ្នាទៅវិញទៅមក

ដើម្បីកសាងគ្រួសារមួយឱ្យមានសុភមង្គល ប្តីប្រពន្ធត្រូវរួមរស់ជីវភាពជាមួយគ្នា ហើយត្រូវសហការសង្គ្រោះគ្នាទៅវិញទៅមក[109] ប៉ុន្តែដោយសារតែអានុភាពនៃការលែងលះកាតព្វកិច្ចរួមរស់ជីវភាពជាមួយគ្នា ការសហការគ្នា និងសង្គ្រោះគ្នាទៅវិញទៅមកត្រូវបានបញ្ចប់។

### ៤.១.១.៣. នាមត្រកូលអាចត្រូវបានបញ្ចប់

នៅពេលរៀបអាពាហ៍ពិពាហ៍ ប្តី ប្រពន្ធអាចប្រើនាមត្រកូលរបស់ប្តី ឬប្រពន្ធ ឬ អាចប្រើនាមត្រកូលដើមរៀងៗខ្លួន ដែលមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍។[110] ក្នុងករណីបើប្តី ឬប្រពន្ធដែលបានប្តូរនាមត្រកូលថ្មីដោយចំណងអាពាហ៍ពិពាហ៍ អាចប្រើនាមត្រកូលដែលមាន នៅមុនពេលរៀបអាពាហ៍ពិពាហ៍វិញបាន ឬអាចប្រើនាមត្រកូលដែលបានប្រើនៅពេលលែងលះគ្នាក៏បាន។[111]

ឧបមាថា៖ លោក ព្រំ បញ្ញា បានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងនារីម្នាក់ឈ្មោះលោកស្រី ផាន់ បូផា។ ក្នុងករណីនេះ លោកស្រី ផាន់ បូផា អាចប្រើនាមត្រកូលរបស់ប្តីនាងបាន ដោយប្តូរទៅជាលោកស្រី ព្រំ បូផាវិញ។ ក្នុងករណីបែបនេះប្រសិនបើអ្នកទាំងពីរលែងលះគ្នាវិញ លោកស្រី បូផា អាចប្រើឈ្មោះ ព្រំ បូផា ដដែលក៏បាន ឬក៏ចង់ប្តូរទៅប្រើឈ្មោះដើមជា ផាន់ បូផា វិញក៏បានដែរ។

[108] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៥០។
[109] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៦៦។
[110] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៦៥។
[111] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៨១។

#### ៤.១.១.៤. ការបញ្ចប់ភាពជាសន្តតិជនជានិច្ច

យោងតាមក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ សហព័ទ្ធដែលស្ថិតក្នុងចំណងអាពាហ៍ពិពាហ៍ បានទទួលស្គាល់ថាជាសហព័ទ្ធរបស់មតកជន ត្រូវក្លាយជាសន្តតិជនជានិច្ច។[112] នៅពេលដែលចំណងអាពាហ៍ពិពាហ៍ត្រូវបានរំលាយដោយការលែងលះ អានុភាពបានធ្វើឱ្យសន្តតិជនជានិច្ចរបស់សហព័ទ្ធនោះ ក៏ត្រូវបានបញ្ចប់ផងដែរ។

#### ៤.១.១.៥. អត្តាធីនភាពនៅតែកើតមាន

អត្តាធីនភាព ជាស្ថានភាពមួយ ដែលផ្តល់ឱ្យអនីតិជនបានរួចផុត ពីអាណាព្យាបាលសម្រាប់អនីតិជន ឬរួចផុតពីអំណាចមេបា ហើយមានសមត្ថភាពដូចនីតិជនដែរ។[113] ដោយយោងតាមក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ប្រសិនបើអនីតិជនបានរៀបអាពាហ៍ពិពាហ៍ អនីតិជននោះត្រូវបានចាត់ទុកបានដល់នីតិភាពដោយអាពាហ៍ពិពាហ៍នោះ។[114] អនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍ហើយ ត្រូវទទួលអត្តាធីនភាពដោយមិនចាំបាច់មានការប្រកាសពីតុលាការទេ។ ប៉ុន្តែទោះបីជាភាគីលែងលះគ្នាក៏ដោយ ក៏អានុភាពនៃអត្តាធីនភាព មិនត្រូវរលត់ឡើយ។[115]

#### ៤.១.១.៦. ភាតព្វកិច្ចសងសំណងជម្ងឺចិត្តអាចកើតមាន

នៅពេលដែលសាលក្រមចូលជាស្ថាពរ នៅក្នុងករណីដែលភាគីដែលគ្មានកំហុស ហើយត្រូវបានភាគីម្ខាងទៀតបំពាន ភាគីដែលទទួលរងនូវការបំពាន អាចទាមទារសំណងជម្ងឺចិត្ត ឬសំណងនៃការខូចខាតបានតាមអំពើអនីត្យានុកូល ដោយផ្អែកតាមមាត្រា ៧៤៣ និង ៧៤៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បាន។

ឧបមាថា៖ ក(ប្តី) បានប្រព្រឹត្តិអំពើផិតក្បត់ ជេរប្រមាថ និងប្រើអំពើហិង្សាមកលើ ខ(ប្រពន្ធ) បណ្តាលឱ្យ ខ(ប្រពន្ធ) រងរបួសធ្ងន់ ដោយត្រូវចំណាយថ្លៃព្យាបាលជម្ងឺអស់ចំនួន USD ៣០០០ (បីពាន់) ដុល្លារអាមេរិក ហើយ ខ(ប្រពន្ធ) ទទួលរងសម្ពាធផ្លូវចិត្តយ៉ាងខ្លាំង។ ក្នុងករណីនេះ ខ(ប្រពន្ធ) អាចទាមទារសំណងនៃការខូចខាតពី ក(ប្តី) បានទាំងសំណងខូចខាតផ្នែកសម្ភារៈ និងផ្លូវចិត្ត។

### ៤.១.២. ការកាត់ផ្តាច់ទំនាក់ទំនងរវាងញាតិពន្ធ

អានុភាពនៃការលែងលះ មិនត្រឹមតែកាត់ផ្តាច់ទំនាក់ទនងរវាងសហព័ទ្ធនោះទេ ការលែងលះថែមទាំងនាំឱ្យមានការកាត់ផ្តាច់នូវទំនាក់ទំនងរវាងញាតិពន្ធផងដែរ។ ផ្អែកតាមក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បានកំណត់ទំហំរបស់ញាតិ មាន ញាតិលោហិតក្នុង ៦ (ប្រាំមួយ) ថ្នាក់ សហព័ទ្ធ និង ញាតិពន្ធក្នុង ៣ (បី) ថ្នាក់។[116]

---

112 ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៦១។

113 ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, សន្ទានុក្រម លេខ១៨៣។

114 ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៦៨។

115 ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា២១ (២)(៣)។

116 ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៣៨។

ញាតិលោហិត គឺសំដៅដល់ញាតិ ដែលមានឈាមជ័រជាមួយគ្នា ដូចជា ឪពុក និងកូន ឬម្ដាយ និងកូន ជាដើម។ សហព័ទ្ធ សំដៅលើ ប្ដី ឬប្រពន្ធ ឬទាំងប្ដី ទាំងប្រពន្ធដែលទទួលបានឋានៈជាសហព័ទ្ធនេះក្រោយពីបានចុះបញ្ជីអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់។[117] ញាតិពន្ធ គឺសំដៅទៅលើញាតិដែលជាសាច់ថ្លៃ ដែលកើតឡើងដោយសារតែមានចំណងអាពាហ៍ពិពាហ៍ជាមួយគ្នាដូចជា ឪពុកម្ដាយក្មេក និងកូនប្រសា បងថ្លៃ ប្អូនថ្លៃ (ខាងប្ដី ឬខាងប្រពន្ធ)។ល។ ហេតុនេះនៅពេលដែលសហព័ទ្ធបានលែងលះគ្នា ទំនាក់ទំនងញាតិពន្ធ ត្រូវបានបញ្ចប់ [118] ចាប់ពីសេចក្ដីសម្រេចរបស់តុលាការចូលជាស្ថាពរ។

## ៤.២. ការបែងចែកទ្រព្យសម្បត្តិ

ការលែងលះនឹងកើតមានឡើងដែលធ្វើឱ្យមានការបែងចែកទ្រព្យសម្បត្តិរបស់សហព័ទ្ធ។ ការបែងចែកទ្រព្យសម្បត្តិមានពីរគឺ ការបែងចែក (៤.២.១.) ទ្រព្យសម្បត្តិអកម្ម និង(៤.២.២.) ទ្រព្យសម្បត្តិសកម្ម។

### ៤.២.១. ទ្រព្យសម្បត្តិអកម្ម

ទ្រព្យសម្បត្តិអកម្ម សំដៅទៅលើបំណុលគ្រួសារទាំងឡាយណាដែលសហព័ទ្ធទាំងពីរបានបង្កើតឡើងក្នុងគោលបំណងដើម្បីជីវភាពក្នុងគ្រួសារ និងការសិក្សាអប់រំកូនចៅរបស់ពួកគេ។ មួយវិញទៀតប្រសិនបើបំណុលនោះបង្កើតឡើងដោយសហព័ទ្ធតែម្ខាង ក្នុងគោលបំណងនៃផលប្រយោជន៍គ្រួសារ ក៏នឹងបង្កើតជាបំណុលគ្រួសារផងដែរ។ ដូចនេះនៅពេលលែងលះសហព័ទ្ធត្រូវធ្វើការសងបំណុលរួមគ្នា ដោយវាជាការទទួលខុសត្រូវដោយសាមគ្គីភាពរវាងប្ដីប្រពន្ធចំពោះម្ចាស់បំណុល។

មួយវិញទៀតចំពោះបំណុលដែលកើតឡើងដោយសហព័ទ្ធតែម្ខាង ក្នុងគោលបំណងដើម្បីបម្រើផលប្រយោជន៍ដោយខ្លួនឯងដូចជា ការផឹកស្រា ការលេងល្បែងស៊ីសង ជាអាទិ៍ ទោះបីបំណុលនោះមុន ឬក្រោយអាពាហ៍ពិពាហ៍ក៏ដោយ បំណុលនោះមិនចាត់ចូលជាបំណុលគ្រួសារឡើយ វាជាបំណុលដោយឡែក នោះភាគីម្ខាងៗត្រូវទទួលខុសត្រូវលើបំណុលនោះរៀងៗខ្លួន។

### ៤.២.២. ទ្រព្យសម្បត្តិសកម្ម

យោងតាមក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ តុលាការត្រូវធ្វើការបែងចែកទ្រព្យសម្បត្តិសកម្មជាពីរ រួមមាន៖ (៤.២.២.១.) ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា និង(៤.២.២.២.) ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់។

[117] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, សន្ទានុក្រម លេខ១៥០។
[118] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៤១។

**៤.២.២.១. ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា**

ប្តីប្រពន្ធ អាចធ្វើកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិ នៅមុន ឬក្រោយអាពាហ៍ពិពាហ៍បាន។[119] កិច្ចសន្យាទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធត្រូវធ្វើឡើង ដើម្បីទប់ស្កាត់វិវាទលើទំនាក់ទំនងទ្រព្យសម្បត្តិ និងដើម្បីបញ្ជាក់ឱ្យច្បាស់អំពីសិទ្ធិ និង ករណីយកិច្ចរបស់ប្តីប្រពន្ធ។ កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវធ្វើជាលាយលក្ខណ៍អក្សរព្រមទាំងចុះបញ្ជីនៅក្រសួងយុត្តិធម៌។[120] នៅពេលលែងលះ ប្រសិនបើប្តីប្រពន្ធបានធ្វើកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិ នោះតុលាការនឹងធ្វើការបែងចែកទ្រព្យសម្បត្តិដោយផ្អែកលើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនោះ។

**៤.២.២.២. ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់**

យ៉ាងណាមិញ បើភាគីលែងលះ មិនអាចពិភាក្សាគ្នាចុះសម្រុងលើការព្រមព្រៀង បែងចែកទ្រព្យសម្បត្តិ និងមិនបានបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិជាមួយគ្នានោះទេ នោះតុលាការមានសិទ្ធិបែងចែកទ្រព្យសម្បត្តិទាំងនេះតាមបណ្តឹងទាមទារ ដោយអនុលោមតាមការកំណត់នៅក្នុងច្បាប់រដ្ឋប្បវេណី។[121] ការបែងចែកទ្រព្យសម្បត្តិរវាងប្តីប្រពន្ធនេះ ច្បាប់បានកំណត់ទ្រព្យសម្បត្តិជា ពីរប្រភេទរួមមាន៖ ក.ទ្រព្យសម្បត្តិរួម និង ខ.ទ្រព្យសម្បត្តិដោយឡែក។

**ក. ទ្រព្យសម្បត្តិរួម**

ទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិទាំងឡាយ ដែលប្តីប្រពន្ធទាំងសងខាង ឬតែម្ខាងទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ លើកលែងតែទ្រព្យសម្បត្តិដែលច្បាប់កំណត់ថាជាទ្រព្យសម្បត្តិដោយឡែក។ [122] នៅពេលលែងលះ សហព័ទ្ធនីមួយៗ មានសិទ្ធិទទួលយក ១ ភាគ ២ (មួយភាគពីរ) នៃទ្រព្យសម្បត្តិរួម។ ជាក់ស្តែងក្នុងសង្គមបច្ចុប្បន្ន ប្តីតែងតែជាអ្នកទៅប្រកបការងារនៅខាងក្រៅ ចំណែកប្រពន្ធជាអ្នករ៉ាប់រងការងារផ្ទះ។ ដែលការងារមេផ្ទះនេះ ក៏មានតម្លៃស្មើគ្នា នឹងកម្រៃដែលបានមកពីការងារធ្វើការនៅខាងក្រៅដែរ។[123] ហេតុនេះនៅពេលលែងលះ ទ្រព្យសម្បត្តិរួមត្រូវធ្វើការបែងចែកជាពីរចំណែកស្មើគ្នា។ ប៉ុន្តែបើមានករណីពិសេស និងមានការទាមទាររបស់ប្តីប្រពន្ធណាម្ខាង តុលាការក៏អាចបែងចែកទ្រព្យសម្បត្តិរួម ដោយពិចារណាទៅលើស្ថានភាពផ្សេងៗ ដូចជា ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ទំហំនៃការបរិច្ចេករបស់ភាគីនីមួយៗចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ការបង្កើនទ្រព្យក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ កម្រិតជីវភាពរស់នៅក្នុងពេលមានចំណង

[119] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៦៩។

[120] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧០។

[121] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៣៨ (២)។

[122] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧៣។

[123] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៣៦។

អាពាហ៍ពិពាហ៍ អាយុ ស្ថានភាពផ្លូវចិត្ត និងផ្លូវកាយ វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគីនីមួយៗ និងផលប្រយោជន៍របស់កូនជាអាទិ៍។[124]

**ខ. ទ្រព្យសម្បត្តិដោយឡែក**

ទ្រព្យសម្បត្តិដោយឡែក ជាទ្រព្យសម្បត្តិដែលសហព័ទ្ធមាន នៅមុនពេលរៀបអាពាហ៍ពិពាហ៍។ ទ្រព្យសម្បត្តិ ដែលសហព័ទ្ធទទួលបាន ដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាន នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។ ឬ ជាទ្រព្យសម្បត្តិជាតម្លៃតប ដែលទទួលបានពីទ្រព្យដោយឡែករបស់សហព័ទ្ធ នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។[125] នៅពេលលែងលះ សហព័ទ្ធនីមួយៗ ត្រូវទទួលបានទ្រព្យសម្បត្តិដោយឡែករបស់ខ្លួនវិញ។[126]

## ៤.៣. ការប្រគល់អំណាចមេបា

ក្នុងករណីមានការលែងលះ តុលាការត្រូវតែកំណត់ពីអ្នកមានអំណាចមេបា ដោយឆន្ទានុសិទ្ធិ ពោលគឺ ទោះបីមិនមានពាក្យសុំពីភាគីក៏ដោយ។[127] ការសម្រេចអំពីអ្នកមានអំណាចមេបា នៅពេលលែងលះ បើឪពុកម្តាយលែងលះគ្នា ត្រូវកំណត់យកឪពុក ឬម្តាយណាម្ខាង ជាអ្នកមានអំណាចមេបា តាមការពិភាក្សារបស់ឪពុកម្តាយ។[128] ក្នុងករណីដែលភាគីមិនអាចពិភាក្សាបានទេ តុលាការត្រូវកំណត់អ្នកមានអំណាចមេបា ដោយធ្វើការពិចារណាទៅលើផលប្រយោជន៍របស់កូន។[129]

មួយវិញទៀតក្នុងករណីដែលឪពុកម្តាយបានលែងលះគ្នានៅមុនកំណើតរបស់កូន ម្តាយគឺជាអ្នកមានអំណាចមេបាចំពោះកូនដែលកើតមកនោះ។ ប៉ុន្តែនៅក្រោយកំណើតរបស់កូន អាចកំណត់យកឪពុកជាអ្នកមានអំណាចមេបា តាមការពិភាក្សារបស់ឪពុកម្តាយបាន។[130]

ចំពោះភាគីដែលមិនមានអំណាចមេបាលើកូន គាត់មានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងកូន និងករណីយកិច្ចទទួលបន្ទុកលើសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន។ ម្យ៉ាងទៀត ពាក់ព័ន្ធនឹងការសម្រេចសេចក្តីពីការចូលជួប និងប្រាស្រ័យទាក់ទង ក្រមរដ្ឋប្បវេណីតម្រូវឱ្យតុលាការធ្វើការពិចារណាទៅលើផលប្រយោជន៍របស់កូនជាអាទិភាព។ ក្នុងន័យនេះតុលាការអាចពិនិត្យពិចារណាទៅលើស្ថានភាពផ្សេងៗ ដូចជា ទំនាក់ទំនងរវាងកូន និងឪពុកម្តាយនៅពេលដែលរស់នៅជាមួយគ្នា អាយុ ស្ថានភាព សុខភាព ស្ថានភាពរបស់កូន បំណង

[124] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៨០ (២)។
[125] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧៣។
[126] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៨០ (២)។
[127] ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/០៦១០/០០៨, ០៨ មិថុនា ២០១០, មាត្រា២២ (១)។
[128] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០៣៧ (១)។
[129] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០៣៧ (៣)។
[130] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០៣៧ (២)។

របស់កូន បំណងរបស់ភាគីទាំងសងខាង ព្រមទាំងស្ថានភាពផ្លូវចិត្តរបស់ភាគីទាំងសងខាងជាដើម។ គប្បីគូសបញ្ជាក់ថា ទាក់ទងនឹងការសម្រេចសេចក្តីពីការកំណត់អ្នកមានអំណាចមេបា តុលាការត្រូវតែពិចារណាថ្លឹងថ្លែងទៅលើយោបល់របស់កូន សមស្របទៅតាមអាយុ និងសភាពចាស់ទុំរបស់កូន។[131] តុលាការក៏អាចផ្លាស់ប្តូរអ្នកមានអំណាចមេបាតាមការទាមទាររបស់ញាតិនៅក្នុង ៤ ថ្នាក់របស់កូនបាន ប្រសិនបើទទួលស្គាល់ថាចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន។[132]

## ៤.៤. ការផ្តល់អាហារកាតព្វកិច្ច

អាហារកាតព្វកិច្ច គឺសំដៅទៅលើកិច្ច ដែលត្រូវតែបំពេញតាមផ្លូវច្បាប់ ឬតាមតាមសេចក្តីសម្រេចរបស់តុលាការ ដែលតម្រូវឱ្យបុគ្គលម្នាក់ ឬច្រើននាក់ផ្តល់នូវប្រាក់ ឬទ្រព្យដើម្បីផ្គត់ផ្គង់ជីវភាពរស់នៅដល់បុគ្គលផ្សេងទៀត ដែលមានទំនាក់ទំនងញាតិនឹងគ្នា។[133] ជាទូទៅនៅពេលលែងលះ គូភាគីអាចធ្វើការពិភាក្សាអំពីការផ្តល់អាហារកាតព្វកិច្ចបាន ប៉ុន្តែក្នុងករណីដែលពិភាក្សាគ្នាមិនបានសម្រេចទេ ភាគីអាចដាក់ពាក្យសុំទាមទារ ហើយតុលាការអាចសម្រេចឱ្យបានផងដែរ។ ការផ្តល់អាហារកាតព្វកិច្ចនេះផងដែរ រួមមាន៖ (៤.៤.១.) អាហារកាតព្វកិច្ចចំពោះកូន និង (៤.៤.២) អាហារកាតព្វកិច្ចចំពោះសហព័ទ្ធ។

### ៤.៤.១. អាហារកាតព្វកិច្ចចំពោះកូន

ក្នុងករណីលែងលះ ឪពុក ឬម្តាយ ដែលមានអំណាចមេបាទៅលើកូន ត្រូវមានកាតព្វកិច្ចចិញ្ចឹមបីបាច់ថែរក្សាកូន និងជួយគ្រប់គ្រងលើកូន។[134] យោងតាមមាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បានកំណត់ថា "សិទ្ធិ និងករណីយកិច្ចរបស់ឪពុក ឬម្តាយ ដែលមិនរស់នៅជាមួយកូន នៅក្រោយពេលលែងលះ ត្រូវមានករណីយកិច្ចទទួលបន្ទុកសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន"។ ដូចនេះក្រោយការលែងលះ ឪពុក និងម្តាយនៅតែមានកាតព្វកិច្ចក្នុងការផ្តល់អាហារកិច្ចដល់កូនរបស់ខ្លួនដដែល ពីព្រោះឪពុក ឬម្តាយដែលបានលែងលះរួចហើយនោះ គឺនៅតែជាញាតិខ្សែផ្ទាល់របស់កូនជានិច្ច។[135] ជាទូទៅ បន្ទុកសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូនគិតចាប់ពីពេលសេចក្តីសម្រេចលែងលះចូលជាស្ថាពរ រហូតកូនដល់នីតិភាព។

### ៤.៤.២. អាហារកាតព្វកិច្ចចំពោះសហព័ទ្ធ

នៅក្នុងមាត្រា ៧៦, មាត្រា ៧៧ និងមាត្រា ៧៩ រហូតដល់មាត្រា ៨១ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩ បានកំណត់ថា ប្រសិនបើករណីមានការលែងលះ ភាគីដែលគ្មាន

---

[131] ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/០៦១០/០០៨, ០៨ មិថុនា ២០១០, មាត្រា២២ (៤)។

[132] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០៤០ (៤)។

[133] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, សទ្ទានុក្រម លេខ២០២។

[134] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១០៣៤។

[135] ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៤០។

កំហុស ឬ មានការខ្វះខាត បានសេចក្តីថា ភាគីដែលគ្មានកំហុសពុំមានទ្រព្យសម្បត្តិ ឬមុខរបរជាក់លាក់សម្រាប់ចិញ្ចឹមជីវិតខ្លួន អាចស្នើសុំអាហារកិច្ចពីភាគីម្ខាងទៀតបាន ទៅតាមលទ្ធភាពរបស់ភាគីនោះ ឬតាមការព្រមព្រៀងរបស់ភាគី ហើយប្រសិនបើភាគីមិនឯកភាពគ្នា នោះតុលាការនឹងជាអ្នកសម្រេចអំពីអាហារកិច្ចនោះ។ ក្នុងករណីនេះតុលាការត្រូវពិនិត្យពិចារណាទៅលើប្រាក់បៀវត្ស លទ្ធភាពនៃការរកប្រាក់ចំណូល អាយុ សុខភាពរបស់ជននោះដើម្បីកំណត់ពីកម្រិតនៃអាហារកិច្ចដែលត្រូវបង់។ ក៏ប៉ុន្តែប្រសិនបើជនដែលទទួលអាហារកិច្ចរៀបអាពាហ៍ពិពាហ៍ជាថ្មីទៀត ជននោះនឹងលែងទទួលបានអាហារកិច្ចបន្តទៀតហើយ។

### ៤.៥. ការចុះបញ្ជីអំពីការលែងលះ

ក្នុងករណីដែលសេចក្តីសម្រេចអំពីការលែងលះ បានចូលជាស្ថាពរ អ្នកដាក់ពាក្យសុំទៅតុលាការត្រូវរាយការណ៍ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ-សង្កាត់ដែលអ្នកដាក់ពាក្យសុំទៅតុលាការរស់នៅ ដោយភ្ជាប់ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសេចក្តីសម្រេចរបស់តុលាការនោះ និងសេចក្តីបញ្ជាក់អំពីថ្ងៃដែលសេចក្តីសម្រេចរបស់តុលាការនោះ បានចូលជាស្ថាពរក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ដោយគិតចាប់ពីថ្ងៃដែលសេចក្តីសម្រេចរបស់តុលាការនោះបានចូលជាស្ថាពរ។ បន្ទាប់ពីសេចក្តីសម្រេចរបស់តុលាការ បានចូលជាស្ថាពរក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងរាជធានីខេត្ត ក៏ត្រូវធ្វើការជូនដំណឹងអំពីសេចក្តីសម្រេចនោះទៅតុលាការមន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្តដែលសាលាដំបូងស្ថិតនៅ។ មួយវិញទៀតក្នុងករណីដែលសេចក្តីសម្រេចនោះចូលជាស្ថាពររយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៅសាលាឧទ្ធរណ៍ ឬតុលាការកំពូលដែលចេញសេចក្តីសម្រេចនោះ ត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនោះទៅមន្ត្រីអត្រានុកូលថ្នាក់ជាតិ។[136]

លើសពីនេះក្រោយពីបានទទួលបានការរាយការណ៍ ឬការជូនដំណឹងពីការចុះបញ្ជីអំពីការលែងលះ មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចត្រូវធ្វើ ការពិនិត្យនិងផ្ទៀងផ្ទាត់ព័ត៌មាននោះទៅនឹងបញ្ជីអាពាហ៍ពិពាហ៍របស់សាមីជនទាំង២ (ពីរ) នាក់ និងត្រូវចុះនិទ្ទេសនៅក្នុងបញ្ជីអាពាហ៍ពិពាហ៍នោះ។[137]

[136] ច្បាប់ស្តីពីអត្រានុកូលដ្ឋានស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម, លេខ នស/រកម/០៧២៣/០០៩, ០១ កក្កដា ២០២៣, មាត្រា៧៨។
[137] ច្បាប់ស្តីពីអត្រានុកូលដ្ឋានស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម, លេខ នស/រកម/០៧២៣/០០៩, ០១ កក្កដា ២០២៣, មាត្រា៧៩។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការសិក្សាស្រាវជ្រាវ និងបកស្រាយ ក្រោមធានបទ " **ការលែងលះរវាងពលរដ្ឋខ្មែរ និង ពលរដ្ឋខ្មែរនៅប្រទេសកម្ពុជា** " រួចមក យើងខ្ញុំយល់ឃើញថា ការរៀបអាពាហ៍ពិពាហ៍ រហូតបង្កើតបាន ជាគ្រួសារមួយជាមួយគ្នានេះដែរ ពាក្យថាគ្រួសារ គឺជាការរស់នៅរបស់មនុស្សពីរនាក់ ឬមួយក្រុម ក្នុងន័យ ស្រឡាញ់គ្នា ដោយទទួលបន្ទុកមើលថែរក្សាការពារគ្នាឱ្យជៀសផុតពីបញ្ហាផ្សេងៗ។ ហេតុនេះដើម្បីបង្កើតបាន ជាគ្រួសារមួយ បុរស និងស្ត្រីត្រូវតែឆ្លងកាត់ការរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាជាមុនសិន ដោយគោរពទៅតាម លក្ខខណ្ឌគតិយុត្ត និងស្របតាមប្រពៃណីឱ្យបានត្រឹមត្រូវ។ ជាមួយគ្នានេះដែរ បន្ទាប់ពីបានរៀបអាពាហ៍ពិពាហ៍ ស្របតាមលក្ខខណ្ឌគតិយុត្តហើយនោះ បុរស និងស្ត្រី ត្រូវទៅចុះសំបុត្រអាពាហ៍ពិពាហ៍ (អេតាស៊ីវិល) ទើបបុរស និងស្ត្រីនឹងក្លាយជាប្តីប្រពន្ធស្របតាមច្បាប់។ ហើយសង្ឃឹមថានឹងអាចរស់នៅជាមួយគ្នាយ៉ាងមានសេចក្តីសុខ ព្រោះមានគោលដៅតែមួយគឺស្រឡាញ់គ្នាដោយចិត្តស្មោះឱ្យតម្លៃចំពោះគ្នាទៅវិញទៅមក ចាប់ដៃគ្នារកស៊ីធ្វើការ ដើម្បីជីវភាពមួយដ៏សមរម្យ និងថ្លៃថ្នូរ ហើយអ្វីដែលកាន់តែវិសេសវិសាលគឺ មានគ្រួសារទាំងសងខាងគាំទ្រ និង លើកទឹកចិត្តយ៉ាងពេញទំហឹង។ ប៉ុន្តែពេលខ្លះគ្រួសារមួយចំនួន តែងតែមានការរកាំរកូសនឹងគ្នា ដែលជាហេតុ ធ្វើឱ្យរស់នៅជាមួយគ្នា មិនចុះសម្រុងនឹងគ្នា និងគ្មានសុភមង្គលដែលឈានដល់ការបែកបាក់គ្នា។ ហេតុនេះ ពេលរស់នៅមិនចុះសម្រុងនឹងគ្នាហើយនោះ ដែលជាហេតុនាំឱ្យមានការលែងលះកើតឡើងមកក្នុងគ្រួសារជា មិនខាន។

ជាពិសេសយើងខ្ញុំសង្កេតឃើញថា មូលហេតុដែលនាំឱ្យកើតមាននូវការលែងលះនេះកើតឡើងនោះ អាចបណ្តាលមកពីកត្តាជាច្រើនដែលនាំឱ្យមានការផ្តាច់នូវចំណងអាពាហ៍ពិពាហ៍របស់ប្តីប្រពន្ធ ដែលបាន រៀបអាពាហ៍ពិពាហ៍ជាមួយគ្នាដោយស្របច្បាប់។ ក៏ប៉ុន្តែប្រសិនបើការលែងលះនោះកើតឡើងពីការបង្ហាញពីឆន្ទៈ ចង់លែងលះដោយព្រមព្រៀងក្តី ឬការលែងលះដោយគ្មានការព្រមព្រៀងក្តី សុទ្ធតែអាចធ្វើការលែងលះបាន ក្នុងករណីដែលសហព័ទ្ធទាំងពីរពិតជារស់នៅមិនចុះសម្រុងនឹងគ្នា និងអស់មនោសញ្ចេតនារវាងគ្នា ឬ ដោយសារ មូលហេតុផ្សេងទៀតដែលនាំឱ្យចំណងអាពាហ៍ពិពាហ៍មិនអាចបន្តទៀតបាន។ ហេតុនេះចំណងអាពាហ៍ពិពាហ៍ នឹងត្រូវបានរលត់ទៅតាមច្បាប់ និងមានសុពលភាពគ្រប់គ្រាន់ក្នុងការអនុវត្ត កាលណាភាគីម្ខាងបានដាក់ ពាក្យសុំលែងលះ ចំពោះការលែងលះដោយការព្រមព្រៀង និងការដាក់ពាក្យបណ្តឹងលែងលះ ចំពោះការលែងលះ ដោយគ្មានការព្រមព្រៀង ទៅកាន់តុលាការជាដាច់ខាត បើមិនដូច្នេះទេ ចំណងអាពាពាហ៍មិនអាចរំលាយបាន ឡើយ។

ជាក់ស្តែងពេលដែលគ្រួសារមួយរស់នៅមិនចុះសម្រុងនឹងគ្នាហើយនោះ ច្បាស់ហើយថាពិតជាពិបាក ក្នុងការផ្សះផ្សាឱ្យជានានឹងគ្នាវិញណាស់ ព្រោះពេលខ្លះអាចភាគីខាងប្តី ឬខាងប្រពន្ធបានបង្កើតនូវកំហុសដ៏ធំ

មួយដែលភាគីណាមួយមិនអាចទទួលយក និងលើកលែងពីកំហុសនោះបាន នេះក៏ជាហេតុដែលនាំឱ្យកើតមាននូវការលែងលះមួយផងដែរ។ ដូចយើងដឹងស្រាប់ហើយថា ការលែងលះមិនមែនជារឿងដែលគ្រួសារនីមួយៗគិតថានឹងអាចដើរដល់ចំណុចមួយនេះទេ ព្រោះប្រសិនបើមានកូនអាចមានផលប៉ះពាល់ជាច្រើនចំពោះកូនដូចជាៈ បាត់បង់ភាពកក់ក្តៅពីឪពុកម្តាយ មិនបានមើលថែរក្សាកូនៗបានដិតដល់ គ្មានការអប់រំច្បាស់លាស់ បាក់ទឹកចិត្តក្នុងការសិក្សារៀនសូត្រ ជាក្មេងដែលមិនទទួលបានការណែនាំ និងប្រៀនប្រដៅពីឪពុកម្តាយ ដែលជាហេតុអាចនាំឱ្យកូនបាត់បង់ទំនុកចិត្ត និងភាពកក់ក្តៅពីឪពុកម្តាយ ដែលអាចធ្វើឱ្យកូនប្រឈមមុខនឹងការដើរក្នុងផ្លូវខុសបាន។

ទោះបីជាការលែងលះបានបន្សល់ទុកនូវផលលំបាកជាច្រើនក៏ដោយ ក៏ការកាត់ផ្តាច់នូវចំណងអាពាហ៍ពិពាហ៍តែងតែមានគុណសម្បត្តិមួយចំនួនផងដែរ ដែលបន្សល់ទុកបន្ទាប់ពីមានការលែងលះ។ ជាក់ស្តែងបើក្នុងគ្រួសារមួយដែលមានប្តី ឬប្រពន្ធ ដែលមានចរិតលក្ខណៈ ពាលា ដើរលេងដាច់យប់ លេងល្បែងស៊ីសងសេពគ្រឿងស្រវឹង និងគ្រឿងញៀនជាអាទិ៍ នោះជាហេតុផលដែលនាំឱ្យជីវិតគ្រួសាររស់នៅគ្មាន សុភមង្គលនោះឡើយ។ ក្នុងករណីនេះ ប្រសិនបើគ្រួសារមួយដែលរស់នៅដោយមានប្តី ឬក៏ប្រពន្ធ បានប្រព្រឹត្តនូវទង្វើបែបនេះនោះស្ថានភាពនៅក្នុងគ្រួសារពិតណាស់ពិតជាមិនអាចបន្តទៅមុខទៀតបានឡើយ។

ទន្ទឹមនឹងនេះ ការលែងលះបានជះផលវិបាកជាច្រើនចំពោះទំនាក់ទំនងក្នុងសង្គម។ បើសិនជានៅក្នុងសង្គមមួយដែលសម្បូរទៅដោយការលែងលះ នោះពួកគេនឹងជួបនូវបញ្ហាច្រើន ជាពិសេសផលវិបាក ដែលមានទៅលើស្មារតីរបស់កូនដែលជាទំពាំងស្នងឬស្សី។ យើងខ្ញុំសង្ឃឹមយ៉ាងជាក់លាក់ថា ប្រជាពលរដ្ឋនៅប្រទេសកម្ពុជានឹងរក្សាគោលជំហរយ៉ាងមុតមាំង ក្នុងការកសាងសុភមង្គលក្នុងគ្រួសារជារៀងរហូតទៅ។

សរុបសេចក្តីមក ការលែងលះរវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរនៅកម្ពុជា មិនថាការលែងលះដោយការព្រមព្រៀង ឬការលែងលះដោយគ្មានការព្រមព្រៀងក៏ដោយក៏នៅតែឆ្លងកាត់នីតិវិធីនៅតុលាការ។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីបានសិក្សាស្រាវជ្រាវអំពីប្រធានបទ "**ការលែងលះរវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរនៅប្រទេសកម្ពុជា**" រួចមក យើងខ្ញុំយល់ឃើញថា ការលែងលះ ពិតជាមានភាពស្មុគស្មាញ ក៏ដូចជាផ្តល់គុណវិបត្តិជាច្រើន ដល់ភាគីបណ្តឹង និងកូនៗថែមទៀតផង។ ព្រោះនៅពេលដែលមានការលែងលះកើតឡើង ភាគីនៃបណ្តឹងនឹងខាតបង់ផលប្រយោជន៍ដូចជា ខាតបង់ពេលវេលា ខាតបង់ទ្រព្យសម្បត្តិ ក៏ដូចជាសុភមង្គលក្នុងគ្រួសារផងដែរ ចំណែកកូនៗត្រូវរស់នៅទាំងគ្មានភាពកក់ក្តៅពីឪពុកម្តាយ ពេលខ្លះអាចឈានដល់ការមានជម្ងឺបាក់ទឹកចិត្តថែមទាំងផង។ មូលហេតុនេះហើយ ទើបយើងខ្ញុំសូមការអនុញ្ញាតលើកឡើងនូវអនុសាសន៍មួយចំនួន ទាក់ទងនឹងការលែងលះរវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរនៅប្រទេសកម្ពុជា។

- រាជរដ្ឋាភិបាល ក៏ដូចជាក្រសួងដែលពាក់ព័ន្ធ ត្រូវតែខិតខំប្រឹងប្រែងធ្វើយ៉ាងណាផ្សព្វផ្សាយច្បាប់ឱ្យបានទូលំទូលាយ ដើម្បីឱ្យប្រជាពលរដ្ឋមានការយល់ដឹងអំពីនីតិវិធីនៃការលែងលះ ព្រមទាំងអាចបង្កលក្ខណៈងាយស្រួលដល់ពួកគាត់ ព្រោះបច្ចុប្បន្ននេះ ប្រជាពលរដ្ឋមួយចំនួន នៅពុំទាន់បានយល់ច្បាស់ ក៏ដូចជានៅមានការភាន់ច្រឡំនៅឡើយ។
- សហព័ទ្ធទាំងអស់ គួរមេត្តាចេះយោគយល់ អត់ឱនឱ្យគ្នា ក៏ដូចជាអធ្យាស្រ័យគ្នាឱ្យបានច្រើន ព្រោះថានៅពេលដែលសហព័ទ្ធនីមួយៗធ្វើការលែងលះគ្នា នឹងផ្តល់នូវគុណវិបត្តិផ្សេងៗ ជាពិសេសសុភមង្គលក្នុងគ្រួសារ។
- អាជ្ញាធរមានសមត្ថកិច្ចក្នុងការដោះស្រាយវិវាទទាក់ទងនឹងការលែងលះ ជាពិសេសតុលាការមានសមត្ថកិច្ចមេត្តាដឹកនាំនីតិវិធីនៃការលែងលះ ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន ពីព្រោះប្រសិនបើការដោះស្រាយវិវាទមានភាពយឺតយ៉ាវអាចបង្កលក្ខណៈលំបាកដល់ភាគីនៃបណ្តឹង ជាពិសេសគឺកូនៗជាម្តង។

# ឯកសារយោង

# ឯកសារយោង

## ១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣។
- ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។
- ក្រមរដ្ឋប្បវេណី, លេខ នស/១២០៧/០៣០, ០៨ ធ្នូ ២០០៧។
- ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩។
- ច្បាប់ស្តីគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, លេខ នស/រកម/០៣០១/០៥, ១៩ មីនា ២០០១។
- ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ, លេខ នស/រកម/១០០៥/០៣១, ២៤ តុលា ២០០៥។
- ច្បាប់ស្តីពីឯកពន្ធភាព, លេខ នស/រកម/១០០៦/០២៦, ២១ តុលា ២០០៦។
- ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០។
- ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/០៦១០/០០៨, ០៨ មិថុនា ២០១០។
- ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, លេខ នស/រកម/០៥១១/០០៧, ៣១ ឧសភា ២០១១។
- ច្បាប់ស្តីពីអគ្រានុកូលដ្ឋានស្ថិតិអគ្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម, លេខ នស/រកម/០៧២៣/០០៩, ០១ កក្កដា ២០២៣។
- ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, លេខ ៨១.កយ.ស្រក/១៣, ០៩ សីហា ២០១៣។
- ប្រកាសស្តីពីការកែសម្រួលឧបសម្ព័ន្ធ១ និងឧបសម្ព័ន្ធ២ នៃប្រកាសលេខ ២៨ កយ ប្រក, ០៧ , ១៧ កក្កដា ២០០៧ ស្តីពីប្រភេទពាក្យសុំដែលតម្រូវឱ្យបង់ពន្ធ ចំនួនទឹកប្រាក់ នៃពន្ធដាក់ពាក្យ និងចំនួនពន្ធដែលត្រូវបង់ដើម្បីធ្វើសកម្មភាពក្រៅពីពាក្យសុំទៅតុលាការឱ្យសម្រេចសេចក្តី និងមាត្រដ្ឋានសម្រាប់គណនាប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ និងតម្លៃកម្មវត្ថុនៃបណ្តឹង, លេខ៥៤ កយ ប្រក/០៩, ចុះថ្ងៃទី២២ មិថុនា ២០០៩។

## ២.សៀវភៅ និងឯកសារយោង

- សៀវភៅស្តីពីការពន្យល់អំពីនីតិវិធីជម្រះក្តីលើកទី១ ឆ្នាំ២០០៩។
- លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត សៀវភៅជំនួយស្មារតី នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ ឆ្នាំ២០១៧។
- គណៈកម្មាការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង ក្រុមការងារជប៉ុនដែលទទួលបន្ទុកលើសេចក្តីព្រាងក្រមរដ្ឋប្បវេណី ២០១០, សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ២ ភ្នំពេញ៖ ក្រសួងយុត្តិធម៌។

## ៣. ប្រភពផ្សេងៗ

- សន្ធានុក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។
- សាលាត្រាជូ, អត្ថបទសាកល្បងស្តីពី លក្ខខណ្ឌនៃការលែងលះដោយការព្រមព្រៀង, ដកស្រង់ចេញពី file:///C:/Users/CP%20computer/Downloads/Telegram%20Desktop/e19e8fe19f92e19e9ae19eb6e19e87e19ebc_e19e80e19eb6e19e9ae19e9be1.pdf

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១. ការលែងលះដោយការព្រមព្រៀង**

១. កិច្ចព្រមព្រៀងលែងលះ

២. លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ

៣. ពាក្យសុំតំណាងដោយអាណត្តិ

៤. ពាក្យសុំពិនិត្យ និងថតចម្លងសំណុំរឿង

៥. ពាក្យសុំលែងលះ

៦. បង្កាន់ដៃបង់ប្រាក់ថ្លៃដាក់ពាក្យសុំ

៧. ដីកាសម្រេចឱ្យបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ

៨. បង្កាន់ដៃបង់ពន្ធ

៩. លិខិតអញ្ជើញមេធាវី

១០. ដីកាកោះ (នីតិវិធីសាកសួរ)

១១. ដីកាសម្រេចរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

១២. លិខិតបញ្ជាក់ការចូលជាស្ថាពរនៃដីកាសម្រេច

១៣. បង្កាន់ដៃបង់ប្រាក់ថ្លៃដាក់លិខិតបញ្ជាក់ការចូលជាស្ថាពរនៃដីកាសម្រេច

**ឧបសម្ព័ន្ធទី២. ការលែងលះដោយគ្មានការព្រមព្រៀង**

១. ពាក្យបណ្តឹងលែងលះ

២. បង្កាន់ដៃបង់ប្រាក់ថ្លៃដាក់ពាក្យបណ្តឹង

៣. លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ

៤. លិខិតតំណាងដោយអាណត្តិ

៥. ពាក្យសុំពិនិត្យ និងថតចម្លងសំណុំរឿង

៦. ដីកាសម្រេចបង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ

៧. លិខិតអញ្ជើញមេធាវី (នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល)

៨. ដីកាកោះ (នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល)

៩. របាយការណ៍បញ្ជូន

១០. កំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

១១. សេចក្ដីថ្លែងការណ៍

១២. ពាក្យសុំបញ្ចូលភស្ដុតាង

១៣. ពាក្យសុំឱ្យកោះហៅសាក្សី

១៤. លិខិតអញ្ជើញមេធាវី (នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់)

១៥. ដីកាកោះ (នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់)

១៦. សាលក្រមលែងលះ

១៧. លិខិតចូលជាស្ថាពរនៃសាលក្រម

១៨. ពាក្យបណ្ដឹងឧទ្ធរណ៍

# ឧបសម្ព័ន្ធទី១

# ការលែងលះដោយការព្រមព្រៀង

# កិច្ចព្រមព្រៀងលែងលះ

រវាង

លោកស្រី

(ភាគី "ក")

និង

លោក

(ភាគី "ខ")

កាលបរិច្ឆេទៈ ថ្ងៃទី ខែ ឆ្នាំ

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀងលែងលះ

កិច្ចព្រមព្រៀងលែងលះនេះ ("**កិច្ចព្រមព្រៀង**") ត្រូវបានធ្វើឡើងនៅថ្ងៃទី ខែ ឆ្នាំ ដោយ និងរវាង៖

១. **លោកស្រី** សញ្ជាតិខ្មែរ កើតថ្ងៃទី ខែ ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ មានអាសយដ្ឋានស្ថិតនៅផ្ទះលេខ ផ្លូវ ភូមិ សង្កាត់ទួលស្វាយព្រៃទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ (តទៅនេះហៅថា **ភាគី** "**ក**") និង

២. **លោក** សញ្ជាតិខ្មែរ កើតថ្ងៃទី ខែ ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ មានអាសយដ្ឋានស្ថិតនៅផ្ទះលេខ ផ្លូវ ភូមិ សង្កាត់ផ្សារកណ្ដាលទី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ (តទៅនេះហៅថា **ភាគី** "**ខ**")។

ភាគីនីមួយៗហៅដោយឡែកពីគ្នាថា "**ភាគី**" និងហៅជារួមថា "**ភាគីទាំងអស់**" ឬ "**ភាគីទាំងពីរ**"។

## <u>បុព្វកថា</u>

**ដោយហេតុថា៖**

**ក.** ភាគីទាំងពីរបានរៀបអាពាហ៍ពិពាហ៍នឹងគ្នា ហើយទទួលបានសំបុត្រអាពាហ៍ពិពាហ៍លេខ ចុះថ្ងៃទី ខែ ឆ្នាំ ។ *ច្បាប់ថតចម្លងនៃសំបុត្រអាពាហ៍ពិពាហ៍ខាងលើ មានភ្ជាប់ជាឧបសម្ព័ន្ធ ១ នៃកិច្ចព្រមព្រៀងនេះ។*

**ខ.** ភាគីទាំងពីរបានបាត់បង់អស់នូវមនោសញ្ចេតនាចំពោះគ្នា និងមិនអាចរស់នៅចុះសម្រុងជាមួយគ្នាក្នុងនាមជាប្ដីប្រពន្ធតទៅទៀត។

## ហេតុដូចនេះ ភាគីទាំងពីរបានព្រមព្រៀងគ្នា ដូចខាងក្រោម៖

### ប្រការ ១ ៖ អំពីការលែងលះ

ភាគីទាំងពីរបានព្រមព្រៀងលែងលះគ្នាដោយគោលការណ៍ស្ម័គ្រចិត្តទាំងសងខាង និងដោយគ្មានការបង្ខិតបង្ខំអ្វីទាំងអស់ពីភាគីណាមួយនោះឡើយ។

### ប្រការ ២ ៖ អំពីកូន

**២.១** ភាគីទាំងពីរអះអាងថា ភាគីទាំងពីរ មានកូន ០២ នាក់ ដែលមានអត្តសញ្ញាណដូចខាងក្រោម៖

កុមារី ភេទស្រី សញ្ជាតិខ្មែរ កើតនៅថ្ងៃទី ខែ ឆ្នាំ នៅសង្កាត់ផ្សារកណ្ដាលទី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ប្រទេសកម្ពុជា ដែលបញ្ជាក់ដោយសេចក្ដីចម្លងសំបុត្រកំណើត ចុះថ្ងៃទី ខែ ឆ្នាំ ។

- កុមារា ភេទប្រុស សញ្ជាតិខ្មែរ កើតនៅថ្ងៃទី ខែ ឆ្នាំ នៅសង្កាត់ផ្សារកណ្តាលទី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ប្រទេសកម្ពុជា ដែលបញ្ជាក់ដោយសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ចុះថ្ងៃទី ខែ ឆ្នាំ ។

  *ច្បាប់ថតចម្លងនៃសេចក្តីចម្លងសំបុត្រកំណើត និង សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតខាងលើ មានភ្ជាប់ជាឧបសម្ព័ន្ធ ២ នៃកិច្ចព្រមព្រៀងនេះ។*

២.២ ភាគីទាំងពីរព្រមព្រៀងកំណត់អំពី សិទ្ធិអំណាចមេបា ដូចខាងក្រោម៖

- **ភាគី "ក"** ទទួលបាននូវសិទ្ធិអំណាចមេបាលើកូនប្រុសឈ្មោះ សញ្ជាតិខ្មែរ កើតនៅថ្ងៃទី ខែ ឆ្នាំ ។
- **ភាគី "ខ"** ទទួលបាននូវសិទ្ធិអំណាចមេបាលើកូនស្រីឈ្មោះ ភេទ សញ្ជាតិខ្មែរ កើតនៅថ្ងៃទី ខែ ឆ្នាំ ។

២.៣ ភាគីទាំងពីរព្រមព្រៀងគ្នាថា **ភាគី "ខ"** ត្រូវផ្តល់អាហារកាតព្វកិច្ច និងទំនុកបម្រុងសព្វគ្រប់បែបយ៉ាងដល់កូនទាំងពីរខាងលើ ចំណែកឯ **ភាគី "ក"** ត្រូវផ្តល់អាហារកាតព្វកិច្ច ដល់កូនទាំងពីរខាងលើ តាមលទ្ធភាពរហូតដល់កូនទាំងពីរនេះដល់នីតិភាព។

២.៤ ភាគីទាំងពីរព្រមព្រៀងគ្នាថា ភាគីនីមួយៗត្រូវបង្កលក្ខណៈងាយស្រួលដល់គ្នាទៅវិញទៅមក ក្នុងការចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនទាំងពីរខាងលើបាន ដោយមិនត្រូវធ្វើឱ្យប៉ះពាល់ដល់ទំនាក់ទំនងរវាងកូនទាំងពីរឡើយ។

## ប្រការ ៣ ៖ អំពីការបែងចែកទ្រព្យសម្បត្តិ និងការទទួលបំណុល

ភាគីទាំងពីរព្រមព្រៀងបែងចែកទ្រព្យសម្បត្តិ និងទទួលបំណុល ដូចខាងក្រោម៖

៣.១ **ភាគី "ក"** ត្រូវទទួលបាននូវទ្រព្យសម្បត្តិ និងទទួលបំណុល ដូចតទៅ៖

**ក. ភាគី "ក"** ត្រូវទទួលបាននូវទ្រព្យសម្បត្តិ ដូចខាងក្រោម៖

- ដីទំហំ $ម^2$ ( ម៉ែត្រការ៉េ) មានទីតាំងស្ថិតនៅភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ សម្គាល់ដោយវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ៖ ចុះថ្ងៃទី ខែ ឆ្នាំ ។

  *ច្បាប់ថតចម្លងនៃវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុខាងលើ មានភ្ជាប់ជាឧបសម្ព័ន្ធ ៣ នៃកិច្ចព្រមព្រៀងនេះ។*

- ភាគហ៊ុននៅក្នុងហាងកាហ្វេ សាខា ចំនួន % ( ភាគរយ) ត្រូវនឹងទឹកប្រាក់ចំនួន USD ( ដុល្លារអាមេរិក) មានទីតាំងស្ថិតនៅភូមិ មហាវិថី ខណ្ឌ រាជធានីភ្នំពេញ ដែលសម្គាល់ដោយលិខិតបញ្ជាក់ភាគហ៊ុនធ្វើឡើងកាលពីថ្ងៃទី ខែ ឆ្នាំ ។

*ច្បាប់ចតចម្លងនៃលិខិតបញ្ជាក់ភាគហ៊ុនខាងលើ មានភ្ជាប់ជាឧបសម្ព័ន្ធ ៤ នៃកិច្ចព្រមព្រៀងនេះ។*

**ខ. ភាគី "ក"** ត្រូវទទួលបំណុល ដូចខាងក្រោម៖

- បំណុលធនាគារ ចំនួន USD ( ដុល្លារអាមេរិក) ដែលបានខ្ចីយកមកទិញ ដី និង ផ្ទះ ទំហំ ម² ( ម៉ែត្រការ៉េ) មានទីតាំងស្ថិតនៅភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ដែលសម្គាល់ដោយវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ៖ ចុះថ្ងៃទី ខែ ឆ្នាំ ។
- បំណុលចំនួន USD ( ដុល្លារអាមេរិក) ដែលបានខ្ចីពីតតិយជន យកមកទិញភាគហ៊ុននៅក្នុងហាងកាហ្វេ មានទីតាំងស្ថិតនៅភូមិ មហាវិថី ខណ្ឌ រាជធានីភ្នំពេញ។

**៣.២ ភាគី "ខ"** ត្រូវទទួលបាននូវទ្រព្យសម្បត្តិ ដូចខាងក្រោម៖

- សិទ្ធិលើបំណុលជាប្រាក់ចំនួន USD ( ដុល្លារអាមេរិក) ដែល **ភាគី "ខ"** បានយកឱ្យតតិយជនខ្ចី។

## ប្រការ ៤៖ សិទ្ធិលើបំណុលទោងសហព័ន្ធ

ភាគីទាំងពីរអះអាងថា ពួកគេទាំងពីរពុំមានសិទ្ធិលើបំណុលចំពោះគ្នាទៅវិញទៅមកនោះទេ។

## ប្រការ ៥៖ ការរក្សាទុកកិច្ចព្រមព្រៀង

កិច្ចព្រមព្រៀងនេះធ្វើឡើងចំនួន ០៣ (បី) ច្បាប់ ដែលមួយច្បាប់រក្សាទុកនៅ **ភាគី "ក"** មួយច្បាប់រក្សាទុកនៅ **ភាគី "ខ"** និងមួយច្បាប់ទៀតរក្សាទុកនៅ ក្រុមមេធាវី ។

*(ផ្នែកដែលនៅសល់នៃទំព័រនេះត្រូវបានទុកឱ្យនៅទំនេរដោយចេតនា)*

**ដើម្បីជាសក្ខីភាព** ភាគីនីមួយៗចុះហត្ថលេខា និងផ្តិតស្នាមមេដៃ នៅកាលបរិច្ឆេទដែលបានកំណត់ខាងលើ។

| **ភាគី "ក"** | | **ភាគី "ខ"** | |
|---|---|---|---|
| **ហត្ថលេខា** | **ស្នាមមេដៃ** | **ហត្ថលេខា** | **ស្នាមមេដៃ** |
| ......................................... | | ......................................... | |
| **លោកស្រី** | | **លោក** | |

**បានឃើញ និងបញ្ជាក់ថា**

ភាគីទាំងពីរពិតជាបានចុះហត្ថលេខា និងផ្តិតស្នាមមេដៃ

នៅចំពោះមុខមេធាវីពិតប្រាកដមែន។

ធ្វើនៅថ្ងៃទី   ខែ   ឆ្នាំ

ព្រះរាជាណាចក្រកម្ពុជា មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

មេធាវី.

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# <u>លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ</u>

ខ្ញុំបាទឈ្មោះ ជនជាតិ កើតថ្ងៃទី ខែ ឆ្នាំ កាន់លិខិតឆ្លងដែន សញ្ជាតិ ចុះថ្ងៃទី ខែ ឆ្នាំ មានអាសយដ្ឋានស្ថិតនៅ ផ្ទះលេខ ផ្លូវ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ (**អាណត្តិទាយក**)។

## <u>សូមប្រគល់សិទ្ធិជូន</u>

លោកមេធាវី អត្តលេខ ជាមេធាវី នៃក្រុមមេធាវី ដែលមានការិយាល័យនៅផ្ទះលេខ ផ្លូវលេខ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ដើម្បីធ្វើជាអ្នកតំណាងដោយអាណត្តិរបស់ខ្ញុំបាទ នៅក្នុងរឿងក្តីលែងលះ។ តាមរយៈលិខិតប្រគល់សិទ្ធិនេះ លោកមេធាវី មានសិទ្ធិបំពេញរាល់កិច្ចការដូចខាងក្រោម៖

- មានសិទ្ធិអំណាចពេញលេញនៅក្នុងការធ្វើសកម្មភាពតំណាងឱ្យខ្ញុំបាទ។
- ដាក់ពាក្យបណ្តឹង ដាក់ពាក្យសុំ ដកពាក្យបណ្តឹង ដកពាក្យសុំ ផ្សះផ្សា សម្រុះសម្រួល បោះបង់ឬទទួលស្គាល់ការទាមទារ ឬ ដកខ្លួនចេញពីបណ្តឹងដែលខ្លួនចូលរួមអន្តរាគមន៍ ឬ ទទួលបណ្តឹងដើម្បីផលប្រយោជន៍ស្របច្បាប់របស់ខ្ញុំបាទ។
- ការតែងតាំងអនុតំណាង។
- ការប្តឹងតវ៉ា/ការប្តឹងទាស់/ការប្តឹងជំទាស់/ការប្តឹងឧទ្ធរណ៍/ការប្តឹងសាទុក្ខ។

**<u>បញ្ជាក់៖</u>** រាល់សោហ៊ុយចំណាយលើការអនុវត្តភារកិច្ចនេះ និងបង់ពន្ធផ្សេងៗនៅក្នុងបណ្តឹង ឬ ពាក្យសុំនេះ ជាបន្ទុករបស់ខ្ញុំបាទ។ ក្នុងករណីមិនបានគោរពតាមកាតព្វកិច្ចនេះ ខ្ញុំបាទសុខចិត្តទទួលខុសត្រូវនូវរាល់ការបាត់បង់ផលប្រយោជន៍នានាដោយខ្លួនឯងផ្ទាល់។

លិខិតប្រគល់សិទ្ធិនេះ មានអានុភាពចាប់ពីថ្ងៃផ្តិតស្នាមមេដៃនេះតទៅ ៕

ថ្ងៃទី ខែ ឆ្នាំ
**ស្នាមមេដៃស្តាំ**

បានឃើញ និងយល់ព្រម
ធ្វើជាមេធាវីតំណាងដោយអាណត្តិឱ្យ
លោក តាមនីតិវិធីច្បាប់។
ថ្ងៃទី ខែ ឆ្នាំ
**មេធាវី**

**លោក**

INTERNATIONAL
ក្រុមហ៊ុនមេធាវី ជីជី អន្តរជាតិ
GG International Law Firm
លេខ: ...... ...ជ.ជ.អ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង... ទទួល ថ្ងៃទី ២៩ ខែ ០៦ ឆ្នាំ ២០២៣ ម៉ោង ១ និង ២២ នាទី

ថ្ងៃ ឆ្នាំ ... បញ្ចស័ក ព.ស២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២៣

## ពាក្យសុំតំណាងដោយអាណត្តិ

ខ្ញុំមេធាវី អត្តលេខ: ជាសមាជិកនៃ **ក្រុមហ៊ុនមេធាវី ជីជី អន្តរជាតិ** ដែលមានអាសយដ្ឋានស្ថិតនៅអាគារលេខ: ផ្លូវលេខ ភូមិ សង្កាត់ ខណ្ឌមានជ័យ រាជធានីភ្នំពេញ និងជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងជាមេធាវីតំណាងដោយអាណត្តិឲ្យឈ្មោះ ក្នុងសំណុំរឿងរដ្ឋប្បវេណីមិនមែនជាបណ្តឹងលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

ទូរស័ព្ទទំនាក់ទំនងលេខ៖

### សូមគោរពចូលមក
### ឯកឧត្តមប្រធាន សាលាដំបូងរាជធានីភ្នំពេញ

**កម្មវត្ថុ** ៖ ស្តីពីការសុំតំណាងដោយអាណត្តិក្នុងសំណុំរឿងរដ្ឋប្បវេណីមិនមែនជាបណ្តឹងលេខ
ចុះថ្ងៃ ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

**យោង** ៖ -ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី
-ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា
-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិរបស់ឈ្មោះ
ចុះថ្ងៃទី ខែ ឆ្នាំ ។

តបតាមកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា៖ ឈ្មោះ បានប្រគល់សិទ្ធិឲ្យនាងខ្ញុំធ្វើជាមេធាវីតំណាងដោយអាណត្តិឲ្យរូបគាត់ នៅក្នុងសំណុំរឿងរដ្ឋប្បវេណីដូចដែលមានចែងក្នុងកម្មវត្ថុខាងលើ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមប្រធាន** មេត្តាទទួលស្គាល់នាងខ្ញុំ ជាមេធាវីតំណាងដោយអាណត្តិនៅក្នុងសំណុំរឿងរដ្ឋប្បវេណីខាងលើទៅតាមនីតិវិធីច្បាប់ដោយក្តីអនុគ្រោះ ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ។

**ហត្ថលេខា និងត្រា**
**មេធាវី**

ព្រះរាជាណាចក្រកម្ពុជា មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

មេធាវី

GG INTERNATIONAL
ក្រុមហ៊ុនមេធាវី ជីជី អន្តរជាតិ
GG International Law Firm
លេខ: ......................ក.ជ.ជ.អ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង...
ចូល លេខ...
ថ្ងៃ...
ម៉ោង...... និង...... នាទី

ថ្ងៃ ឆ្នាំ... បញ្ចស័ក ព.ស២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី..... ខែ ឆ្នាំ២០២៣

## ពាក្យសុំពិនិត្យ និងថតចម្លងសំណុំរឿង

ខ្ញុំមេធាវី អត្តលេខ សមាជិកនៃ **ក្រុមហ៊ុនមេធាវី ជីជី អន្តរជាតិ** ដែលមានអាសយដ្ឋានស្ថិតនៅអាគារលេខ ផ្លូវលេខ ភូមិ សង្កាត់ ខណ្ឌមានជ័យ រាជធានីភ្នំពេញ និងជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងជាមេធាវីតំណាងដោយអាណត្តិឲ្យឈ្មោះ ក្នុងសំណុំរឿងរដ្ឋប្បវេណីមិនមែនជាបណ្តឹងលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

ទូរស័ព្ទទំនាក់ទំនងលេខ៖

**<u>សូមគោរពចូលមក</u>**

**ឯកឧត្តមប្រធាន សាលាដំបូងរាជធានីភ្នំពេញ**

**<u>កម្មវត្ថុ</u>** ៖ សំណើសុំពិនិត្យ និងថតចម្លងសំណុំរឿងរដ្ឋប្បវេណីមិនមែនជាបណ្តឹងលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

**<u>យោង</u>** ៖ -មាត្រា២៥៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។
-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិរបស់ឈ្មោះ
ចុះថ្ងៃទី... ខែ ឆ្នាំ ។

តបតាមកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា៖ ឈ្មោះ បានប្រគល់សិទ្ធិឲ្យនាងខ្ញុំធ្វើជាមេធាវីតំណាងដោយអាណត្តិឲ្យរូបគាត់ នៅក្នុងសំណុំរឿងរដ្ឋប្បវេណីដូចដែលមានចែងក្នុងកម្មវត្ថុខាងលើ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមប្រធាន** មេត្តាអនុញ្ញាឲ្យនាងខ្ញុំបានពិនិត្យ និងថតចម្លងសំណុំរឿង រដ្ឋប្បវេណីខាងលើទៅតាមនីតិវិធីច្បាប់ដោយក្តីអនុគ្រោះ ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពស់អំពីនាងខ្ញុំ។

**...និងត្រា**

មេធាវី
AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA


GG International Law Firm
Registered under the Bar Association of the Kingdom of Cambodia
# 224D Street 20, Prek Talong Village, Sangkat Chak Angre Kroam, Khan Mean Chey, Phnom Penh, Cambodia
Phone: +855 93 337 626 , E-mail: official@ggi.law , web: www.ggi.law

គំរូលេខ 09 សហវ/ថមព

260-1- 00201963

MEF20882604121

ក្រសួងយុត្តិធម៌

# បង្កាន់ដៃបង់ប្រាក់

អង្គភាព ......សាលាដំបូងខេត្តតាកែវ......

(ប្រគល់ជូនអ្នកបង់ប្រាក់)

ទទួលពី .................................................. អង្គភាព ......[illegible]......

ចំនួនទឹកប្រាក់ជាលេខ ......៥,០០០៛......

ជាអក្សរ ......ប្រាំពាន់រៀល......

អត្ថន័យចំណូល ......[illegible]...... មាតិកាថវិកា ..........

ថ្ងៃទី.......... ខែ.......... ឆ្នាំ..........

អ្នកប្រមូលចំណូល

អេង សុខណ្ណារ៉ា

MINISTRY OF ECONOMY AND FINANCE

បង្កាន់ដៃនេះត្រូវបានបោះពុម្ព និងគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្របតាមអនុក្រឹត្យលេខ ៨២អនក្រ. ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ

លោក ស៊ាង ចាន់ពិសិដ្ឋ

ក្រឡាបញ្ជី បន្ទប់(ឃ) ជាន់ទី(៣)

# **ដីកាសម្រេច**

## **ឱ្យបង់ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ**

យើង **ឆឹម ឬទ្ធី** ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**បានឃើញ** មាត្រា ២២ ច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង។

**បានឃើញ** សំណុំរឿងរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ខែ ឆ្នាំ ដែលមាន៖

អ្នកដាក់ពាក្យសុំឈ្មោះ ភេទស្រី កើតថ្ងៃទី ខែ ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ មានទីលំនៅសព្វថ្ងៃ ភូមិ សង្កាត់ ក្រុង ខេត្ត ។

ដោយមានមេធាវី អត្តលេខ មានការិយាល័យនៅផ្ទះលេខ ផ្លូវ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

ភាគីម្ខាងទៀតឈ្មោះ ភេទ កើតថ្ងៃទី ខែ ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ មានទីលំនៅសព្វថ្ងៃ ផ្ទះលេខ ផ្លូវ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

**កម្មវត្ថុ៖** ប្ដឹងសុំលែងលះតាមព្រមព្រៀង។

## **សំអាងហេតុ**

ដើម្បីដំណើរការនីតិវិធី គប្បីឱ្យអ្នកដាក់ពាក្យសុំឈ្មោះ បង់ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធតាមបញ្ញត្តិមាត្រា ២២ ច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង។

## **ហេតុដូច្នេះសម្រេច**

១.បង្គាប់ឱ្យអ្នកដាក់ពាក្យសុំឈ្មោះ បង់ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធជាប្រាក់ចំនួន ១០០.០០០ (មួយសែន)រៀល នៅសាលាដំបូងរាជធានីភ្នំពេញ ត្រឹមថ្ងៃទី ខែ ឆ្នាំ ជាកំណត់ ដើម្បីតុលាការចាត់ការរឿងក្ដីនេះតាមច្បាប់។

២.ក្នុងករណីមិនអនុវត្តត្រង់ចំណុចទី១ នៃសេចក្ដីសម្រេចខាងលើនេះ និងលើកបណ្ដឹងចោលតាមច្បាប់។

ថ្ងៃ ខែ ឆ្នាំ ព.ស.

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ

**ចៅក្រម**

**ឆឹម ឬទ្ធី**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
៣៣៣ ✵ ១១១

**សាលាដំបូងរាជធានីភ្នំពេញ**

សំណុំរឿងរដ្ឋប្បវេណីមិនមែនបណ្តឹងលេខ
ចុះថ្ងៃទី ខែ ឆ្នាំ

## <u>លិខិតអញ្ជើញមេធាវី</u>

យើង **ឌីង គឹមពិសាល** ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

- បានឃើញ លិខិតតំណាងដោយអាណត្តិ ចុះថ្ងៃទី ខែ ឆ្នាំ របស់មេធាវី អត្តលេខ ជាមេធាវីនៃ ក្រុមមេធាវី ស្តីពីការធ្វើជាមេធាវីតំណាងដោយអាណត្តិឱ្យអ្នកដាក់ពាក្យសុំឈ្មោះ ។
- សូមអញ្ជើញលោកមេធាវី អត្តលេខ មានការិយាល័យនៅផ្ទះលេខ ផ្លូវ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។
- <u>ចូលខ្លួនមកកាន់សាលាដំបូងរាជធានីភ្នំពេញ នៃអគារសាលាយុត្តិធម៌ បន្ទប់ ជាន់ទី នៅថ្ងៃទី ខែ ឆ្នាំ វេលាម៉ោង និង នាទីព្រឹក</u>។
- ដើម្បី៖ <u>ចូលរួមនីតិវិធីសាកសួរជាមួយកូនក្តី</u>។
- ពីដំណើររឿង៖ <u>កូនក្តីរបស់មេធាវីសុំលែងលះតាមការព្រមព្រៀង</u>។
- សូមមេធាវីអញ្ជើញចូលរួមឱ្យបានទាន់ពេលវេលា និងយកលិខិតផ្សេងៗដែលទាក់ទងនឹងរឿងខាងលើនេះមកជាមួយផង ប្រសិនបើមាន។

ថ្ងៃ ខែ ព.ស.

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ

**ចៅក្រម**

**ឌីង គឹមពិសាល**

---

អាសយដ្ឋាន អគារសាលាយុត្តិធម៌ ស្ថិតនៅដីឡូតិ៍លេខ B តំបន់អភិវឌ្ឍន៍ OCIC ផ្លូវលោកតាក្របាមក ភូមិព្រែកលៀប សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

សំណុំរឿងរដ្ឋប្បវេណីមិនមែនបណ្តឹងលេខ
ចុះថ្ងៃទី ខែ ឆ្នាំ

## ដីកាកោះ

យើង **ទីវ គឹមពិសាល** ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

- កោះហៅឈ្មោះ ភេទ កើតថ្ងៃទី ខែ ឆ្នាំ ជាអ្នកដាក់ពាក្យសុំ។
- មានទីលំនៅសព្វថ្ងៃ ភូមិ សង្កាត់ ក្រុង ខេត្ត ។
- ឱ្យចូលខ្លួនមកកាន់សាលាដំបូងរាជធានីភ្នំពេញ នៃអគារសាលាយុត្តិធម៌ បន្ទប់ ជាន់ទី នៅថ្ងៃទី ខែ ឆ្នាំ វេលាម៉ោង និង នាទីព្រឹក។
- ដើម្បី៖ សាកសួរ។
- ពីដំណើររឿង៖ សុំលែងលះតាមការព្រមព្រៀង។
- សាមីខ្លួន ត្រូវអញ្ជើញតាមដីកាកោះនេះឱ្យបានទាន់ពេលវេលា និងយកលិខិតផ្សេងៗដែលទាក់ទងនឹងរឿងខាងលើនេះមកជាមួយផង ប្រសិនបើមាន។

ថ្ងៃ ខែ ឆ្នាំ ព.ស.

រាជធានីភ្នំពេញ,ថ្ងៃទី ខែ ឆ្នាំ

**ចៅក្រម**

**ទីវ គឹមពិសាល**

អាសយដ្ឋាន អគារសាលាយុត្តិធម៌ ស្ថិតនៅដីឡូតិ៍លេខ B តំបន់អភិវឌ្ឍន៍ OCIC ផ្លូវលោកតាក្របាមក ភូមិព្រែកលៀប សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

-សំណុំរឿងរដ្ឋប្បវេណីមិនមែនជា
បណ្តឹងលេខ
ចុះថ្ងៃទី ខែ ឆ្នាំ
ដីកាសម្រេច
លេខ.
ចុះថ្ងៃទី ខែ ឆ្នាំ

# ដីកាសម្រេច
# រឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

យើង **តាំង ស៊ុនឡាយ** ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ មាត្រា៣ និងមាត្រាពាក់ព័ន្ធនិងច្បាប់ស្តីពីនីតិវិធី នៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១០/០១៣ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០។

-បានឃើញ មាត្រា ៩៧៩ និងមាត្រាពាក់ព័ន្ធ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

-បានឃើញ សំណុំរឿងរដ្ឋប្បវេណីមិនមែនជាបណ្តឹងលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមាន៖

-ភាគីអ្នកដាក់ពាក្យសុំ ឈ្មោះ ភេទ កើតថ្ងៃទី ខែ ឆ្នាំ កាន់ ចុះថ្ងៃទី ខែ ឆ្នាំ អាសយដ្ឋានស្ថិតនៅផ្ទះលេខ ផ្លូវលំ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

អ្នកតំណាងដោយអាណត្តិ លោក អត្តលេខ ជាមេធាវី មានការិយាល័យ ផ្ទះលេខ ផ្លូវលេខ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

-ភាគីម្ខាងទៀត ឈ្មោះ ភេទ កើតថ្ងៃទី ខែ ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លេខ អាសយដ្ឋានស្ថិតនៅផ្ទះលេខ ផ្លូវលំ ភូមិ សង្កាត់ រាជធានីភ្នំពេញ។

## អង្គហេតុ និងចំណុចវិវាទ

**១-ខ្លឹមសារនៃដីកាសម្រេចដែលភាគីអ្នកដាក់ពាក្យសុំទាមទារឱ្យតុលាការចេញ៖**

១.១.ឱ្យភាគីអ្នកដាក់ពាក្យសុំឈ្មោះ ភេទ កើតថ្ងៃទី ខែ ឆ្នាំ និង ភាគីម្ខាងទៀតឈ្មោះ ភេទ កើតថ្ងៃទី ខែ ឆ្នាំ លែងលះតាមការព្រមព្រៀង។

១.២.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីអ្នកដាក់ពាក្យសុំ។

**២-ដំណើររឿងក្តី**

កាលពីអំឡុងឆ្នាំ ភាគីអ្នកដាក់ពាក្យសុំឈ្មោះ បានរៀបអាពាហ៍ពិពាហ៍ជាមួយ ភាគីម្ខាងទៀតឈ្មោះ ដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ ចុះថ្ងៃទី ខែ ឆ្នាំ

នៅមន្ត្រីអត្រានុកូលដ្ឋានសង្កាត់ ។ នៅក្នុងចំណងអាពាហ៍ពិពាហ៍ភាគីទាំងពីរពុំមានកូន ទ្រព្យសម្បត្តិរួម និងបំណុលឡើយ។ ដោយការរស់នៅជាមួយគ្នាកន្លងមកមិនចុះសម្រុងនឹងគ្នា រហូតដល់គូភាគីអស់មនោសញ្ចេតនាជាប្តីប្រពន្ធតទៅទៀត ទើបភាគីទាំងពីរដាក់ពាក្យសុំលែងលះតាមការព្រមព្រៀងមកតុលាការ។

**៣-អង្គហេតុដែលអះអាងដោយភាគីអ្នកដាក់ពាក្យសុំ**

ភាគីអ្នកដាក់ពាក្យសុំឈ្មោះ បានអះអាងថា ខ្លួនស្នើរសុំឱ្យតុលាការចេញដីកាសម្រេច៖

-លែងលះតាមការព្រមព្រៀងរវាងអ្នកដាក់ពាក្យសុំឈ្មោះ និងភាគីម្ខាងទៀតឈ្មោះ ។

-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីអ្នកដាក់ពាក្យសុំ។

ចំពោះអង្គហេតុគឺ ខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ កាលពីឆ្នាំ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ ចុះថ្ងៃទី ខែ ឆ្នាំ ត្រឹមត្រូវតាមច្បាប់។ ក្នុងចំណងអាពាហ៍ពិពាហ៍រហូតមកដល់សព្វថ្ងៃពុំមានកូន ទ្រព្យសម្បត្តិរួម និងបំណុលរួមនោះទេ។ មូលហេតុនៃការលែងលះ គឺដោយហេតុថាខ្លួន និងភាគីម្ខាងទៀតរស់នៅមិនចុះសម្រុងនឹងគ្នា រហូតដល់បណ្តាលឱ្យអស់មនោសញ្ចេតនាជាប្តីប្រពន្ធតទៅទៀត ដែលធ្វើឱ្យទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់មិនអាចធ្វើបដិទានវិញបាន។ ចំពោះកិច្ចព្រមព្រៀងលែងលះចុះថ្ងៃទី ខែ ឆ្នាំ គឺកើតចេញពីឆន្ទៈពិតប្រាកដរបស់ខ្លួន មិនមានការបង្ខិតបង្ខំឡើយ ហើយស្នាមម្រាមដៃលើកិច្ចព្រមព្រៀងគឺពិតជាស្នាមម្រាមដៃរបស់ខ្លួនប្រាកដមែន ដូច្នេះខ្លួនសុំឱ្យតុលាការសម្រេចតាមពាក្យសុំរបស់ខ្លួន។

**៤-អង្គហេតុដែលអះអាងដោយភាគីម្ខាងទៀត**

ភាគីម្ខាងទៀតឈ្មោះ បានអះអាងថាខ្លួនឯកភាពលែងលះជាមួយភាគីអ្នកដាក់ពាក្យសុំឈ្មោះ ។ ចំពោះអង្គហេតុ និងមូលហេតុ ដែលភាគីអ្នកដាក់ពាក្យសុំបានលើកឡើងគឺពិតជាត្រឹមត្រូវខ្លួនមិនមានការជំទាស់ឡើយ ចំណែកកិច្ចព្រមព្រៀងលែងលះ ចុះថ្ងៃទី ខែ ឆ្នាំ គឺកើតចេញពីឆន្ទៈពិតប្រាកដរបស់ខ្លួនមិនមានការបង្ខិតបង្ខំឡើយ ហើយស្នាមម្រាមដៃលើកិច្ចព្រមព្រៀងគឺ ពិតជាស្នាមម្រាមដៃរបស់ខ្លួនប្រាកដមែន ដូច្នេះខ្លួនសុំឱ្យតុលាការសម្រេចតាមច្បាប់។

## ការពិនិត្យភស្តុតាង

**១-ភស្តុតាងជាឯកសាររបស់ភាគីអ្នកដាក់ពាក្យសុំ**

-កិច្ចព្រមព្រៀងលែងលះ ចុះថ្ងៃទី ខែ ឆ្នាំ រវាងឈ្មោះ និងឈ្មោះ ។

-សំបុត្រអាពាហ៍ពិពាហ៍លេខ ចុះថ្ងៃទី ខែ ឆ្នាំ ក្នុងសៀវភៅអាពាហ៍ពិពាហ៍ លេខ ចេញដោយមន្ត្រីអត្រានុកូលដ្ឋាន សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

- លេខ របស់ឈ្មោះ ។

**២-ភស្តុតាងជាឯកសាររបស់ភាគីម្ខាងទៀត**

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ចុះថ្ងៃទី របស់ឈ្មោះ ។

## សំអាងហេតុ

១-តាមសេចក្តីថ្លែងការណ៍របស់ភាគីអ្នកដាក់ពាក្យសុំឈ្មោះ និងភាគីម្ខាងទៀតឈ្មោះ នាពេលសាកសួរ ព្រមទាំងសំបុត្រអាពាហ៍ពិពាហ៍ លេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់មន្ត្រី

អគ្រានុកូលដ្ឋាន សង្កាត់ ក្នុងខណ្ឌ រាជធានីភ្នំពេញ បានបង្ហាញឱ្យឃើញថា រវាងភាគីអ្នកដាក់ពាក្យសុំឈ្មោះ និងភាគីម្ខាងទៀតឈ្មោះ ពិតជាប្តីប្រពន្ធស្របច្បាប់ដែលបានរៀបអាពាហ៍ពិពាហ៍ ទទួលស្គាល់ដោយមន្ត្រីអគ្រានុកូលដ្ឋានសង្កាត់ ប្រាកដមែន។

២-តាមការអះអាងរបស់ភាគីអ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀត នៅក្នុងកំណត់ហេតុសាកសួរ ដែលភាគីទាំងពីរបានបញ្ជាក់មូលហេតុដែលឈានដល់ការលែងលះតាមការព្រមព្រៀង តុលាការយល់ឃើញថាអាពាហ៍ពិពាហ៍រវាងឈ្មោះ និងឈ្មោះ ពិតជាបានបាក់បែកមិនអាចធ្វើបដិទានវិញបាន ហើយភាគីទាំងពីរពិតជាមានឆន្ទៈពិតប្រាកដក្នុងការលែងលះ ទោះបីជាតុលាការបានខិតខំផ្សះផ្សាយ៉ាងណាក៏ដោយ ភាគីនៅតែទាមទារតុលាការឱ្យសម្រេចអំពីការលែងលះ គប្បីតុលាការពិនិត្យ និងសម្រេចអំពីការលែងលះនេះតាមបញ្ញត្តិមាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី។

៣-នាពេលសាកសួរភាគីទាំងពីរបានអះអាងថា ក្នុងចំណងអាពាហ៍ពិពាហ៍គូភាគីពុំមានកូន ទ្រព្យសម្បត្តិរួម និងបំណុលរួម ដែលត្រូវធ្វើការបែងចែកឡើយ **ដូចនេះ តុលាការមិនលើកយកចំនុចទាំងនេះមកពិចារណា និងសម្រេចឡើយ។**

៤-ភាគីអ្នកដាក់ពាក្យសុំបានស្នើសុំទទួលបន្ទុកប្រាក់ប្រដាប់ក្តី ដូចនេះគប្បីតុលាការពិចារណា និងសម្រេចអំពីបន្ទុកនៃប្រាក់ប្រដាប់ក្តីទៅតាមបញ្ញត្តិមាត្រា២២ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។

**សេចក្តីសម្រេចបញ្ចប់**

១-ឱ្យភាគីអ្នកដាក់ពាក្យសុំឈ្មោះ ភេទ កើតថ្ងៃទី ខែ ឆ្នាំ និងភាគីម្ខាងទៀតឈ្មោះ ភេទ កើតថ្ងៃទី ខែ ឆ្នាំ លែងលះតាមការព្រមព្រៀង។

២-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីអ្នកដាក់ពាក្យសុំ។

**ចៅក្រម**

**ហត្ថលេខា និងត្រា: តាំង ស៊ុនឡាយ**

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ ខែ ឆ្នាំ ព.ស.

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ

**ក្រឡាបញ្ជី**

**មិន វិឆ្ន**

**បានឃើញ**

**ចៅក្រម**

តាំង_ស៊ុនឡាយ

គំរូលេខ 09 សហវ/ចមព

260-1- 00203712

MEF20882604121

ក្រសួងយុត្តិធម៌

អង្គភាព [illegible]

# បង្កាន់ដៃបង់ប្រាក់

(ប្រគល់ជូនអ្នកបង់ប្រាក់)

ទទួលពី [illegible] អង្គភាព [illegible]

ចំនួនទឹកប្រាក់ជាលេខ [illegible]

ជាអក្សរ [illegible]

អត្ថន័យចំណូល [illegible] មាតិកាថវិកា

ថ្ងៃទី. ខែ. ឆ្នាំ.

អ្នកប្រមូលចំណូល

[illegible]

បង្កាន់ដៃនេះត្រូវបានបោះពុម្ព និងគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្របតាមអនុក្រឹត្យលេខ ៨២អនក្រ. ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥

# ឧបសម្ព័ន្ធទី២

# ការលែងលះដោយគ្មានការព្រមព្រៀង

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ
ចូល ថ្ងៃទី ខែ ឆ្នាំ

## ពាក្យបណ្តឹងលែងលះ

**ដើមចោទ៖** ឈ្មោះ ភេទ ជនជាតិខ្មែរ កើតថ្ងៃទី ខែ ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ចុះថ្ងៃទី ខែ ឆ្នាំ មានអាសយដ្ឋានបច្ចុប្បន្នស្ថិតនៅផ្ទះលេខ ផ្លូវលេខ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ទូរស័ព្ទលេខ៖ ។

**ចុងចម្លើយ៖** ឈ្មោះ ភេទ កើតថ្ងៃទី ខែ ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ចុះថ្ងៃទី ខែ ឆ្នាំ មានអាសយដ្ឋានស្ថិតនៅ ភូមិ ឃុំ ស្រុក ខេត្ត ទូរស័ព្ទលេខ ។

**សូមគោរពជូន**
**ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ**

### ១. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ៖

១. ដើមចោទឈ្មោះ លែងលះពីចុងចម្លើយឈ្មោះ ។

២. កំណត់យកដើមចោទឈ្មោះ ដែលជាឪពុក ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ ភេទ អាយុ ឆ្នាំ កើតថ្ងៃទី ខែ ឆ្នាំ មានសំបុត្របញ្ជាក់កំណើតលេខ ចុះថ្ងៃទី ខែ ឆ្នាំ ។

៣. បែងចែកទ្រព្យសម្បត្តិរួម ដូចមានរៀបរាប់ខាងក្រោមជា ០២ (ពីរ) ចំណែកស្មើៗគ្នា រវាងភាគីដើមចោទ និងភាគីចុងចម្លើយ៖

- រថយន្តម៉ាក TOYOTA HILUX ពណ៌ស ផលិតឆ្នាំ សម្គាល់ដោយផ្លាកលេខ ភ្នំពេញ ចុះថ្ងៃទី ខែ ឆ្នាំ ដែលមានឈ្មោះ ជាកម្មករលើប័ណ្ណសម្គាល់រថយន្ត។
- អចលនទ្រព្យ៖ ផ្ទះ និង ដី ទំហំ x ម២ ( គុណនឹង ) ម៉ែត្រការ៉េ, លេខក្បាលដីសម្គាល់ដោយគំនូសបង្ហាញទីតាំងដីសាងសង់លំនៅឋាន ចុះថ្ងៃទី ខែ ឆ្នាំ មានទីតាំងស្ថិតនៅផ្លូវជាតិលេខ ភូមិ ឃុំ ស្រុក ខេត្ត ។

៤. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

### ២. អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ និង អង្គហេតុដែលជាមូលហេតុនៃការទាមទារ

កាលពីថ្ងៃទី ខែ ឆ្នាំ ខ្ញុំបាទបានរៀបអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយឈ្មោះ និង បានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមផ្លូវច្បាប់។ នៅក្នុងចំណងអាពាហ៍ពិពាហ៍ ខ្ញុំបាទ និង ចុងចម្លើយមានកូនមួយនាក់ឈ្មោះ

ភេទ    អាយុ    ឆ្នាំ កើតថ្ងៃទី    ខែ    ឆ្នាំ    មានសំបុត្របញ្ជាក់កំណើតលេខ    ចុះថ្ងៃទី    ខែ    ឆ្នាំ    និង មានទ្រព្យសម្បត្តិរួមដូចខាងក្រោម៖

- រថយន្តម៉ាក TOYOTA HILUX ពណ៌ស ផលិតឆ្នាំ    សម្គាល់ដោយផ្លាកលេខ ភ្នំពេញ    ចុះថ្ងៃទី    ខែ    ឆ្នាំ    ដែលមានឈ្មោះខ្ញុំបាទ    ជាកម្មករលើប័ណ្ណសម្គាល់រថយន្ត។
- អចលនទ្រព្យ៖ ផ្ទះ និង ដី ទំហំ    x    ម២ (    គុណនឹង    ) ម៉ែត្រការ៉េ, លេខក្បាលដី    សម្គាល់ដោយគំនូសបង្ហាញទីតាំងដីសាងសង់លំនៅឋាន ចុះថ្ងៃទី    ខែ    ឆ្នាំ    មានទីតាំងស្ថិតនៅផ្លូវជាតិលេខ    ភូមិ    ឃុំ    ស្រុក    ខេត្ត    (អចលនទ្រព្យនេះកំពុងដំណើរការនីតិវិធីចុះបញ្ជីដីធ្លី ដែលអាជ្ញាធរបានចុះទៅវាស់វែង កំណត់ព្រំរួចរាល់ហើយ និងពុំមានជម្លោះជាមួយបុគ្គលណាម្នាក់ឡើយ)។

ក្រោយពេលរៀបអាពាហ៍ពិពាហ៍ មួយរយៈពេលចុងក្រោយនេះ យើងខ្ញុំទាំងពីរនាក់រស់នៅពុំចុះសំរុងនឹងគ្នា និង មិនអាចបន្តរស់នៅជាមួយគ្នាបាន រហូតឈានដល់ការបែកលំនៅឋានពីគ្នាតាំងពីថ្ងៃទី    ខែ    ឆ្នាំ    មកម្ល៉េះ ដែលបច្ចុប្បន្ននេះ ខ្ញុំបាទបានមករស់នៅផ្ទះលេខ    ផ្លូវលេខ    ភូមិ    សង្កាត់    ខណ្ឌ    រាជធានីភ្នំពេញ។ យើងខ្ញុំទាំងពីរនាក់អស់មនោសញ្ចេតនាជាប្តីប្រពន្ធនឹងគ្នា តទៅទៀតហើយ ដែលធ្វើឱ្យចំនាក់ចំនងអាពាហ៍ពិពាហ៍នេះត្រូវបែកបាក់ទាំងស្រុង ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបានឡើយ។ បន្ថែមពីនេះ ខ្ញុំបាទសុំសិទ្ធិធ្វើជាអ្នកមានអំណាចមេបាលើកូនប្រុសឈ្មោះ    ខាងលើ ដោយសារតែខ្ញុំបាទមានប្រាក់ចំណូលជាក់លាក់គ្រាប់គ្រាន់ក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូន និង អាចឱ្យកូនចូលរៀននៅសាលាល្អបាន។ ជាពិសេស ខ្ញុំបាទមានពេលវេលាគ្រប់គ្រាន់ក្នុងការមើលថែរក្សាកូនឱ្យបានជិតដល់ ដើម្បីឱ្យកូនរស់នៅប្រកបដោយភាពកក់ក្តៅ និង មានអនាគតល្អ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាចេញសាលក្រមលែងលះតាមការទាមទារខាងលើដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ៕

រាជធានីភ្នំពេញ, ថ្ងៃទី    ខែ    ឆ្នាំ

**ស្នាមមេដៃស្តាំ**

**បានឃើញ**

រាជធានីភ្នំពេញ, ថ្ងៃទី    ខែ    ឆ្នាំ

**មេធាវី**

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

មេធាវី

ជូនភ្ជាប់មកជាមួយនូវ៖

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ

ខ្ញុំបាទឈ្មោះ ជនជាតិខ្មែរ កើតថ្ងៃទី ខែ ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ចុះថ្ងៃទី ខែ ឆ្នាំ មានអាសយដ្ឋានបច្ចុប្បន្នស្ថិតនៅផ្ទះលេខ ផ្លូវលេខ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ទូរស័ព្ទលេខ៖ (**អាណត្តិទាយក**)។

## សូមប្រគល់សិទ្ធិជូន

លោកមេធាវី អត្តលេខ ជាមេធាវី នៃក្រុមមេធាវី ដែលមានការិយាល័យនៅផ្ទះលេខ ផ្លូវលេខ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ដើម្បីធ្វើជាអ្នកតំណាងដោយអាណត្តិរបស់ខ្ញុំបាទ នៅក្នុងរឿងក្តីលែងលះ។ តាមរយៈលិខិតប្រគល់សិទ្ធិនេះ លោកមេធាវី មានសិទ្ធិបំពេញរាល់កិច្ចការដូចខាងក្រោម៖

- មានសិទ្ធិអំណាចពេញលេញនៅក្នុងការធ្វើសកម្មភាពតំណាងឱ្យខ្ញុំបាទ។
- ដាក់ពាក្យបណ្តឹង ដាក់ពាក្យសុំ ដកពាក្យបណ្តឹង ដកពាក្យសុំ ផ្សះផ្សា សម្រុះសម្រួល បោះបង់ ឬ ទទួលស្គាល់ការទាមទារ ឬ ដកខ្លួនចេញពីបណ្តឹងដែលខ្លួនចូលរួមអន្តរាគមន៍ ឬ ទទួលបណ្តឹងដើម្បីផលប្រយោជន៍ស្របច្បាប់របស់ខ្ញុំបាទ។
- ការតែងតាំងអនុតំណាង។
- ការប្តឹងតវ៉ា/ការប្តឹងទាស់/ការប្តឹងជំទាស់/ការប្តឹងឧទ្ធរណ៍/ការប្តឹងសាទុក្ខ។

**បញ្ជាក់៖** រាល់សោហ៊ុយចំណាយលើការអនុវត្តភារកិច្ចនេះ និង បង់ពន្ធផ្សេងៗនៅក្នុងបណ្តឹង ឬ ពាក្យសុំនេះ ជាបន្ទុករបស់ខ្ញុំបាទ។ ក្នុងករណីមិនបានគោរពតាមកាតព្វកិច្ចនេះ ខ្ញុំបាទសុខចិត្តទទួលខុសត្រូវនូវរាល់ការបាត់បង់ផលប្រយោជន៍នានាដោយខ្លួនឯងផ្ទាល់។

លិខិតប្រគល់សិទ្ធិនេះ មានអានុភាពចាប់ពីថ្ងៃផ្តិតស្នាមមេដៃនេះតទៅ៕

ថ្ងៃទី ខែ ឆ្នាំ

**ស្នាមមេដៃស្តាំ**

បានឃើញ និងយល់ព្រម

ធ្វើជាមេធាវីតំណាងដោយអាណត្តិឱ្យ

លោក ណុប ណូរ៉ា តាមនីតិវិធីច្បាប់។

ថ្ងៃទី ខែ ឆ្នាំ

**មេធាវី**

មេធាវី

ATTORNEY AT LAW

KINGDOM OF CAMBO

មេធាវី

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

INTERNATIONAL
ក្រុមហ៊ុនមេធាវី ជីជី អន្តរជាតិ
GG International Law Firm

លេខ: . ជ.ជ.អ

សាលាដំបូងរាជធានីភ្នំពេញ
ទទួល
លេខ...
ថ្ងៃទី... ខែ... ឆ្នាំ...
ម៉ោង... និង... នាទី

ថ្ងៃអង្គារ ៥ រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៣

## ពាក្យសុំតំណាងដោយអាណត្តិ

យើងខ្ញុំមេធាវី , អត្តលេខ: និងលោកមេធាវី អត្តលេខ: ជាសមាជិកនៃ **ក្រុមហ៊ុនមេធាវី ជីជី អន្តរជាតិ** ដែលមានអាសយដ្ឋានស្ថិតនៅអាគារលេខ: ផ្លូវលេខ ភូមិ សង្កាត់ ខណ្ឌមានជ័យ រាជធានីភ្នំពេញ និងជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងជាមេធាវីតំណាងដោយអាណត្តិឲ្យឈ្មោះ ក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ខែ ឆ្នាំ២០២៣ របស់សាលាដំបូងរាជធានីភ្នំពេញ។

ទូរស័ព្ទទំនាក់ទំនងលេខ៖ /

ជូនទៅក្រុមបន្ទប់
និងចាត់ការ

**សូមគោរពចូលមក**
**ឯកឧត្តមប្រធាន សាលាដំបូងរាជធានីភ្នំពេញ**

**កម្មវត្ថុ** ៖ ស្តីពីការសុំតំណាងដោយអាណត្តិក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

**យោង** ៖ -ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី
-ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា
-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិរបស់ឈ្មោះ
ចុះថ្ងៃទី ខែ ឆ្នាំ ។

តបតាមកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា៖ ឈ្មោះ បានប្រគល់សិទ្ធិឲ្យយើងខ្ញុំធ្វើជាមេធាវីតំណាងដោយអាណត្តិឲ្យរូបគាត់ នៅក្នុងសំណុំរឿងរដ្ឋប្បវេណីដូចដែលមានចែងក្នុងកម្មវត្ថុខាងលើ។

អាស្រ័យហេតុនេះ: សូម **ឯកឧត្តមប្រធាន** មេត្តាទទួលស្គាល់យើងខ្ញុំ ជាមេធាវីតំណាងដោយអាណត្តិនៅក្នុងសំណុំរឿងរដ្ឋប្បវេណីខាងលើទៅតាមនីតិវិធីច្បាប់ដោយក្តីអនុគ្រោះ ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

មេធាវី
ATTORNEY AT LAW
KINGDOM OF CAMBODIA

មេធាវី                                        មេធាវី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

GG INTERNATIONAL

ក្រុមហ៊ុនមេធាវី ជីជី អន្តរជាតិ

GC International Law Firm

លេខ: ១៨៣៥/២៣ ជ.ជ.អ

សាលាដំបូងរាជធានីភ្នំពេញ ចូល លេខ..... ថ្ងៃ..... ខែ..... ឆ្នាំ..... ម៉ោង..... នាទី.....

ថ្ងៃ ខែ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២៣

## ពាក្យសុំពិនិត្យ និងថតចម្លងសំណុំរឿង

យើងខ្ញុំមេធាវី អត្តលេខ: និងលោកមេធាវី អត្តលេខ:

ជាសមាជិកនៃ **ក្រុមហ៊ុនមេធាវី ជីជី អន្តរជាតិ** ដែលមានអាសយដ្ឋានស្ថិតនៅអាគារលេខ: ផ្លូវលេខ ភូមិ សង្កាត់ ខណ្ឌមានជ័យ រាជធានីភ្នំពេញ និងជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងជាមេធាវីតំណាងដោយអាណត្តិឲ្យឈ្មោះ ក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ខែ ឆ្នាំ២០២៣ របស់សាលាដំបូងរាជធានីភ្នំពេញ។

ទូរស័ព្ទទំនាក់ទំនងលេខ:

ជូនទៅក្រុមបន្ទប់ ... ពិនិត្យ និងចាត់ការ

**សូមគោរពចូលមក**

**ឯកឧត្តមប្រធាន សាលាដំបូងរាជធានីភ្នំពេញ**

**កម្មវត្ថុ៖** ស្តីពីការសុំតំណាងដោយអាណត្តិក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ខែ ឆ្នាំ២០២៣ របស់សាលាដំបូងរាជធានីភ្នំពេញ។

**យោង ៖** -មាត្រា២៥៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិរបស់ឈ្មោះ ចុះថ្ងៃទី ខែ ឆ្នាំ២០២៣។

តបតាមកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា៖ ឈ្មោះ បានប្រគល់សិទ្ធិឲ្យយើងខ្ញុំធ្វើជាមេធាវីតំណាងដោយអាណត្តិឲ្យរូបគាត់ នៅក្នុងសំណុំរឿងរដ្ឋប្បវេណីដូចដែលមានចែងក្នុងកម្មវត្ថុខាងលើ។

អាស្រ័យហេតុនេះ: សូម **ឯកឧត្តមប្រធាន** មេត្តាអនុញ្ញាឲ្យយើងខ្ញុំបានពិនិត្យ និងថតចម្លងសំណុំរឿង រដ្ឋប្បវេណីខាងលើទៅតាមនីតិវិធីច្បាប់ដោយក្តីអនុគ្រោះ ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

ហត្ថលេខា និងត្រា

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

មេធាវី មេធាវី

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

លេខ:

## ដីកាសម្រេចបង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្ដី
## គុណការក្រៅពីពន្ធ

យើង **ឃិច ឈាណាទី** ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ។

**-បានឃើញ មាត្រា ៦២** និង**មាត្រា ៨២** នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

**-បានឃើញ** សំណុំរឿងរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

**<u>ដើមចោទ</u>**៖ ឈ្មោះ ភេទ កើតឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្នផ្ទះលេខ ផ្លូវលេខ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

**<u>អ្នកតំណាងដោយអាណត្តិ</u>**៖ លោកមេធាវី អត្តលេខ មានការិយាល័យនៅផ្ទះលេខ ផ្លូវ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

**<u>ចុងចោទ</u>**៖ ឈ្មោះ ភេទ កើតឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិ ឃុំ ស្រុក ខេត្ត ។

**<u>ខ្លឹមសារនៃការទាមទាររបស់ដើមចោទ</u>**៖ សុំលែងលះ។

### <u>សំអាងហេតុ</u>

ដើមចោទឈ្មោះ មិនទាន់បានបង់ប្រាក់ប្រដាប់ក្ដីគុណការក្រៅពីពន្ធសម្រាប់បញ្ជូនឯកសារនៅឡើយ ដែលជាហេតុធ្វើឱ្យតុលាការមិនអាចចាត់ការសំណុំរឿងនេះតាមនីតិវិធីបាន។

### <u>ហេតុដូច្នេះសម្រេច</u>

១-បង្គាប់ឱ្យឈ្មោះ ភេទ ជនជាតិខ្មែរ បង់ប្រាក់សម្រាប់បញ្ជូនឯកសារ និងដីកាផ្សេងៗ ចំនួន **១០០.០០០** (ដប់ម៉ឺន) រៀល នៅសាលាដំបូងរាជធានីភ្នំពេញ (**ជាន់ទី បន្ទប់** " ") ក្នុង**អំឡុងពេល ១៥ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានដីកាសម្រេចនេះ**។

**២**-ក្នុងករណីដើមចោទមិនបង់ប្រាក់ប្រដាប់ក្ដីទៅតាមការកំណត់នៅក្នុងដីកាសម្រេចនេះទេ តុលាការនឹងលើកចោលពាក្យបណ្ដឹងនេះដោយដីកាសម្រេច។

ថ្ងៃ ខែ ឆ្នាំ ព.ស.

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ

បានទទួលថ្ងៃទី...............................

ស្នាមមេដៃស្ដាំ

**ចៅក្រម**

ឃិច ឈាណាទី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរដ្ឋប្បវេណីលេខ:

ចុះថ្ងៃទី ខែ ឆ្នាំ

## <u>លិខិតអញ្ជើញមេធាវី</u>

យើង **យិច ឈាណាទី** ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

**<u>អញ្ជើញ</u>៖** លោកមេធាវី អត្តលេខ **<u>ជាអ្នកតំណាងដោយអាណត្តិឱ្យដើមចោទ</u>**។

**<u>ការិយាល័យ</u>៖** ផ្ទះលេខ ផ្លូវលេខ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

**<u>លេខទូរស័ព្ទ</u>៖** ។

ឱ្យចូលមកកាន់សាលាដំបូងរាជធានីភ្នំពេញ នៅថ្ងៃទី ខែ ឆ្នាំ វេលាម៉ោង **និង នាទី** **(បន្ទប់ " " ជាន់ទី )**។

**<u>ដើម្បីចូលរួម</u>៖** នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។

**<u>ពីដំណើររឿង</u>៖** សុំសាលក្រមបែងចែក។

សាមីខ្លួនត្រូវអញ្ជើញតាមដីកាកោះនេះឱ្យបានទាន់ពេលវេលា និងយកលិខិតផ្សេងៗដែលទាក់ទងនឹងរឿងខាងលើមកជាមួយផងប្រសិនបើមាន ។

ថ្ងៃ ខែ ឆ្នាំ ព.ស.

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ

**ចៅក្រម**

យិច ឈាណាទី

---

ក្រឡាបញ្ជីទទួលបន្ទុកសំណុំរឿងលោក **ហ៊ិន សំភ្ជុដា**

ទូរស័ព្ទទំនាក់ទំនងលេខ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

សំណុំរឿងរដ្ឋប្បវេណីលេខ:

ចុះថ្ងៃទី ខែ ឆ្នាំ

# <u>ដីកាកោះ</u>

យើង **ឃិច ឈាណាទី** ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

**<u>អញ្ជើញ</u>៖** ឈ្មោះ ភេទ កើតឆ្នាំ សញ្ជាតិខ្មែរ **<u>ជាដើមចោទ</u>**។

**<u>ទីលំនៅបច្ចុប្បន្ន</u>៖** ផ្ទះលេខ ផ្លូវលេខ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

**<u>លេខទូរស័ព្ទ</u>៖** ។

ឱ្យចូលមកកាន់សាលាដំបូងរាជធានីភ្នំពេញ នៅថ្ងៃទី ខែ ឆ្នាំ វេលាម៉ោង **និង នាទី** **(បន្ទប់ " " ជាន់ទី )** ។

**<u>ដើម្បីចូលរួម</u>៖** នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។

**<u>ពីដំណើររឿង</u>៖** សុំសាលក្រមលែងលះ។

សាមីខ្លួនត្រូវអញ្ជើញតាមដីកាកោះនេះឱ្យបានទាន់ពេលវេលា និងយកលិខិតផ្សេងៗដែលទាក់ទងនឹងរឿងខាងលើមកជាមួយផងប្រសិនបើមាន។

ថ្ងៃ ខែ ឆ្នាំ ព.ស.

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ

**ចៅក្រម**

ឃិច~ឈាណាទី

ក្រឡាបញ្ជីទទួលបន្ទុកសំណុំរឿងលោក **ហ៊ីន ស័ក្កដា**

ទូរស័ព្ទទំនាក់ទំនងលេខ

សាលាដំបូងរាជធានីភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍អំពីការបញ្ជូន

ប្រអប់ខាងក្រោមបំពេញដោយក្រឡាបញ្ជី

កាលបរិច្ឆេទផ្ញើចេញ: ថ្ងៃទី................ ............ខែ......... .........................ឆ្នាំ.. ......................

លេខសំណុំរឿង : [illegible]

ឈ្មោះឯកសារដែលត្រូវបានបញ្ជូន : [illegible]

ឈ្មោះ និង អាសយដ្ឋានរបស់អ្នកទទួលបន្ទុកកិច្ចការបញ្ជូន: លោក ឌុត កុម្ភៈ មន្ត្រីបញ្ជូននៃសាលាដំបូងរាជធានីភ្នំពេញ

ឈ្មោះជនដែលត្រូវទទួលការបញ្ជូន:.. ..........................................................................................

ហត្ថលេខា ឬ ស្នាមមេដៃ របស់អ្នកទទួលឯកសារដាក់ស្តែង:

ប្រអប់ខាងក្រោមត្រូវបំពេញដោយអ្នកប្រតិបត្តិការបញ្ជូន

ទីកន្លែងដែលបានធ្វើការបញ្ជូន:.

កាលបរិច្ឆេទនៃការបញ្ជូន: ថ្ងៃទី. ....ខែ....... ....ឆ្នាំ. ...ម៉ោង......... ......ព្រឹក / រសៀល

| | |
|---|---|
| | វិធីដាក់ស្តែងក្នុងការបញ្ជូន |
| ☑ ១ | ខ្ញុំបានប្រគល់ឯកសារ ជូនដល់ជនដែលត្រូវទទួលការបញ្ជូនដោយដៃផ្ទាល់ |
| | ☐ ខ្ញុំបានពន្យល់ជូនជនដែលត្រូវទទួលការបញ្ជូននូវខ្លឹមសារសង្ខេបនៃឯកសារដែលបានបញ្ជូនពីព្រោះជននោះមិនចេះអក្សរ |
| ☐ ២ | បានប្រគល់ឯកសារ ទៅអ្នកដែលមានការយល់ដឹងសមរម្យចំពោះការទទួលឯកសារនេះ ពីព្រោះខ្ញុំមិនបានជួប អ្នកដែលត្រូវទទួលការបញ្ជូនដោយផ្ទាល់នៅទីកន្លែងដែលត្រូវបញ្ជូននោះទេ។ |
| | ☐ -អ្នកបំរើ ☐ -អ្នកនៅជាមួយ ☐ -អ្នកផ្សេងដែលធ្វើការនៅទីនោះ |
| | ឈ្មោះ...........................................ភេទ............អាយុ..............ឆ្នាំ ត្រូវជា.......................................... |
| ☐ ៣ | ឯកសារត្រូវបានទុកនៅឯទីកន្លែងដែលត្រូវធ្វើការបញ្ជូន ដោយហេតុថា បុគ្គលខាងក្រោមនេះមិនទទួលការបញ្ជូនដោយគ្មានហេតុផល។ |
| | ☐ -ជនដែលត្រូវទទួលការបញ្ជូន ☐ -អ្នកបំរើ ☐ -អ្នកនៅជាមួយ ☐ -អ្នកផ្សេងដែលធ្វើការនៅទីនោះ |
| | ឈ្មោះ...........................................ភេទ............អាយុ..............ឆ្នាំ ត្រូវជា.......................................... |

☑ ខ្ញុំបានបញ្ជូនឯកសារតាមនីតិវិធីខាងលើ។

☐ ខ្ញុំមិនអាចធ្វើការបញ្ជូនឯកសារខាងលើបានសម្រេចទេ ពីព្រោះនៅទីកន្លែងដែលត្រូវបញ្ជូន ខ្ញុំពុំបានជួបជនដែលត្រូវទទួលការបញ្ជូន ឬ ជនដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារ។

កាលបរិច្ឆេទធ្វើរបាយការណ៍ : ថ្ងៃទី.......... ..... ..ខែ.. ..... ..........ឆ្នាំ... .................................

ហត្ថលេខា ឬ ស្នាមមេដៃ របស់អ្នកធ្វើរបាយការណ៍:

១៥
២

សាលាដំបូងខេត្តកណ្ដាល
បាន
លេខ: 390
ថ្ងៃទី 27 ខែ 02 ឆ្នាំ
ម៉ោង 9 និង 50 នាទី

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# សេចក្តីថ្លែងការណ៍

ខ្ញុំបាទឈ្មោះ ភេទប្រុស អាយុ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំនៅ បច្ចុប្បន្ន ភូមិកជានុកូល សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង។

## សូមគោរពជូន

## លោក គីម វ៉ត្ថុណារិន ចៅក្រមសាលាដំបូងខេត្តកណ្ដាល

**កម្មវត្ថុ** ៖ សំណើសុំផ្លាស់ប្តូរសេចក្តីថ្លែងការណ៍ ក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ០៨ ខែវិច្ឆិកា ឆ្នាំ របស់សាលាដំបូងខេត្តកណ្ដាល។

**យោង** ៖ -ដីកាកោះ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកណ្ដាល។
-សេចក្តីថ្លែងការណ៍ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ ។
-ពាក្យបណ្ដឹង ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ ។
-សំណុំរឿងរដ្ឋប្បវេណីលេខ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ របស់សាលាដំបូងខេត្តកណ្ដាល។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូន **លោកចៅក្រម** មេត្តាជ្រាបថា៖ ខ្ញុំបាទឈ្មោះ និងឈ្មោះ បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាជាប្ដីប្រពន្ធតាំងពីឆ្នាំ ១៩៩៣។ បន្ទាប់ពីខ្ញុំបាទ និងប្រពន្ធឈ្មោះ ចាប់ដៃគ្នាជាប្ដីប្រពន្ធមកគឺពួកយើងខ្ញុំមានកូនប្រុសចំនួន ០២នាក់ គឺឈ្មោះ អាយុ ឆ្នាំ និងឈ្មោះ អាយុ ១២ឆ្នាំ និងមានទ្រព្យសម្បត្តិរួមមួយចំនួនទៀត។ <u>ប៉ុន្តែដោយហេតុថា</u> ការរួមរស់ជាមួយគ្នាមិនចុះសម្រុងគ្នា ណាមួយខ្ញុំបាទអស់មនោសញ្ចេតនាជាប្ដីប្រពន្ធតទៅទៀតហើយ ហេតុនេះខ្ញុំបាទឈ្មោះ សុខចិត្តដាក់ពាក្យបណ្ដឹងសុំលែងលះទៅសាលាដំបូងខេត្តកណ្ដាល។

តាមខ្លឹមសារនៃពាក្យបណ្ដឹង ទ្រព្យសម្បត្តិរួមទាំងអស់ដូចដែលបានរៀបរាប់បានប្រគល់ឱ្យម្ដាយ និងកូនពីរនាក់ តែតាមសេចក្តីថ្លែងការណ៍ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ ទ្រព្យរួមទាំងនោះខ្ញុំបានសម្រេចប្រគល់ឱ្យម្ដាយ និងកូនស្រីឈ្មោះ តែពីរនាក់ ម្ដាយនិងកូនតែប៉ុណ្ណោះ ចំណែកឯកូនឈ្មោះ ជាបន្ទុករបស់ខ្ញុំបាទ មិនឱ្យទាមទារទ្រព្យសម្បត្តិទាំងនោះទេ។ ក្រោយពីតុលាការខេត្តកណ្ដាលមានចំណាត់ការលើរឿងក្តីខ្ញុំបាទ និងក្រោយពីខ្ញុំបាទធ្វើសេចក្តីថ្លែងការណ៍ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៩ កន្លងមកឃើញថា ភាគីឈ្មោះ ចេះតែបង្កបញ្ហា ដែលធ្វើឱ្យរាំងស្ទះនីតិវិធីរបស់តុលាការ ផ្ទុយពីអ្វីដែលខ្ញុំបាទបានសន្យាខាងលើ ទើបខ្ញុំបាទសម្រេចចិត្តកែប្រែសេចក្តីថ្លែង

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងខេត្តកណ្ដាល
លេខ: 486
ថ្ងៃទី 14 ខែ 3 ឆ្នាំ
ម៉ោង 8 និង 10 នាទី

## ពាក្យសុំបញ្ចូលភស្តុតាង

នាងខ្ញុំឈ្មោះ ជាចុងចម្លើយនៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ: ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ របស់សាលាដំបូងខេត្តកណ្ដាល។

**សូមគោរពជូនចំពោះ**

**លោក គីម រ័ត្នណារិន អនុប្រធានសាលាដំបូងខេត្តកណ្ដាល**

*សូមទានជ្រាប។*

**<u>កម្មវត្ថុ៖</u>** ស្នើសុំបញ្ចូលភស្តុតាងក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ: ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ របស់សាលាខេត្តកណ្ដាល។

**<u>យោង៖</u>** សំណុំរឿងរដ្ឋប្បវេណីលេខ: ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ របស់សាលាខេត្តកណ្ដាល។

តបតាមកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំសូមជម្រាបជូន **លោកចៅក្រម** មេត្តាជ្រាបថា: កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ តុលាការបានបញ្ចប់នីតិវិធីត្រៀមទាញហេតុផលលើកទី២ ចំពោះសំណុំរឿងរដ្ឋប្បវេណីលេខ: ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់សាលាដំបូងខេត្តកណ្ដាល ហើយតុលាការបានទុកពេលវេលាឲ្យចំនួន ០២សប្ដាហ៍ ដើម្បីភាគីដាក់បញ្ចូលភស្តុតាង។ ដូចនេះ ដើម្បី **លោកចៅក្រម** មានមូលដ្ឋានកាន់តែរឹងមាំក្នុងការពិចារណា និងសម្រេចសេចក្ដីក្នុងសំណុំរឿងខាងលើ នាងខ្ញុំសូមអនុញ្ញាតដាក់បញ្ចូលភស្តុតាងដូចខាងក្រោម៖

១. សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ លេខ: ០៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៤ ចេញដោយមេឃុំរការកោង២។

២. សំបុត្របញ្ជាក់កំណើត លេខ: ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៩ របស់កូនប្រុសច្បងឈ្មោះ ចេញដោយមេឃុំរការកោង២។

៣. សំបុត្របញ្ជាក់កំណើត លេខ: ៧៧ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៩ របស់កូនស្រីឈ្មោះ ចេញដោយមេឃុំរការកោង២។

៤. សៀវភៅស្នាក់នៅ លេខ: ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១០។

៥. ដី មានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី លេខ: / រកII ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៨ បញ្ជាក់ដោយមេឃុំរការកោង២។

៦. ដី មានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី លេខ: / រកII ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៨ បញ្ជាក់ដោយមេឃុំរការកោង២។

៧. ដី មានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី លេខ: មព ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ បញ្ជាក់ដោយអភិបាលរងស្រុកមុខកំពូល។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងខេត្តបន្ទាយមានជ័យ
លេខ...
ថ្ងៃ... ខែ... ឆ្នាំ...
ម៉ោង...

**ពាក្យសុំឲ្យកោះហៅសាក្សី**

ខ្ញុំបាទឈ្មោះ អាយុ២៨ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិ២ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ជាចុងចំលើយ ( )

**សូមគោរពជូន**

**លោកប្រធានសាលាដំបូងខេត្តបន្ទាយមានជ័យ**

កម្មវត្ថុ សំណើសុំកោះហៅសាក្សីឲ្យចូលមកឆ្លើយបំភ្លឺក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នាថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨ ម៉ោង៨ព្រឹក។

យោង .សំណុំរឿងរដ្ឋប្បវេណីលេខ ចុះថ្ងៃទី០៦.១១.l របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។

តាមកម្មវត្ថុ និង យោងខាងលើនេះ ខ្ញុំបាទ សូមគោរពជំរាបជូន **លោកប្រធាន**មេត្តាជ្រាបថា ៖ ខ្ញុំបាទត្រូវបានប្រពន្ធឈ្មោះ ប្តឹងសុំលែងលះពីខ្ញុំបាទ។ ព័ន្ធរឿងក្តីនេះ មានការវិវាទក្នុងរឿងទ្រព្យសម្បត្តិ ខ្ញុំសូមបញ្ជាក់ថា ចំពោះទ្រព្យសម្បត្តិមានដី និងផ្ទះនៅលើដី និងម៉ូតូមួយគ្រឿងដែលប្រពន្ធទាមទារថាជាទ្រព្យរួមនោះ គឺមិនត្រឹមត្រូវទេ។ ដី និងផ្ទះនៅលើដី និងម៉ូតូមួយគ្រឿងជាទ្រព្យសម្បត្តិដោយឡែករបស់ខ្ញុំបាទ គឺ៖

១.ដី និងផ្ទះនៅលើដី ជារបស់ឪពុកម្តាយខ្ញុំបាទ ចែកឲ្យក្រោយពេលរៀបការ។

២.ម៉ូតូ១គ្រឿង គឺជាម៉ូតូដែលប្អូនខ្ញុំបាទឈ្មោះ ឲ្យខ្ញុំបាទខ្ចីជិះទៅធ្វើការ មានសាក្សីដឹងលឺ ៖

.ឈ្មោះ ភេទស្រី អាយុ ឆ្នាំ នៅភូមិ២ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ជាម្តាយខ្ញុំបាទ។

.ឈ្មោះ ភេទប្រុស អាយុ ឆ្នាំ នៅភូមិសូភី សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

ខ្ញុំបាទមានសំណូមពរ សុំឲ្យតុលាការកោះអញ្ជើញសាក្សី ដើម្បីបំភ្លឺការពិតជូនតុលាការពេលសវនាការ។

អាស្រ័យដូចបានគោរពជូនខាងលើនេះសូម **ប្រធាន** មេត្តាសំរេច តាមសំណូមពរ ខ្ញុំបាទ ដោយក្តីអនុគ្រោះ។

សូម **លោកប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

ធ្វើនៅថ្ងៃទី ១៥ ខែវិច្ឆកា ឆ្នាំ
ស្នាមមេដៃស្តាំ

បញ្ជូនទៅ...
ដើម្បីចាត់ការតាមនីតិវិធីច្បាប់។
បន្ទាយមានជ័យ, ថ្ងៃទី 15 ខែ 11 ឆ្នាំ
ប្រធានសាលាដំបូង

26/19

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

## លិខិតអញ្ជើញ

យើង គីម វត្ថុណារិន ចៅក្រមសាលាដំបូងខេត្តកណ្តាល

អញ្ជើញ ៖ មេធាវី អត្តលេខ នៃក្រុមមេធាវី មានអាសយដ្ឋាននៅ ផ្ទះលេខ ១០-B2 E₀E₁ ផ្លូវលេខ ២១១ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ជាមេធាវីតំណាងអាណត្តិឱ្យចុងចោទឈ្មោះ ។

| | |
|---|---|
| សញ្ញាណរឿងក្តី និង ភាគី | សំណុំរឿងរដ្ឋប្បវេណីលេខ ១០៧៧ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៦<br>ការទាមទាររបស់ដើមចោទ ៖ ប្តឹងសុំលែងលះប្រពន្ធ<br>+ ដើមចោទឈ្មោះ អាច ប្រុស<br>+ ចុងចម្លើយឈ្មោះ អេច ស្រី |
| កាលបរិច្ឆេទ និងទីកន្លែងដែលបង្ហាញខ្លួន | ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៩ វេលាម៉ោង ០៧ និង ០០ នាទីព្រឹក/រសៀល<br>☑សាលាដំបូងខេត្តកណ្តាល ☐បន្ទប់សវនាការទី....... ☑បន្ទប់ "ឆ" |
| ប្រភេទនៃកាលបរិច្ឆេទ (សំគាល់ដោយសញ្ញា ☑) | ☐នីតិវិធីត្រៀម ☑ទាញហេតុផលផ្ទាល់មាត់ ☐ ប្រកាសសាលក្រម<br>...................................................................................................... |
| ប្រភេទនៃឯកសារភ្ជាប់មកជាមួយ (សំគាល់ដោយសញ្ញា ☑) | ឯកសារស្តីពីចំណុចនៃការសាកសួរ<br>ឯកសារស្តីពីចំណុចនៃការធ្វើកោសល្យវិច្ច័យ |
| លទ្ធផលផ្លូវច្បាប់ក្នុងករណីដែលមិនបង្ហាញខ្លួនដោយគ្មានមូលហេតុត្រឹមត្រូវ | -បើដើមចោទមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទលើកទី១ នៃនីតិវិធីត្រៀមសំរាប់ ការទាញហេតុផលទេតុលាការត្រូវច្រានចោលការទាមទាររបស់ដើមចោទនោះ ដោយសាលក្រមកំបាំង មុខ តាមមាត្រា២០០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។<br>-បើចុងចំលើយមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទលើកទី១ នៃនីតិវិធីត្រៀម សំរាប់ការទាញហេតុផលទេ តុលាការត្រូវបញ្ចប់នីតិវិធីត្រៀមសំរាប់ការទាញ ហេតុផលដោយភ្លាមៗ ហើយកំណត់នូវកាលបរិច្ឆេទលើកទី១ នៃការទាញ ហេតុ ផលដោយផ្ទាល់មាត់ តាមមាត្រា ២០១ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ |

សូមបង្ហាញខ្លួនដូច ដែលបានចែងខាងលើនេះ ។

ថ្ងៃពុធ ១៤រោច ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

កណ្តាល, ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩

ចៅក្រម

គីម វត្ថុណារិន

យើង.......................................ជា.......................
បានប្រគល់ដីកាកោះនេះឱ្យឈ្មោះ....................................
មានទីលំនៅបច្ចុប្បន្ននៅភូមិ..........................ឃុំ...............
ស្រុក..........................ខេត្ត.........................នៅថ្ងៃទី
.................ខែ.................ឆ្នាំ..............ហើយយើងបាន
ប្រាប់ថាសាម៉ីខ្លួន ត្រូវប្រគល់ចុងដីកាកោះនេះ ដល់ក្រឡាបញ្ជី នៅពេលដែលខ្លួនចូលមកចំពោះមុខតុលាការខេត្តកណ្តាល។

អ្នកទទួល អ្នកប្រគល់

ក្រឡាបញ្ជី មកប្រគល់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

------ ------

[illegible]បូងខេត្តកណ្ដាល

## ដីកាកោះ

យើង គឹម រ័ត្នណារិន ចៅក្រមសាលាដំបូងខេត្តកណ្ដាល

អញ្ជើញ ៖ ឈ្មោះ ភេទ ស្រី អាយុ ឆ្នាំ សញ្ជាតិខ្មែរ មានអាសយដ្ឋានបច្ចុប្បន្ននៅ ភូមិរការកោង ឃុំរការកោង១ ស្រុកមុខកំពូល ខេត្តកណ្ដាល ជាចុងចម្លើយ។

| | |
|---|---|
| សញ្ញាណរឿងក្ដី និង ភាគី | សំណុំរឿងរដ្ឋប្បវេណីលេខ ១០៧៧ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៦<br>ការទាមទារដោយដើមចោទ ៖ ប្ដឹងសុំលែងលះប្រពន្ធ<br>+ ដើមចោទឈ្មោះ . ភេទ ប្រុស<br>+ ចុងចម្លើយឈ្មោះ ភេទ ស្រី |
| កាលបរិច្ឆេទ និងទីកន្លែងដែលបង្ហាញខ្លួន | ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១៩ វេលាម៉ោង [illegible] និង ០០.... នាទីព្រឹក/រសៀល<br>☑ សាលាដំបូងខេត្តកណ្ដាល ☐ បន្ទប់សវនាការទី...... ☑ បន្ទប់ "ឆ" |
| ប្រភេទនៃកាលបរិច្ឆេទ<br>( សំគាល់ដោយសញ្ញា ☑ ) | ☐ នីតិវិធីត្រៀម ☑ ទាញហេតុផលផ្ទាល់មាត់ ☐ ប្រកាសសាលក្រម<br>........................................................................................ |
| ប្រភេទនៃឯកសារភ្ជាប់មកជាមួយ<br>( សំគាល់ដោយសញ្ញា ☑ ) | ឯកសារស្ដីពីចំណុចនៃការសាកសួរ<br>ឯកសារស្ដីពីចំណុចនៃការធ្វើកោសល្យវិច័យ |
| ទណ្ឌកម្មជាអាទិ៍ក្នុងករណីដែលមិនបង្ហាញ ខ្លួនដោយគ្មានមូល ហេតុ ត្រឹមត្រូវ | -បើដើមចោទមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទលើកទី១ នៃនីតិវិធីត្រៀមសំរាប់ ការទាញហេតុផលទេតុលាការត្រូវច្រានចោលការទាមទាររបស់ដើមចោទនោះ ដោយសាលក្រមកំបាំង មុខ តាមមាត្រា២០០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។<br>-បើចុងចំលើយមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទលើកទី១ នៃនីតិវិធីត្រៀម សំរាប់ការទាញហេតុផលទេ តុលាការត្រូវបញ្ចប់នីតិវិធីត្រៀមសំរាប់ការទាញ ហេតុផលដោយភ្លាមៗ ហើយកំណត់នូវកាលបរិច្ឆេទលើកទី១ នៃការទាញ ហេតុ ផលដោយផ្ទាល់មាត់ តាមមាត្រា ២០១ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ |

សូមបង្ហាញខ្លួនដូច ដែលបានចែងខាងលើនេះ ។

ថ្ងៃពុធ ១៤រោច ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

[illegible] ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩

[illegible]ចៅក្រម

គឹម រ័ត្នណារិ

យើង...[illegible]...............ជា..[illegible]

បានប្រគល់ដីកាកោះនេះឱ្យឈ្មោះ..[illegible]........

មានទីលំនៅបច្ចុប្បន្ននៅភូមិ..[illegible]........ឃុំ.[illegible]

ស្រុក..[illegible]......ខេត្ត..[illegible]..........នៅថ្ងៃទី

...09........ខែ..[illegible]....ឆ្នាំ..2019...ហើយយើងបាន

ប្រាប់ថាសាម៉ីខ្លួន ត្រូវប្រគល់ចុងដីកាកោះនេះ ដល់ក្រឡាបញ្ជី នៅពេលដែលខ្លួនចូលទៅចំពោះមុខតុលាការខេត្តកណ្ដាល។

អ្នកទទួល

អ្នកប្រគល់

ក្រឡាបញ្ជី[illegible]

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមរដ្ឋប្បវេណី**
លេខ
ចុះថ្ងៃទី ខែ ឆ្នាំ
សំណុំរឿងរដ្ឋប្បវេណីលេខ
ចុះថ្ងៃទី ខែ ឆ្នាំ

## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ នៅថ្ងៃទី ខែ ឆ្នាំ វេលាម៉ោង និង នាទីរសៀល នៅសាលសវនាការទី លើសំណុំរឿងរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ខែ ឆ្នាំ ដោយមានសមាសភាព៖

### <u>ចៅក្រមជំនុំជម្រះ</u>

លោក **ស សំណាង** ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

### <u>ក្រឡាបញ្ជី</u>

លោក **ហ៊ីន សំភ្ជា** ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

<u>ដើមចោទ</u>៖ ឈ្មោះ ភេទ អាយុ ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ ផ្លូវលេខ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

<u>អ្នកតំណាងដោយអាណត្តិ</u>៖ លោកមេធាវី មានការិយាល័យនៅផ្ទះលេខ ផ្លូវលេខ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

<u>ចុងចម្លើយ</u>៖ ឈ្មោះ ភេទ អាយុ ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិ ឃុំ ស្រុក ខេត្ត ។

<u>អ្នកតំណាងដោយអាណត្តិ</u>៖ លោកមេធាវី មានការិយាល័យនៅផ្ទះលេខ ផ្លូវលេខ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

### <u>អង្គហេតុ និងចំណុចវិវាទ</u>

១-ខ្លឹម<u>សារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ</u>៖

ក-សុំលែងលះពីចុងចម្លើយឈ្មោះ ។

ខ-សុំមានអំណាចមេបាលើកូនឈ្មោះ ភេទ អាយុ ឆ្នាំ កើតថ្ងៃទី ខែ ឆ្នាំ ។

គ-សុំបែងចែកទ្រព្យសម្បត្តិរួមជាពីរចំណែកស្មើគ្នាមាន៖

គ.១-រថយន្តម៉ាក TOYOTA HILUX ពណ៌ ផលិតឆ្នាំ សម្គាល់ដោយស្លាកលេខ ចុះថ្ងៃទី ខែ ឆ្នាំ ។

គ.១-អចលនទ្រព្យ៖ ដី និងផ្ទះទំហំ x ( គុណ ) ម៉ែត្រការ៉េ, លេខក្បាលដី សម្គាល់ដោយគំនូសបង្ហាញទីតាំងដីសាងសង់លំនៅឋាន ចុះថ្ងៃទី ខែ ឆ្នាំ មានទីតាំងស្ថិតនៅផ្លូវជាតិលេខ ភូមិ ឃុំ ស្រុក ខេត្ត ។

ឃ-សុំទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្តី។

២-ការពន្យល់ត្រួសៗអំពីរឿងក្តី៖

កាលពីថ្ងៃទី ខែ ឆ្នាំ ដើមចោទឈ្មោះ បានរៀបអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយឈ្មោះ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់។ នៅក្នុងចំណងអាពាហ៍ពិពាហ៍ ដើមចោទ និងចុងចម្លើយមានកូនមួយនាក់ឈ្មោះ ភេទ អាយុ ឆ្នាំ កើតថ្ងៃទី ខែ ឆ្នាំ មានសំបុត្រកំណើតលេខ ចុះថ្ងៃទី ខែ ឆ្នាំ និងមានទ្រព្យសម្បត្តិរួមដូចជា៖ ១.រថយន្តម៉ាក TOYOTA HILUX ពណ៌ ផលិតឆ្នាំ សម្គាល់ដោយស្លាកលេខ ចុះ ថ្ងៃទី ខែ ឆ្នាំ និង ២.អចលនទ្រព្យ៖ ផ្ទះ និងដីទំហំ x ( គុណ ) ម៉ែត្រការ៉េ, លេខក្បាលដី សម្គាល់ដោយគំនូសបង្ហាញទីតាំងដីសាងសង់លំនៅឋាន ចុះថ្ងៃទី ខែ ឆ្នាំ មានទីតាំងស្ថិតនៅផ្លូវជាតិលេខ ភូមិ ឃុំ ស្រុក ខេត្ត (អចលនទ្រព្យនេះកំពុងដំណើរការនីតិវិធីចុះបញ្ជីដីធ្លី ដែលអាជ្ញាធរបានចុះទៅវាស់វែង កំណត់ព្រំរួចរាល់ហើយ និងពុំមានជម្លោះជាមួយបុគ្គលណាម្នាក់ឡើយ)។ ក្រោយពេលរៀបអាពាហ៍ពិពាហ៍ មួយរយៈចុងក្រោយនេះ ដើមចោទ និងចុងចម្លើយរស់នៅពុំចុះសម្រុងនឹងគ្នា និងមិនអាចបន្តរស់នៅជាមួយគ្នាបាន រហូតឈានដល់ការបែកលំនៅឋានពីគ្នាតាំងពីថ្ងៃទី ខែ ឆ្នាំ មកម្ល៉េះ ដែលបច្ចុប្បន្ននេះ ដើមចោទបានមករស់នៅផ្ទះលេខ ផ្លូវលេខ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។ ដើមចោទ និងចុងចម្លើយអស់មនោសញ្ចេតនាជាប្ដីប្រពន្ធនឹងគ្នាតទៅទៀតហើយ ដែលធ្វើឱ្យទំនាក់ទំនងអាពាហ៍ពិពាហ៍នេះត្រូវបែកបាក់ទាំងស្រុង ហើយគ្មានសង្ឃឹមថានឹងអាចបដិសានឡើងវិញបានឡើយ។ បន្ថែមពីនេះ ដើមចោទបានសុំសិទ្ធិធ្វើជាអ្នកមានអំណាចមេបាលើកូនប្រុសឈ្មោះ ខាងលើ ដោយសារដើមចោទមានប្រាក់ចំណូលជាក់លាក់គ្រប់គ្រាន់ក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូន និងអាចឱ្យកូនរៀននៅសាលាល្អបាន។ ជាពិសេស ដើមចោទមានពេលគ្រប់គ្រាន់ក្នុងការមើលថែរក្សាកូនឱ្យបានដិតដល់ ដើម្បីឱ្យកូនរស់នៅប្រកបដោយភាពកក់ក្ដៅ និងមានអនាគតល្អ។

៣-អង្គហេតុដែលអះអាងដោយដើមចោទ៖

ខ្លួន និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍កាលពីឆ្នាំ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់។ អំឡុងពេលរួមរស់ជាមួយគ្នាជាប្ដីប្រពន្ធមានកូនម្នាក់ឈ្មោះ ភេទ កើតថ្ងៃទី ខែ ឆ្នាំ ។ ខ្លួនទាមទារលែងលះពីចុងចម្លើយ។ ខ្លួននៅតែទាមទារការមានអំណាចមេបាលើកូនដដែល។ ដោយឡែកអចលនទ្រព្យមានផ្ទះ និងដីទំហំ x ( គុណ ) ម៉ែត្រការ៉េ បើជាទ្រព្យដោយឡែករបស់ចុងចម្លើយ ខ្លួនមិនទាមទារទេ។ ចំពោះរថយន្តម៉ាក TOYOTA HILUX ពណ៌ ផលិតឆ្នាំ សម្គាល់ដោយស្លាកលេខ ចុះថ្ងៃទី ខែ ឆ្នាំ ខ្លួនសុំបែងចែកជាពីរចំណែកស្មើគ្នា។

៤-សេចក្តីថ្លែងការណ៍របស់អ្នកតំណាងដោយអាណត្តិរបស់ដើមចោទ៖

អ្នកតំណាងដោយអាណត្តិឱ្យដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ថា៖ កូនក្តីរបស់ខ្លួន និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាកាលពីថ្ងៃទី ខែ ឆ្នាំ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ស្របទៅតាមច្បាប់ ដែលមានសំបុត្រអាពាហ៍ពិពាហ៍លេខ ចុះថ្ងៃទី ខែ ឆ្នាំ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំ ។ នៅក្នុងចំណងអាពាហ៍ពិពាហ៍ ខ្លួន និងចុងចម្លើយមានកូនមួយនាក់ឈ្មោះ ភេទ អាយុ ឆ្នាំ កើតថ្ងៃទី ខែ ឆ្នាំ មានសំបុត្របញ្ជាក់កំណើតលេខ ចុះថ្ងៃទី ខែ ឆ្នាំ និងមានទ្រព្យរួមដូចជា៖ ១.រថយន្តម៉ាក TOYOTA HILUX ពណ៌ ផលិតឆ្នាំ សម្គាល់ដោយស្លាកលេខ ចុះថ្ងៃទី ខែ ឆ្នាំ ដែលមានឈ្មោះកូនក្តីខ្លួនឈ្មោះ ជាកម្មសិទ្ធិករលើប័ណ្ណសម្គាល់រថយន្ត, ២.ដីសម្គាល់ដោយវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី ខែ ឆ្នាំ ស្ថិតនៅភូមិ ឃុំ ស្រុក ខេត្ត ។

ចំពោះដីនេះ កូនក្តីខ្លួនបានប្រគល់ប្រាក់សុទ្ធដោយផ្ទាល់ចំនួន ( ) ដុល្លារអាមេរិក ឱ្យទៅលោក ដែលជាឪពុករបស់ចុងចម្លើយដើម្បីជាថ្នូរនឹងការធ្វើអំណោយលើដីខាងលើមកឱ្យកូនក្តីរបស់ខ្លួន និងចុងចម្លើយជាទ្រព្យរួមក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ កាលពីអំឡុងឆ្នាំ ដែលក្នុងនោះប្រាក់ចំនួន ( ) ដុល្លារអាមេរិក ជាប្រាក់ចំណងដៃអាពាហ៍ពិពាហ៍របស់កូនក្តីរបស់ខ្លួន និងចុងចម្លើយ និងប្រាក់ចំនួន ( ) ដុល្លារអាមេរិក ជាប្រាក់ផ្ទាល់ខ្លួនរបស់កូនក្តីរបស់ខ្លួន, ៣.ផ្ទះទំហំ x ម$^{២}$ មានជាន់ផ្ទាល់ដី ជាន់ឡៅតឿ និងជាន់ទី១ ព្រមទាំងអគារចង្ក្រានបាយដែលបានសាងសង់នៅលើទីតាំងខាងលើ អស់ទឹកប្រាក់ចំនួន ( ) ដុល្លារអាមេរិក ជាប្រាក់ដែលកូនក្តីខ្លួន និងចុងចម្លើយរកបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍, ប្រាក់សុទ្ធចំនួន ( ) ដុល្លារអាមេរិក (បានផ្ទេរតាមធនាគារទៅឱ្យចុងចម្លើយ), ៥.ប្រាក់លក់ដីចំការនៅខេត្តកោះកុងចំនួន ( ) ដុល្លារអាមេរិក (បានប្រគល់ឱ្យចុងចម្លើយដោយផ្ទាល់) និងទ្រព្យដោយឡែករបស់ដើមចោទ៖ នៅមុនពេលអាពាហ៍ពិពាហ៍ កូនក្តីរបស់ខ្លួនមានសម្ភារៈដូចជា ។ បច្ចុប្បន្ន ទ្រព្យដោយឡែកនេះបានដាក់នៅក្នុងឃ្លាំងនៃដីដែលជាទ្រព្យរួមខាងលើ។

យោងតាមអង្គហេតុខាងលើឃើញថា កូនក្តីខ្លួន និងចុងចម្លើយរស់នៅពុំចុះសំរុងនឹងគ្នា និងមិនអាចបន្តរស់នៅជាមួយគ្នាបានរហូតឈានដល់ការបែកលំនៅឋានពីគ្នាតាំងពីថ្ងៃទី ខែ ឆ្នាំ រហូតមកដល់បច្ចុប្បន្ននេះ។ ទំនាក់ទំនងអាពាហ៍ពិពាហ៍នេះត្រូវបានបែកបាក់ទាំងស្រុង និងគ្មានសង្ឃឹមថានឹងអាចត្រឡប់ទៅត្រូវគ្នាដូចដើមវិញបានឡើយ។ ករណីនេះយើងឃើញថា វាជាមូលហេតុមួយនៃការលែងលះដូចមានចែងក្នុងចំណុច ង កថាខណ្ឌទី១ នៃមាត្រា៩៧៨ នៃក្រមរដ្ឋប្បវេណីខាងលើ ដែលចែងថា អាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន។ សរុបមកដោយផ្អែកតាមអង្គហេតុ និងមាត្រា៩៧៨-១-ង ដើមចោទអាចប្តឹងលែងលះពីចុងចម្លើយបាន។

យោងតាមពាក្យស្នើសុំពិនិត្យភស្តុតាង ចុះថ្ងៃទី ខែ ឆ្នាំ ដែលកូនក្តីខ្លួនបានដាក់ជូនតុលាការពិនិត្យឃើញថា កូនក្តីខ្លួនជា មានការអប់រំ និងមានប្រាក់ចំណូលខ្ពស់ មានជីវភាពធូរធារ ដូចនេះកូនក្តីរបស់ខ្លួនមានលទ្ធភាពឱ្យកូនចូលសិក្សាសាលាល្អ ផ្តល់សម្ភារៈផ្សេងៗដើម្បីបំពេញតាមតម្រូវការរបស់កូន និងមានក្រុមគ្រួសារជួយមើលថែរក្សាជិតដល់គ្រប់ពេលវេលា ដែលអាចធានាបានពីសុខសុវត្ថិភាព ភាពកក់ក្តៅ និងក្លាយជាកូនល្អ ពលរដ្ឋល្អ និងមានអនាគតល្អ។ ជាពិសេសជាងនេះទៅទៀត កូនក្តីខ្លួនសូមអះអាងថា នឹងផ្តល់ពេលវេលាដ៏សប្បាយរីករាយដល់កូន ដោយនាំគាត់ទៅដើរកម្សាន្តនៅរមណីយដ្ឋាននានានាពេលចុងសប្តាហ៍ ឬពេលសម្រាកពីការសិក្សារបស់កូន ដើម្បីឱ្យកូនរស់នៅក្នុងបរិយាកាសសប្បាយរីករាយ និងមានភាពកក់ក្តៅជាទីបំផុត។ ម្យ៉ាងវិញទៀត កូនក្តីខ្លួននឹងមិនទាមទារឱ្យចុងចម្លើយផ្តល់អាហារកាតព្វកិច្ចក្នុងការចិញ្ចឹមកូនអ្វីទាំងអស់ ក្នុងករណីយល់ព្រមប្រគល់សិទ្ធិអំណាចមេបាលើកូនមកឱ្យកូនក្តីខ្លួន។ ទាំងនេះបង្ហាញឱ្យឃើញពីលទ្ធភាព និងឆន្ទៈរបស់កូនក្តីខ្លួនដែលអាចផ្តល់ផលប្រយោជន៍ដល់កូនបានសព្វគ្រប់បែបយ៉ាង ស្របតាមស្មារតីនៃមាត្រា១០៣៧ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីខាងលើ។ សរុបមក តុលាការអាចកំណត់យកកូនក្តីខ្លួនធ្វើជាអ្នកមានសិទ្ធិអំណាចមេបាលើកូនបាននៅក្រោយពេលលែងលះគ្នា ព្រោះកូនក្តីខ្លួនអាចផ្តល់នូវផលប្រយោជន៍ដល់កូនបានគ្រប់បែបយ៉ាង។

យោងតាមអង្គហេតុខាងលើ និងពាក្យស្នើសុំពិនិត្យភស្តុតាង ចុះថ្ងៃទី ខែ ឆ្នាំ ត្រង់ចំណុច១ (តារាងតម្លៃសាងសង់ និងរូបភាពផ្ទះវីឡាដែលបានសាងសង់) និងចំណុច២ (គម្រោងសាងសង់លំនៅស្ថាន-ផ្ទះល្វែង) និងពាក្យស្នើសុំពិនិត្យភស្តុតាងបន្ថែម ចុះថ្ងៃទី ខែ ឆ្នាំ ដែលកូនក្តីខ្លួនបានដាក់ជូនតុលាការពិនិត្យ ឃើញថានៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ កូនក្តីខ្លួន និងចុងចម្លើយមានទ្រព្យរួមដូចជា៖ ១.រថយន្តម៉ាក TOYOTA HILUX ពណ៌ ផលិតឆ្នាំ

សម្គាល់ដោយស្លាកលេខ ចុះ ថ្ងៃទី ខែ ឆ្នាំ ដែលមានឈ្មោះ ជាកម្មសិទ្ធិករលើប័ណ្ណសម្គាល់រថយន្ត, ២.ដីសម្គាល់ដោយវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី ខែ ឆ្នាំ ស្ថិតនៅភូមិ ឃុំ ស្រុក ខេត្ត ។ ចំពោះដីនេះ កូនក្តីខ្លួនបានប្រគល់ប្រាក់ចំនួន ( ) ដុល្លារអាមេរិក ឲ្យទៅលោក ដែលជាឪពុករបស់ចុងចម្លើយដើម្បីជាថ្នូរនឹងការធ្វើអំណោយលើដីខាងលើមកឲ្យកូនក្តីខ្លួន និងចុងចម្លើយជាទ្រព្យរួមក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ កាលពីអំឡុងឆ្នាំ ដែលក្នុងនោះប្រាក់ចំនួន ( ) ដុល្លារអាមេរិក ជាប្រាក់ចំណងដៃអាពាហ៍ពិពាហ៍របស់កូនក្តីខ្លួន និងចុងចម្លើយ និងប្រាក់ចំនួន ( ) ដុល្លារអាមេរិក ជាប្រាក់ផ្ទាល់ខ្លួនរបស់កូនក្តីខ្លួន។ កាលនោះ ដីនេះនៅពុំទាន់ចុះបញ្ជីប្លង់កម្មសិទ្ធិ (ប្លង់រឹង) នៅឡើយទេ ហើយចុងចម្លើយអះអាងថានឹងចុះបញ្ជីធ្វើប្លង់កម្មសិទ្ធិ (ប្លង់រឹង) មកជាទ្រព្យសម្បត្តិរួមរវាងកូនក្តីខ្លួន និងចុងចម្លើយ។ ជាក់ស្តែងកាលពីថ្ងៃទី ខែ ឆ្នាំ កូនក្តីខ្លួន និងចុងចម្លើយបានទៅខ្ចីប្រាក់ពីធនាគារ ចំនួន ( ) ដុល្លារអាមេរិក ដោយយកដីខាងលើទៅដាក់ធានាភាគឭកិច្ចជាមួយធនាគារ (បង្កើតហ៊ីប៉ូតែក) ដែលមានបញ្ជាក់ថាជាកម្មសិទ្ធិរបស់ឈ្មោះ និងឈ្មោះ ។ នេះបង្ហាញឲ្យឃើញថា ចុងចម្លើយបានទទួលស្គាល់ថាដីនោះជាដីកម្មសិទ្ធិរួមរបស់ខ្លួនជាមួយនឹងកូនក្តីរបស់ខ្លួនរួចទៅហើយ។ ប៉ុន្តែ ក្រោយពេលដែលកូនក្តីខ្លួនមានបញ្ហា និងរស់នៅមិនចុះសម្រុងគ្នាជាមួយនឹងចុងចម្លើយ ទើបចុងចម្លើយបានទៅចុះបញ្ជីធ្វើប័ណ្ណកម្មសិទ្ធិ (ប្លង់រឹង) នៅរដ្ឋបាលសុរិយោដីតែឯកឯងស្ងាត់ៗ ដោយដាក់ឈ្មោះខ្លួនឯងតែម្នាក់ជាម្ចាស់កម្មសិទ្ធិ ដោយលួចលាក់ពុំឲ្យកូនក្តីខ្លួនបានដឹងឡើយ (ប្រែក្រឡាស់ពីការអះអាងរបស់ខ្លួនពីមុន ដែលសន្យាថានឹងចុះបញ្ជីធ្វើប័ណ្ណកម្មសិទ្ធិជាទ្រព្យសម្បត្តិរួម)។ ២.ផ្ទះ៖ កូនក្តីខ្លួនបានចំណាយពេលវេលា និងចំណេះជំនាញរបស់ខ្លួនក្នុងនាមជា ។ ចំពោះការសាងសង់ផ្ទះនេះ ត្រូវចំណាយអស់ប្រាក់ចំនួន ( និង ) ដុល្លារអាមេរិក ដោយគិតបញ្ចូលទាំងថ្លៃទិញសម្ភារៈទាំងអស់ និងចំណេះជំនាញដែលកូនក្តីខ្លួនមាន ក្នុងនាមជា ។ ប្រាក់ចំណាយក្នុងការសាងសង់ផ្ទះនេះ ជាប្រាក់ដែលរកបានក្នុងចំណងអាពាហ៍ពិពាហ៍ទាំងអស់ ហើយកូនក្តីខ្លួនសូមបដិសេធចោលទាំងស្រុងចំពោះលិខិតខ្ចីប្រាក់ដែលចុងចម្លើយខ្ចីពីឪពុករបស់ខ្លួន និងលិខិតខ្ចីប្រាក់ដែលចុងចម្លើយខ្ចីពីបងស្រីរបស់ខ្លួន ព្រោះវាគ្រាន់តែជាលិខិតឯកជនធម្មតា សន្លឹក ដែលគ្មានកាលបរិច្ឆេទស្នាពរ, គ្មានសាក្សី, គ្មានអាជ្ញាធរ ឬសាការីដឹងឮឡើយ ដូចនេះវាមិនមែនជាលិខិតយថាភូតដែលអាចយកមកធ្វើជាភស្តុតាងបន្ទាល់បានឡើយ ហើយលិខិតប្រភេទនេះអ្នកណាក៏អាចរៀបចំឡើងបានដែរ ដែលវាគ្មានតម្លៃជាភស្តុតាងដែលគួរឲ្យជឿទុកចិត្តសូម្បីតែបន្តិច។ ជាពិសេសជាងនេះទៅទៀត សូមលោកចៅក្រមមេត្តាកត់សម្គាល់ថា បើពិតជាមានការខ្ចីប្រាក់ពីឪពុក និងបងស្រីរបស់ចុងចម្លើយដើម្បីយកមកសាងសង់ផ្ទះនេះពិតប្រាកដមែន ហេតុអ្វីក៏គ្មានវត្តមានរបស់កូនក្តីខ្លួនចូលរួមខ្ចីជាមួយដែរ? ហើយការខ្ចីប្រាក់នេះមានដល់ទៅ លើក និងមានចំនួនសរុបយ៉ាងច្រើនដល់ទៅ ( ) ដុល្លារអាមេរិកឯណោះ! ដោយឡែក សូមក្រឡេកមើលទៅការខ្ចីប្រាក់ពីធនាគារ កាលពីថ្ងៃទី ខែ ឆ្នាំ ជាភស្តុតាងដែលចុងចម្លើយបានដាក់ជូនតុលាការពិនិត្យវិញម្តង ឃើញថាកម្ចីត្រឹមតែចំនួនទឹកប្រាក់ ( ) ដុល្លារអាមេរិក ប៉ុណ្ណោះ ក៏ចុងចម្លើយដាក់ឈ្មោះកូនក្តីខ្លួនឲ្យក្លាយជាអ្នកកម្ចីរួមគ្នាដែរ ចុះទម្រាំខ្ចីប្រាក់ពីឪពុក និងបងស្រីរបស់ខ្លួនយ៉ាងច្រើនសន្ធឹកសន្ធាប់បែបនេះ ចុះម្តេចមិនបបួលកូនខ្លួនឲ្យខ្ចីរួមគ្នាផង? នេះសបញ្ជាក់ឲ្យឃើញយ៉ាងច្បាស់ថា តាមពិតគ្មានការខ្ចីប្រាក់ពិតប្រាកដឡើយ វាគ្រាន់តែជាលិខិតឯកជនមួយដែលចុងចម្លើយរៀបចំជាភស្តុតាងឡើងតែប៉ុណ្ណោះ។ ដូចនេះយើងឃើញថា រថយន្ត, ដី និងផ្ទះ ដូចដែលបានរៀបរាប់ខាងលើនេះ សុទ្ធតែជាទ្រព្យសម្បត្តិរួមរបស់កូនក្តីខ្លួន និងចុងចម្លើយស្របតាមមាត្រា

៩៧៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ហើយដោយសារតែជាទ្រព្យសម្បត្តិរួម កូនក្តីរបស់ខ្លួន និងចុងចម្លើយមានសិទ្ធិទទួលបានម្នាក់ៗ ១ ភាគ ២ នៃទ្រព្យសម្បត្តិរួម ដោយផ្អែកតាមមាត្រា៩៨០ កថាខណ្ឌ២ ចំណុចខ ស្តីពីការបែងចែកទ្រព្យសម្បត្តិរួមនៅពេលលែងលះគ្នា នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

សរុបមក កូនក្តីរបស់ខ្លួនមានសិទ្ធិទាមទារចំណែក ១ ភាគ ២ នៃដី និងថ្លៃចំណាយសរុបក្នុងការសាងសង់ផ្ទះខាងលើ ដោយស្របតាមច្បាប់ដែលនៅជាធរមាន។

៥-<u>អង្គហេតុដែលការអះអាងដោយចុងចម្លើយ</u>៖

ខ្លួនឯកភាពក្នុងការលែងលះពីដើមចោទ តែបដិសេធក្នុងការប្រគល់ការមានអំណាចមេបាលើកូនឱ្យទៅដើមចោទ។ ចុងចម្លើយបែងចែកទ្រព្យសម្បត្តិរួមជាពីរចំណែកស្មើគ្នានូវរថយន្តម៉ាក TOYOTA HILUX ពណ៌ ផលិតឆ្នាំ សម្គាល់ដោយស្លាកលេខ ចុះថ្ងៃទី ខែ ឆ្នាំ ប៉ុន្តែចំពោះអចលនទ្រព្យ ខ្លួនមិនព្រមបែងចែកជាពីរចំណែកទេ ដោយសារទ្រព្យនេះជាកេរ្តិ៍ដែលឪពុកម្តាយខ្លួនប្រគល់ឱ្យខ្លួន។

៦-<u>សេចក្តីថ្លែងការណ៍របស់អ្នកតំណាងដោយអាណត្តិរបស់ចុងចម្លើយ</u>៖

អ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយបានធ្វើសេចក្តីថ្លែងការណ៍ថា៖ កាលពីថ្ងៃទី ខែ ឆ្នាំ ដើមចោទបានដាក់ពាក្យបណ្តឹងលែងលះជាមួយកូនក្តីរបស់ខ្លួន និងសុំកំណត់យកអំណាចមេបាលើកូនមួយនាក់ និងបែងចែកទ្រព្យសម្បត្តិមានរថយន្តមួយគ្រឿង និងអចលនទ្រព្យមួយកន្លែង។ យោងតាមសំបុត្រអាពាហ៍ពិពាហ៍ ចុះថ្ងៃទី ខែ ឆ្នាំ កូនក្តីរបស់ខ្លួនយល់ព្រមក្នុងការលែងលះជាមួយនឹងដើមចោទ។ យោងតាមសំបុត្របញ្ជាក់កំណើត ចុះថ្ងៃទី ខែ ឆ្នាំ របស់កូនឈ្មោះ កូនក្តីរបស់ខ្លួននៅតែទាមទារអំណាចមេបាដោយហេតុថា៖ ១.ដូចនឹងការអះអាងរបស់កូនក្តីខ្លួននៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ក្រោយពីការរស់នៅមិនចុះសម្រុង ដើមចោទបានចុះចាកចេញពីផ្ទះរយៈពេលជិតមួយឆ្នាំមកហើយ យោងតាមពាក្យបណ្តឹងចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ ដោយទុកឱ្យកូនក្តីនៅចិញ្ចឹមបីបាច់កូនតូចតែម្នាក់ឯង ហើយដើមចោទពុំដែលមកមើលកូន និងផ្តល់ជាសោហ៊ុយក្នុងការចិញ្ចឹមបីបាច់កូនឡើយ រហូតដល់ថ្ងៃនេះ។ ការអះអាងនេះក៏ត្រូវបានទទួលស្គាល់ពីដើមចោទនៅក្នុងដំណាក់កាលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផងដែរ ហើយដើមចោទមកមើលកូនតែពីរដងគត់ក្នុងរយៈពេល២សប្តាហ៍ដំបូង ក្រោយពីចុះចាកចេញពីផ្ទះ។ ២.ដូចនឹងការអះអាងរបស់កូនក្តីខ្លួននៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដើមចោទពុំមានមុខរបរដែលមានចំណូលទៀងទាត់ និងពុំមានទីស្នាក់អាស្រ័យជាអចិន្ត្រៃយ៍ឡើយ ដែលសព្វថ្ងៃស្នាក់នៅជាមួយឪពុកម្តាយនៅ ដោយឡែកកូនក្តីខ្លួនមានផ្ទះនៅទីប្រជុំជន និងមុខរបរនៅផ្ទះលក់គ្រឿងសំណង់ ដែលមានចំណូលយ៉ាងទៀងទាត់ជាប្រចាំថ្ងៃ។ ជាក់ស្តែងតាំងពីដើមចោទចុះចាកចេញពីផ្ទះរបស់កូនក្តីខ្លួនមក កូនក្តីខ្លួនពុំមានផលវិបាកណាមួយចំពោះកូនឡើយ ផ្ទុយទៅវិញក៏បានចិញ្ចឹមបីបាច់កូនមានសុខភាពល្អ និងបញ្ជូនកូនទៅសិក្សារៀនសូត្រនៅសាលារៀនជិតផ្ទះរស់នៅរាល់ថ្ងៃផងដែរ។ ការអះអាងនេះក៏ត្រូវបានទទួលស្គាល់ពីដើមចោទនៅក្នុងដំណាក់កាលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដែរ។ ៣.ដូចនឹងការអះអាងរបស់កូនក្តីខ្លួននៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដើមចោទក៏ធ្លាប់ធ្វើសកម្មភាពបោកប្រាស់ទ្រព្យសម្បត្តិនៅក្នុងផ្ទះ និងនៅចំពោះមុខកូនតូចផងដែរ ដែលជាមូលហេតុចម្បងមួយអាចនឹងធ្វើឱ្យប៉ះពាល់ដល់ការរស់នៅ និងផ្លូវចិត្តរបស់កូន។ ហេតុដូចនេះ កូនក្តីរបស់ខ្លួនស្នើសុំអំណាចមេបាលើកូន ដោយពុំទាមទារសោហ៊ុយអាហារកាតព្វកិច្ចអ្វីឡើយ។ ៤.ចំពោះរថយន្តមួយគ្រឿងម៉ាក TOYOTA HILUX ពណ៌ ផលិតឆ្នាំ យោងតាមកិច្ចសន្យាលក់ទិញរថយន្ត ចុះថ្ងៃទី ខែ ឆ្នាំ និងរូបភាពប្រតិបត្តិការផ្ញើប្រាក់ ចុះថ្ងៃទី ខែ ឆ្នាំ និងចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ កូនក្តីរបស់ខ្លួនយល់ព្រមបែងចែកជាពីរចំណែកស្មើគ្នា។ ហេតុដូចនេះ កូនក្តីរបស់ខ្លួនស្នើ

សុំបែងចែកជាពីរចំណែកស្មើគ្នាលើរថយន្តមួយគ្រឿងនេះតាមការព្រមព្រៀង។ ៥.ចំពោះអចលនវត្ថុទំហំ ម៉ែត្រការ៉េ ស្ថិតនៅភូមិ ឃុំ ស្រុក ខេត្ត យោងតាមវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ចុះថ្ងៃទី ខែ ឆ្នាំ ជាកម្មសិទ្ធិដោយឡែករបស់ឈ្មោះ និងលិខិតបញ្ជាក់ប្រវត្តិដី ចុះថ្ងៃទី ខែ ឆ្នាំ របស់ចៅសង្កាត់ កូនក្តីរបស់ខ្លួនពុំយល់ព្រមក្នុងការបែងចែកឡើយ ដោយហេតុថា អចលនវត្ថុនោះគឺជារបស់ឪពុកកូនក្តីខ្លួនដែលធ្វើអំណោយមកឱ្យកូនក្តីខ្លួន ហើយវាជាទ្រព្យសម្បត្តិដោយឡែក ដូចមានបញ្ជាក់ក្នុងភស្តុតាងខាងលើ។ នៅក្នុងដំណាក់កាលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដើមចោទក៏បានអះអាងថា ដើមចោទពុំបានធ្វើការទាមទារ និងទទួលស្គាល់ថាជាទ្រព្យសម្បត្តិដោយឡែករបស់កូនក្តីខ្លួនដែរ ប្រសិនបើកូនក្តីខ្លួនមានភស្តុតាងបង្ហាញ។ ដូចនឹងការអះអាងរបស់កូនក្តីខ្លួននៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចំពោះសំណង់ផ្ទះ គឺដើមចោទពុំដែលចេញប្រាក់ណាមួយយកមកសាងសង់ឡើយ គឺជាប្រាក់របស់កូនក្តីខ្លួនទៅខ្ចីគេមកសាងសង់ទាំងអស់ ដូចមានក្នុងភស្តុតាងកិច្ចសន្យា ចុះថ្ងៃទី ខែ ឆ្នាំ រវាងឈ្មោះ ឈ្មោះ និងធនាគារ និងលិខិតខ្ចីប្រាក់ ចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ និងលិខិតខ្ចីប្រាក់ ចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ ។ បំណុលទាំងអស់ ដើមចោទពុំដែលធ្វើការសងប្រាក់ទៅម្ចាស់បំណុលមួយណាឡើយ គឺកូនក្តីខ្លួនជាអ្នកសងគេទាំងអស់ចំពោះប្រាក់ដែលខ្ចីយកមកសាងសង់ផ្ទះនេះ។ ចំពោះភស្តុតាងដែលដើមចោទបានដាក់មានពាក្យសុំអនុញ្ញាតសាងសង់ កិច្ចសន្យាសាងសង់ក្នុងតំបន់ពុំទាន់អភិវឌ្ឍន៍ កិច្ចសន្យាហ៊ុំព័ទ្ធការដ្ឋាន គំនូសប្លង់បង្ហាញទីតាំងដីសាងសង់ គឺសុទ្ធតែជាបែបបទរដ្ឋបាលក្នុងការសាងសង់ដោយពុំមានចំណាយប្រាក់ណាមួយឡើយ។ ផ្ទុយទៅវិញចំពោះសម្ភារៈសំណង់គ្រប់យ៉ាង គឺកូនក្តីខ្លួនជាអ្នកខ្ចីប្រាក់គេទៅទិញយកមកសាងសង់ទាំងអស់។ កូនក្តីខ្លួនសូមបដិសេធចំពោះភស្តុតាងតារាងតម្លៃសាងសង់ដែលរៀបចំវាយកុំព្យូទ័រជាឯកតោភាគីរបស់ដើមចោទ ដោយពុំមានការទទួលស្គាល់ពីភាគីណាមួយថាដើមចោទបានចំណាយប្រាក់ក្នុងតារាងនោះឡើយ។ ៧.ចំណុចសុំដោយតុលាការធ្វើការចាប់អារម្មណ៍ក្នុងការពិចារណា ដោយហេតុថាត្បិតកូនក្តីខ្លួនរៀបអាពាហ៍ពិពាហ៍ជាមួយដើមចោទពិតប្រាកដមែន ដូចនឹងការអះអាងរបស់កូនក្តីខ្លួននៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដើមចោទពុំដែលផ្គត់ផ្គង់គ្រួសារឡើយ ដែលជាហេតុនាំឱ្យគ្រួសារបែកបាក់នេះ ជាក់ស្តែងមើលការទិញឡាន ក៏កូនក្តីរបស់ខ្លួនផ្ញើប្រាក់ផ្ទាល់ខ្លួនពីគណនីធនាគារផ្ទាល់ទៅកក់ក្រុមហ៊ុន និងផ្ញើទៅដើមចោទដើម្បីយកទៅបង់ឱ្យក្រុមហ៊ុនដែរ ពោលគឺកូនក្តីរបស់ខ្លួន និងដើមចោទទុកដាក់ប្រាក់រៀងខ្លួនតាំងពីដើមមក។ ប្រសិនបើដើមចោទពុំមានភស្តុតាងបញ្ជាក់អំពីការចំណាយប្រាក់ផ្ទាល់ខ្លួនក្នុងការសាងសង់ផ្ទះ ក្រៅពីតារាងតម្លៃសាងសង់ដែលរៀបចំវាយកុំព្យូទ័រឯកតោភាគីនោះទេ ផ្អែកតាមកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី ខែ ឆ្នាំ រវាងឈ្មោះ ឈ្មោះ និងធនាគារ និងលិខិតខ្ចីប្រាក់ ចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ និងលិខិតខ្ចីប្រាក់ ចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ

ពិតប្រភពប្រាក់ទាំងអស់ដែលយកមកសាងសង់ផ្ទះពិតប្រាកដមែន ហើយបំណុលទាំងអស់នេះ ក៏កូនក្តីខ្លួនធ្វើការសងប្រាក់ទៅម្ចាស់បំណុលតែម្នាក់ឯងដែរ។ ហេតុដូចនេះ កូនក្តីខ្លួនស្នើសុំឱ្យតុលាការប្រគល់អចលនវត្ថុទំហំ ម៉ែត្រការ៉េ ស្ថិតនៅ ឃុំ ស្រុក ខេត្ត យោងតាមវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ចុះថ្ងៃទី ខែ ឆ្នាំ ដែលជាកម្មសិទ្ធិដោយឡែករបស់ឈ្មោះ មកឱ្យកូនក្តីរបស់ខ្លួនតែម្នាក់ឯង។

៥-<u>អង្គហេតុដែលគូភាគីទទួលស្គាល់</u>៖ ការរៀបអាពាហ៍ពិពាហ៍, ការលែងលះ។

៦-<u>ចំណុចគ្មានវិវាទ</u>៖ ការលែងលះ។

៧-<u>ចំណុចវិវាទ</u>៖ ការមានអំណាចមេបា និងការបែងចែកទ្រព្យសម្បត្តិ។

## ការពិនិត្យភស្តុតាង

**១-ភស្តុតាងជាឯកសាររបស់ដើមចោទ៖**

១.១-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ (ថតចម្លង) ចំនួន០១ច្បាប់។

១.២-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ របស់ឈ្មោះ (ថតចម្លង) ចំនួន០១ច្បាប់។

១.៣-សំបុត្របញ្ជាក់កំណើតលេខ ចុះថ្ងៃទី ខែ ឆ្នាំ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំ ស្រុក ខេត្ត របស់ឈ្មោះ (ថតចម្លង) ចំនួន០១ច្បាប់។

១.៤-បណ្ណសម្គាល់យានយន្ត ចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ (ថតចម្លង) ចំនួន០១ច្បាប់។

១.៥-ពាក្យសុំអនុញ្ញាតសាងសង់ ចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ និងឈ្មោះ (ថតចម្លង) ចំនួន០១ច្បាប់។

១.៦-កិច្ចសន្យាសាងសង់ក្នុងតំបន់ពុំទាន់អភិវឌ្ឍន៍ ចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ និងឈ្មោះ (ថតចម្លង) ចំនួន០១ច្បាប់។

១.៧-កិច្ចសន្យាហ៊ុំព័ទ្ធការដ្ឋាន ចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ និងឈ្មោះ (ថតចម្លង) ចំនួន០១ច្បាប់។

១.៨-គំនូសប្លង់បង្ហាញទីតាំងដីសាងសង់លំនៅឋានរបស់ឈ្មោះ និងឈ្មោះ (ថតចម្លង) ចំនួន០១ច្បាប់។

១.៩-តារាងតម្លៃសាងសង់ និងរូបភាពផ្ទះវីឡាដែលបានសាងសង់ (ថតចម្លង) ចំនួន០១ច្បាប់។

១.១០-គម្រោងសាងសង់លំនៅស្ថាន-ផ្ទះល្វែង (ប្លង់ស្ថាបត្យកម្ម និងគម្រោងអគារ, ប្លង់ប្រព័ន្ធបណ្តាញទឹកក្នុងអគារ និងប្លង់បណ្តាញអគ្គិសនីក្នុងអគារ (ថតចម្លង) ចំនួន០១ច្បាប់។

១.១១-បរិញ្ញាបត្ររបស់ឈ្មោះ ចេញដោយសាកលវិទ្យាល័យ ចុះថ្ងៃទី ខែ ឆ្នាំ (ថតចម្លង) ចំនួន០១ច្បាប់។

១.១២-តារាងផ្ទេរប្រាក់ និងវិក្កយបត្រផ្ទេរប្រាក់ពីធនាគារ ឱ្យទៅចុងចម្លើយ (ថតចម្លង) ចំនួន០៨ច្បាប់។

**២-ភស្តុតាងជាឯកសាររបស់ចុងចម្លើយ៖**

២.១-សំបុត្រអាពាហ៍ពិពាហ៍លេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ និងឈ្មោះ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំ ស្រុក ខេត្ត (ថតចម្លង) ចំនួន០១ច្បាប់។

២.២-សំបុត្របញ្ជាក់កំណើតលេខ ចុះថ្ងៃទី ខែ ឆ្នាំ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំ ស្រុក ខេត្ត របស់ឈ្មោះ (ថតចម្លង) ចំនួន០១ច្បាប់។

២.៣-ពាក្យបណ្តឹង ចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ (ថតចម្លង) ចំនួន០១ច្បាប់។

២.៤-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី ខែ ឆ្នាំ ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត (ថតចម្លង) ចំនួន០១ច្បាប់។

២.៥-រូបភាពក្នុងប្រព័ន្ធសុរិយោដី (ថតចម្លង) ចំនួន០១ច្បាប់។

២.៦-បង្កាន់ដៃចុះបញ្ជីកម្មសិទ្ធិរបស់ឈ្មោះ (ថតចម្លង) ចំនួន០១ច្បាប់។

២.៧-លិខិតបញ្ជាក់ប្រវត្តិដី ចុះថ្ងៃទី ខែ ឆ្នាំ ចេញដោយចៅសង្កាត់ (ថតចម្លង) ចំនួន០១ច្បាប់។

២.៨-កិច្ចសន្យាលក់ទិញរថយន្តរបស់ឈ្មោះ (ថតចម្លង) ចំនួន០១ច្បាប់។

២.៩-រូបភាពប្រតិបត្តិការផ្ញើប្រាក់ ចុះថ្ងៃទី និងថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ (ថតចម្លង) ចំនួន០៥ច្បាប់។

២.១០-កិច្ចសន្យាខ្ចីប្រាក់ (ឥណទានអាជីវកម្មខ្នាតតូច) របស់ឈ្មោះ ឈ្មោះ និងធនាគារ ចុះថ្ងៃទី ខែ ឆ្នាំ (ថតចម្លង) ចំនួន០១ច្បាប់។

២.១១-លិខិតខ្ចីប្រាក់របស់ឈ្មោះ (ថតចម្លង) ចំនួន០២ច្បាប់។

៣-ការសាកសួរសាក្សី៖ គ្មាន។

## សំអាងហេតុ

ផ្អែកតាមលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាង តុលាការយល់ឃើញថា៖

១-ដើមចោទឈ្មោះ និងចុងចម្លើយឈ្មោះ បានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីខ្មែរ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ ចុះថ្ងៃទី ខែ ឆ្នាំ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានឃុំ ស្រុក ខេត្ត ដែលសមស្របតាមមាត្រា៩៥៥ នៃក្រមរដ្ឋប្បវេណី។

២-ដើមចោទ និងចុងចម្លើយបានព្រមព្រៀងគ្នាក្នុងការលែងលះដោយមានការស្ម័គ្រចិត្តរៀងៗខ្លួន ដោយមូលហេតុការរស់នៅមិនចុះសម្រុងនឹងគ្នា ទើបបណ្តាលឱ្យអស់មនោសញ្ចេតនាក្នុងការរួមរស់ជាមួយគ្នាជាប្តីប្រពន្ធតទៅទៀត អាចឱ្យតុលាការជឿបានថា៖ គូភាគីពិតជាមានបំណងក្នុងការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍ប្រាកដមែន។ ហេតុនេះ គប្បីតុលាការពិចារណា និងសម្រេចតាមការព្រមព្រៀងរបស់គូភាគីដែលសមស្របទៅនឹងមាត្រា៩៧៥ នៃក្រមរដ្ឋប្បវេណី។

៣-ការរួមរស់ជាមួយគ្នាជាប្តីប្រពន្ធ ដើមចោទ និងចុងចម្លើយមានកូនម្នាក់ឈ្មោះ ភេទ កើតថ្ងៃទី ខែ ឆ្នាំ ។ ដើមចោទសុំមានអំណាចមេបាលើកូន ប៉ុន្តែចុងចម្លើយបដិសេធ។ អ្នកតំណាងដោយអាណត្តិឱ្យដើមចោទបានលើកឡើងថា កូនក្តីខ្លួនជា មានការអប់រំ និងមានប្រាក់ចំណូលខ្ពស់ មានជីវភាពធូរធារ ដូចនេះកូនក្តីរបស់ខ្លួនមានលទ្ធភាព ឱ្យកូនចូលសិក្សាសាលាល្អ ផ្តល់សម្ភារៈផ្សេងៗដើម្បីបំពេញតាមតម្រូវការរបស់កូន និងមានក្រុមគ្រួសារជួយមើលថែរក្សា ជិតដល់គ្រប់ពេលវេលា ដែលអាចធានាបានពីសុខសុវត្ថិភាព ភាពកក់ក្តៅ និងក្លាយជាកូនល្អ ពលរដ្ឋល្អ និងមានអនាគតល្អ។ ជាពិសេសជាងនេះទៅទៀត កូនក្តីខ្លួនសូមអះអាងថា នឹងផ្តល់ពេលវេលាដ៏សប្បាយរីករាយដល់កូន ដោយនាំគាត់ទៅដើរ កម្សាន្តនៅរមណីយដ្ឋាននានានាពេលចុងសប្តាហ៍ ឬពេលសម្រាកពីការសិក្សារបស់កូន ដើម្បីឱ្យកូនរស់នៅក្នុងបរិយាកាសសប្បាយរីករាយ និងមានភាពកក់ក្តៅជាទីបំផុត។ ម៉្យាងវិញទៀត កូនក្តីខ្លួននឹងមិនទាមទារឱ្យចុងចម្លើយផ្តល់អាហារកាតព្វកិច្ចក្នុងការចិញ្ចឹមកូនអ្វីទាំងអស់ ក្នុងករណីយល់ព្រមប្រគល់សិទ្ធិអំណាចមេបាលើកូនមកឱ្យកូនក្តីខ្លួន។ ទាំងនេះបង្ហាញឱ្យឃើញពីលទ្ធភាព និងឆន្ទៈរបស់កូនក្តីខ្លួនដែលអាចផ្តល់ផលប្រយោជន៍ដល់កូនបានសព្វគ្រប់បែបយ៉ាង ស្របតាមស្មារតីនៃមាត្រា ១០៣៧ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីខាងលើ។ សរុបមក តុលាការអាចកំណត់យកកូនក្តីខ្លួនធ្វើជាអ្នកមានសិទ្ធិអំណាចមេបាលើកូនបាននៅក្រោយពេលលែងលះគ្នា ព្រោះកូនក្តីខ្លួនអាចផ្តល់នូវផលប្រយោជន៍ដល់កូនបានគ្រប់បែបយ៉ាង។ ចំណែក អ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយបានលើកឡើងថា កាលពីថ្ងៃទី ខែ ឆ្នាំ ដើមចោទបានដាក់ពាក្យបណ្តឹងលែងលះជាមួយកូនក្តីរបស់ខ្លួន និងសុំកំណត់យកអំណាចមេបាលើកូនមួយនាក់ និងបែងចែកទ្រព្យសម្បត្តិមានរថយន្តមួយគ្រឿង និងអចលនទ្រព្យមួយកន្លែង។ យោងតាមសំបុត្រអាពាហ៍ពិពាហ៍ ចុះថ្ងៃទី ខែ ឆ្នាំ

កូនក្ដីរបស់ខ្លួនយល់ព្រមក្នុងការលែងលះជាមួយនឹងដើមចោទ។ យោងតាមសំបុត្របញ្ជាក់កំណើត ចុះថ្ងៃទី ខែ ឆ្នាំ របស់កូនឈ្មោះ កូនក្ដីរបស់ខ្លួននៅតែទាមទារអំណាចមេបាដោយហេតុថា៖ ១.ដូចនឹងការអះអាងរបស់កូនក្ដីខ្លួននៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ក្រោយពីការរស់នៅមិនចុះសម្រុង ដើមចោទបានចុះចាកចេញពីផ្ទះរយៈពេលជិតមួយឆ្នាំមកហើយ យោងតាមពាក្យបណ្ដឹងចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ ដោយទុកឱ្យកូនក្ដីនៅចិញ្ចឹមបីបាច់កូនតូចតែម្នាក់ឯង ហើយដើមចោទពុំដែលមកមើលកូន និងផ្ដល់ជាសោហ៊ុយក្នុងការចិញ្ចឹមបីបាច់កូនឡើយ រហូតដល់ថ្ងៃនេះ។ ការអះអាងនេះក៏ត្រូវបានទទួលស្គាល់ពីដើមចោទនៅក្នុងដំណាក់កាលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផងដែរ ហើយដើមចោទមកមើលកូនតែពីរដងគត់ក្នុងរយៈពេល២សប្ដាហ៍ដំបូង ក្រោយពីចុះចាកចេញពីផ្ទះ។ ២.ដូចនឹងការអះអាងរបស់កូនក្ដីខ្លួននៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដើមចោទពុំមានមុខរបរដែលមានចំណូលទៀងទាត់ និងពុំមានទីស្នាក់អាស្រ័យជាអចិន្ត្រៃយ៍ឡើយ ដែលសព្វថ្ងៃស្នាក់នៅជាមួយឪពុកម្ដាយនៅខេត្ត ដោយឡែកកូនក្ដីខ្លួនមានផ្ទះនៅទីប្រជុំជន និងមុខរបរនៅផ្ទះលក់គ្រឿងសំណង់ ដែលមានចំណូលយ៉ាងទៀងទាត់ជាប្រចាំថ្ងៃ។ ជាក់ស្ដែងតាំងពីដើមចោទចុះចាកចេញពីផ្ទះរបស់កូនក្ដីខ្លួនមក កូនក្ដីខ្លួនពុំមានផលវិបាកណាមួយចំពោះកូនឡើយ ផ្ទុយទៅវិញក៏បានចិញ្ចឹមបីបាច់កូនមានសុខភាពល្អ និងបញ្ជូនកូនទៅសិក្សារៀនសូត្រនៅសាលារៀនជិតផ្ទះរស់នៅរាល់ថ្ងៃផងដែរ។ ការអះអាងនេះក៏ត្រូវបានទទួលស្គាល់ពីដើមចោទនៅក្នុងដំណាក់កាលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដែរ។ ៣.ដូចនឹងការអះអាងរបស់កូនក្ដីខ្លួននៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដើមចោទក៏ធ្លាប់ធ្វើសកម្មភាពបោកប្រាស់ទ្រព្យសម្បត្តិនៅក្នុងផ្ទះ និងនៅចំពោះមុខកូនតូចផងដែរ ដែលជាមូលហេតុចម្បងមួយអាចនឹងធ្វើឱ្យប៉ះពាល់ដល់ការរស់នៅ និងផ្លូវចិត្តរបស់កូន។ ហេតុដូចនេះ កូនក្ដីរបស់ខ្លួនស្នើសុំអំណាចមេបាលើកូន ដោយពុំទាមទារសោហ៊ុយអាហារកាតព្វកិច្ចអ្វីឡើយ។ ហេតុនេះ គប្បីតុលាការពិចារណា និងសម្រេចតាមបញ្ញត្តិមាត្រា១០៣៧ នៃក្រមរដ្ឋប្បវេណី។

៤-អំឡុងពេលរួមរស់ជាមួយគ្នា ដើមចោទ និងចុងចម្លើយមានទ្រព្យសម្បត្តិរួមដូចជា៖ ១. រថយន្តម៉ាក TOYOTA HILUX ពណ៌ ផលិតឆ្នាំ សម្គាល់ដោយស្លាកលេខ ចុះថ្ងៃទី ខែ ឆ្នាំ ដែលមានឈ្មោះ និង ២.អចលនទ្រព្យមានដី និងផ្ទះទំហំ x ម៉ែត្រការ៉េ លេខក្បាលដី សម្គាល់ដោយគំនូសបង្ហាញទីតាំងដីសាងសង់លំនៅឋាន ចុះថ្ងៃទី ខែ ឆ្នាំ មានទីតាំងស្ថិតនៅផ្លូវជាតិលេខ ភូមិ ឃុំ ស្រុក ខេត្ត ។ ចំពោះរថយន្តម៉ាក TOYOTA HILUX ពណ៌ ផលិតឆ្នាំ សម្គាល់ដោយស្លាកលេខ គូភាគីឯកភាពក្នុងបែងចែកជាពីរចំណែកស្មើគ្នា។ ចំណែកឯ អចលនទ្រព្យមានផ្ទះ និងដីទំហំ x ម៉ែត្រការ៉េ លេខក្បាលដី សម្គាល់ដោយគំនូសបង្ហាញ ទីតាំងដីសាងសង់លំនៅឋាន ចុះថ្ងៃទី ខែ ឆ្នាំ មានទីតាំងស្ថិតនៅផ្លូវជាតិលេខ ភូមិ ឃុំ ស្រុក ខេត្ត ដើមចោទស្នើសុំធ្វើការបែងចែកជាពីរចំណែកស្មើគ្នា ប៉ុន្តែចុងចម្លើយមិនឯកភាពក្នុងការបែងពីរទ្រព្យនេះជាពីរចំណែកស្មើគ្នាទេ។ អ្នកតំណាងដោយអាណត្តិឱ្យដើមចោទបានលើកឡើងថា កូនក្ដីខ្លួនបានប្រគល់ប្រាក់ចំនួន ( ) ដុល្លារអាមេរិក ឱ្យទៅលោក ជាឪពុកបង្កើតរបស់ចុងចម្លើយ ដើម្បីជាថ្នូរនឹងការធ្វើអំណោយដីខាងលើមកឱ្យកូនក្ដីខ្លួន និងចុងចម្លើយ។ ការលើកឡើងនេះមិនមានភស្ដុតាងដើម្បីឱ្យតុលាការពិនិត្យនោះទេ ហេតុនេះ គប្បីតុលាការមិនលើកយកចំណុចនេះមកពិចារណា និងសម្រេចឡើយ។ ដើមចោទបានផ្ទេរប្រាក់សុទ្ធចំនួន ( ) ដុល្លារអាមេរិក ឱ្យទៅចុងចម្លើយតាមរយៈធនាគារ ដើម្បីធ្វើការសាងសង់ផ្ទះ ដូចមាននៅក្នុងតារាងផ្ទេរប្រាក់ និងវិក្កយបត្រផ្ទេរប្រាក់ពីធនាគារឱ្យទៅចុងចម្លើយ (ថតចម្លង) ចំនួន០៨ច្បាប់។ ចំណុចនេះ គប្បីតុលាការលើកយកមកពិចារណា និងសម្រេចតាមមាត្រា ៩៨០ នៃក្រមរដ្ឋប្បវេណី។ ចំពោះប្រាក់លក់ដីចំការនៅខេត្តកោះកុង បានចំនួន ( ) ដុល្លារអាមេរិក

ដើមចោទបានប្រគល់ឱ្យចុងចម្លើយដោយផ្ទាល់ ដើមចោទមិនមានភស្តុតាងដាក់ជូនឱ្យតុលាការពិនិត្យនោះទេ ហេតុនេះ គប្បីតុលាការមិនលើកយកចំណុចនេះមកពិចារណា និងសម្រេចឡើយ។ ចំណែក អ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយ បានលើកឡើងថា ចំពោះអចលនវត្ថុទំហំ ម៉ែត្រការ៉េ ស្ថិតនៅភូមិ ឃុំ ស្រុក ខេត្ត យោងតាមវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ចុះថ្ងៃទី ខែ ឆ្នាំ ជាកម្មសិទ្ធិដោយឡែករបស់ឈ្មោះ និងលិខិតបញ្ជាក់ប្រវត្តិដី ចុះថ្ងៃទី ខែ ឆ្នាំ របស់ចៅសង្កាត់ កូនក្តីរបស់ខ្លួនពុំយល់ព្រមក្នុងការបែងចែកឡើយ ដោយហេតុថា អចលនវត្ថុនោះគឺជារបស់ឪពុក កូនក្តីខ្លួនដែលធ្វើអំណោយមកឱ្យកូនក្តីខ្លួន ហើយវាជាទ្រព្យសម្បត្តិដោយឡែក ដូចមានបញ្ជាក់ក្នុងភស្តុតាងខាងលើ។ នៅក្នុងដំណាក់កាលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដើមចោទក៏បានអះអាងថា ដើមចោទពុំបានធ្វើការទាមទារ និងទទួលស្គាល់ថាជាទ្រព្យសម្បត្តិដោយឡែករបស់កូនក្តីខ្លួនដែរ ប្រសិនបើកូនក្តីខ្លួនមានភស្តុតាងបង្ហាញ។ ដូចនឹងការអះអាងរបស់កូន ក្តីខ្លួននៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចំពោះសំណង់ផ្ទះ គឺដើមចោទពុំដែលចេញប្រាក់ណាមួយយកមកសាងសង់ឡើយ គឺជាប្រាក់របស់កូនក្តីខ្លួនទៅខ្ចីគេមកសាងសង់ទាំងអស់ ដូចមានក្នុងភស្តុតាងកិច្ចសន្យា ចុះថ្ងៃទី ខែ ឆ្នាំ រវាងឈ្មោះ ឈ្មោះ និងធនាគារ និងលិខិតខ្ចីប្រាក់ ចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ និងលិខិតខ្ចីប្រាក់ ចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ ។ បំណុលទាំងអស់ ដើមចោទពុំដែលធ្វើការសងប្រាក់ទៅម្ចាស់បំណុលមួយណាឡើយ គឺកូនក្តីខ្លួនជាអ្នកសងគេទាំងអស់ចំពោះប្រាក់ ដែលខ្ចីយកមកសាងសង់ផ្ទះនេះ។ ចំពោះភស្តុតាងដែលដើមចោទបានដាក់មានពាក្យសុំអនុញ្ញាតសាងសង់ កិច្ចសន្យាសាងសង់ ក្នុងតំបន់ពុំទាន់អភិវឌ្ឍន៍ កិច្ចសន្យាហ៊ុំព័ទ្ធការដ្ឋាន គំនូសប្លង់បង្ហាញទីតាំងដីសាងសង់ គឺសុទ្ធតែជាបែបបទរដ្ឋបាលក្នុងការសាងសង់ដោយពុំមានចំណាយប្រាក់ណាមួយឡើយ។ ផ្ទុយទៅវិញចំពោះសម្ភារៈសំណង់គ្រប់យ៉ាង គឺកូនក្តីខ្លួនជាអ្នកខ្ចីប្រាក់ គេទៅទិញយកមកសាងសង់ទាំងអស់។ កូនក្តីខ្លួនសូមបដិសេធចំពោះភស្តុតាងតារាងតម្លៃសាងសង់ដែលរៀបចំវាយកុំព្យូទ័រ ជាឯកតោភាគីរបស់ដើមចោទ ដោយពុំមានការទទួលស្គាល់ពីភាគីណាមួយថាដើមចោទបានចំណាយប្រាក់ក្នុងតារាងនោះឡើយ។ ដោយហេតុថាឡិតកូនក្តីខ្លួនរៀបអាពាហ៍ពិពាហ៍ជាមួយដើមចោទពិតប្រាកដមែន ដូចនឹងការអះអាងរបស់កូនក្តីខ្លួននៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដើមចោទពុំដែលផ្គត់ផ្គង់គ្រួសារឡើយ ដែលជាហេតុនាំឱ្យគ្រួសារបែកបាក់នេះ ជាក់ស្តែងមើលការទិញឡាន ក៏កូនក្តីរបស់ខ្លួនផ្ញើប្រាក់ផ្ទាល់ខ្លួនពីគណនីធនាគារផ្ទាល់ទៅកក់ក្រុមហ៊ុន និងផ្ញើទៅដើមចោទដើម្បីយកទៅបង់ឱ្យក្រុមហ៊ុនដែរ ពោលគឺកូនក្តីរបស់ខ្លួន និងដើមចោទទុកដាក់ប្រាក់រៀងខ្លួនតាំងពីដើមមក។ ប្រសិនបើដើមចោទពុំមានភស្តុតាងបញ្ជាក់អំពីការចំណាយប្រាក់ផ្ទាល់ខ្លួនក្នុងការសាងសង់ផ្ទះ ក្រៅពីតារាងតម្លៃសាងសង់ដែលរៀបចំវាយកុំព្យូទ័រឯកតោភាគីនោះទេ ផ្អែកតាមកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី ខែ ឆ្នាំ រវាងឈ្មោះ ឈ្មោះ និងធនាគារ និងលិខិតខ្ចីប្រាក់ ចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ និងលិខិតខ្ចីប្រាក់ ចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ

ពិតប្រភពប្រាក់ទាំងអស់ដែលយកមកសាងសង់ផ្ទះពិតប្រាកដមែន ហើយបំណុលទាំងអស់នេះ ក៏កូនក្តីខ្លួនធ្វើការសងប្រាក់ទៅម្ចាស់បំណុលតែម្នាក់ឯងដែរ។ ហេតុដូចនេះ កូនក្តីខ្លួនស្នើសុំឱ្យតុលាការប្រគល់អចលនវត្ថុទំហំ ម៉ែត្រការ៉េ ស្ថិតនៅភូមិ ឃុំ ស្រុក ខេត្ត យោងតាមវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ចុះថ្ងៃទី ខែ ឆ្នាំ ដែលជាកម្មសិទ្ធិដោយឡែករបស់ឈ្មោះ មកឱ្យកូនក្តីរបស់ខ្លួនតែម្នាក់ឯង។ ហេតុនេះ គប្បីតុលាការពិចារណា និងសម្រេចតាមមាត្រា៩៨០ នៃក្រមរដ្ឋប្បវេណី។

៥-ប្រាក់ប្រដាប់ក្តីគប្បីអនុវត្តតាមមាត្រា៦៤ កថាខណ្ឌ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

# <u>សេចក្តីសម្រេចបញ្ចប់</u>

១-ឱ្យដើមចោទឈ្មោះ និងចុងចម្លើយឈ្មោះ បានលែងលះគ្នា។

២-ឱ្យចុងចម្លើយឈ្មោះ មានអំណាចមេបាលើកូនឈ្មោះ ភេទ កើតថ្ងៃទី ខែ ឆ្នាំ ។ ភាគីដែលមិនមានអំណាចមេបាលើកូនមានសិទ្ធិជួបប្រាស្រ័យទាក់ទង និងសួរសុខទុក្ខជាមួយកូនបានជាធម្មតា។

៣-ប្រគល់អចលនទ្រព្យមាន៖ ដីទំហំ ( ) ម៉ែត្រការ៉េ និងផ្ទះទំហំ x ម៉ែត្រការ៉េ លេខក្បាលដី សម្គាល់ដោយគំនូសបង្ហាញទីតាំងដីសាងសង់លំនៅឋាន ចុះថ្ងៃទី ខែ ឆ្នាំ មានទីតាំងស្ថិតនៅផ្លូវជាតិលេខ ភូមិ ឃុំ ស្រុក ខេត្ត ឱ្យទៅចុងចម្លើយជាអ្នកគ្រប់គ្រង។

៤-ប្រគល់ប្រាក់ចំនួន ( ) ដុល្លារអាមេរិក ឱ្យទៅដើមចោទ។

៥-បែងចែកទ្រព្យសម្បត្តិរួមមាន រថយន្តម៉ាក TOYOTA HILUX ពណ៌ ផលិតឆ្នាំ សម្គាល់ដោយស្លាកលេខ ភ្នំពេញ ចុះថ្ងៃទី ខែ ឆ្នាំ ឱ្យទៅដើមចោទឈ្មោះ និងចុងចម្លើយឈ្មោះ ជាពីរចំណែកស្មើគ្នា។

៦-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

សាលក្រមនេះ បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី ខែ ឆ្នាំ និងប្រកាសជាសាធារណៈនៅថ្ងៃទី ខែ ឆ្នាំ ។ គូភាគីមានសិទ្ធិប្តឹងឧទ្ធរណ៍តាមច្បាប់កំណត់។

ថ្ងៃ ខែ ឆ្នាំ ព.ស.

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា៖ **ស សំណាង**

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃ ខែ ឆ្នាំ ព.ស.

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

ស_សំណាង

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ

**ក្រឡាបញ្ជី**

ហ៊ិន សក្កដា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ

**<u>លិខិតបញ្ជាក់ការចូលជាស្ថាពរនៃសាលក្រម</u>**

**យើង គឹក ស្រីមុំ ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ**

-បានឃើញ មាត្រា ២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រម នស/រកម/០៧០៦/២១ ចុះថ្ងៃទី ០៦.០៧.២០០៦ ។

-បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូង រាជធានីភ្នំពេញ ។

-បានឃើញ សាលក្រមលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ពាក្យសុំចុះថ្ងៃទី ខែ ឆ្នាំ របស់មេធាវីតំណាងដោយអាណត្តិឲ្យឈ្មោះ ដែលមានខ្លឹមសារសុំលិខិតបញ្ជាក់ការចូលស្ថាពរ នៃសាលក្រមលេខ ចុះថ្ងៃទី ខែធ្នូ ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ សេចក្តីអនុញ្ញាត ចុះថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ២០១៨ របស់ប្រធានសាលាដំបូងរាជធានីភ្នំពេញ។

**<u>សូមបញ្ជាក់ថា</u>**

១/សាលក្រមលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ បានចូលជា ចាប់ពីថ្ងៃទី ខែ ឆ្នាំ រួចហើយ ។

២/លិខិតបញ្ជាក់ការចូលស្ថាពរនៃសាលក្រមនេះ ចេញឲ្យសាមីខ្លួន ដើម្បីយកទៅប្រើប្រាស់តាមផ្លូវច្បាប់ ។

ថ្ងៃ ខែ ឆ្នាំ ព.ស

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ

**ក្រឡាបញ្ជី**

គឹក ស្រីមុំ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**


សាលាដំបូងរាជធានីភ្នំពេញ
ចូល លេខ ........
ថ្ងៃទី ខែ ឆ្នាំ
ម៉ោង


# ពាក្យបណ្តឹងឧទ្ធរណ៍

ខ្ញុំបាទ កើតនៅថ្ងៃទី ខែ ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ចុះថ្ងៃទី ខែ ឆ្នាំ មានអាសយដ្ឋានបច្ចុប្បន្នស្ថិតនៅផ្ទះលេខ១៧៨ ផ្លូវលេខ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ទូរស័ព្ទលេខ៖ ។

## សូមគោរពជូន

## ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ

*សូមមេត្តាជ្រាប។*

**កម្មវត្ថុ** ៖ សុំប្តឹងឧទ្ធរណ៍ចំពោះ**សាលក្រមរដ្ឋប្បវេណីលេខ៖ ចុះថ្ងៃទី ខែ ឆ្នាំ** របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់សេចក្តីសម្រេចបញ្ចប់**ចំណុច ២** និងចំណុចដែលតុលាការមិនបានសម្រេចសេចក្តីតាមការទាមទាររបស់ខ្ញុំបាទ ដែលទាក់ទងនឹងទ្រព្យដោយឡែកដូចបានរៀបរាប់ក្នុង**ចំណុច ២ នៃសេចក្តីថ្លែងការណ៍បន្ថែម** របស់លោក**មេធាវី** ចុះថ្ងៃទី ខែ ឆ្នាំ ។

**យោង** ៖ **សាលក្រមរដ្ឋប្បវេណីលេខ៖ ចុះថ្ងៃទី ខែ ឆ្នាំ** របស់សាលាដំបូងរាជធានីភ្នំពេញ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា៖ កាលពីថ្ងៃទី ខែ ឆ្នាំ សាលាដំបូងរាជធានីភ្នំពេញបានប្រកាស**សាលក្រមរដ្ឋប្បវេណីលេខ៖ ចុះថ្ងៃទី ខែ ឆ្នាំ** ជាសាធារណៈ និងបានប្រគល់សាលក្រមនេះមកឱ្យខ្ញុំបាទ តាមរយៈមេធាវីតំណាងដោយអាណត្តិរបស់ខ្ញុំបាទ នៅថ្ងៃទី ខែ ឆ្នាំ ។

ដោយហេតុថា ខ្ញុំបាទមិនសុខចិត្តចំពោះសេចក្តីសម្រេចនៃសាលក្រមខាងលើនេះត្រង់**ចំណុច ២** ទាំងស្រុង និងចំណុចដែលតុលាការមិនបានសម្រេចសេចក្តីតាមការទាមទាររបស់ខ្ញុំបាទ ទាក់ទងនឹងទ្រព្យដោយឡែករបស់ខ្ញុំបាទ ដែលរួមមានសម្ភារៈ ដូចជា ក្តារពុម្ព, ទិប, ជន្ទល, ម៉ូទ័របុក, ម៉ូទ័រស្វាន, ម៉ាស៊ីនបង្ហាប់ និងសម្ភារៈសំណង់ផ្សេងទៀត ដូចដែលបានរៀបរាប់ក្នុង**ចំណុច ២ នៃសេចក្តីថ្លែងការណ៍បន្ថែម** របស់លោក**មេធាវី** (មេធាវីតំណាងដោយអាណត្តិរបស់ខ្ញុំបាទ) ចុះថ្ងៃទី ខែ ឆ្នាំ ។

សេចក្តីសម្រេចនេះ មានភាពអយុត្តិធម៌ និងធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ខ្ញុំបាទ ហេតុដូច្នោះហើយ ទើបខ្ញុំបាទដាក់ពាក្យបណ្តឹងឧទ្ធរណ៍ចំពោះ**សាលក្រមរដ្ឋប្បវេណីលេខ៖ ចុះថ្ងៃទី ខែ ឆ្នាំ** របស់សាលាដំបូងរាជធានីភ្នំពេញត្រង់សេចក្តីសម្រេចបញ្ចប់**ចំណុច ២** និងចំណុច

ដែលតុលាការមិនបានសម្រេចសេចក្តីតាមការទាមទាររបស់ខ្ញុំបាទ ដែលទាក់ទងនឹងទ្រព្យដោយឡែកដូចបានរៀបរាប់ក្នុង**ចំណុច ២ នៃសេចក្តីថ្លែងការណ៍បន្ថែម** របស់លោក**មេធាវី** ចុះថ្ងៃទី ខែ ឆ្នាំ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាទទួលពាក្យបណ្តឹងឧទ្ធរណ៍របស់ខ្ញុំបាទខាងលើ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ៕

ថ្ងៃ ខែ ឆ្នាំ ព.ស

ថ្ងៃទី ខែ ឆ្នាំ

**ស្នាមមេដៃស្តាំ**

<u>ជូនភ្ជាប់មកជាមួយនូវ៖</u>

- សាលក្រមរដ្ឋប្បវេណីលេខ៖ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ (ច្បាប់ថតចម្លង១ច្បាប់)។
- សេចក្តីថ្លែងការណ៍បន្ថែម ចុះថ្ងៃទី ខែ ឆ្នាំ របស់លោកមេធាវី (ច្បាប់ថតចម្លង១ច្បាប់)។